ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"

**សាធារណៈ**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

## ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩
## សវនាការលើអង្គសេចក្តី (លើកទី ១៤)

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាចាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ បេ៊ត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទួអាត ហ្វដ *(Mr.Stuart FORD)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្គេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោក គឹម ម៉េងឃី

លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោក ហ្វីលីព កាណុន

*(Mr. Philippe Canonne)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ខ្លឹមសារ

## សាក្សី

**សាក្សី ៖** ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច

សួរដោយ លោក អាឡិចសាន់ឌឺ ប៊េត ផ្តើមពី ........................................ ទំព័រ ២

សួរដោយ កញ្ញា ទី ស្រ៊ីនណា ផ្តើមពី ........................................ ទំព័រ ១៣

សួរដោយ លោក អាឡាំង វ៉ែនណឺ ផ្តើមពី ........................................ ទំព័រ ២៣

សួរដោយ លោកស្រី ស៊ីលឃិ ស្ទូតហ្សីនស្គី ផ្តើមពី........................................ ទំព័រ ៣៨

សួរដោយ លោក ហ្វីលីព កាណុន ផ្តើមពី ........................................ ទំព័រ ៥២

សួរដោយ លោក គីម ម៉េងឃី ផ្តើមពី........................................ ទំព័រ ៥៨

សួរដោយ លោក ហុង គីមសួន ផ្តើមពី ........................................ ទំព័រ ៦១

## បញ្ជីឈ្មោះ អ្នកនិយាយ៖

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| លោក អាឡិចសាន់ឌឺ ប៊ែត | អង់គ្លេស |
| ចៅក្រម និល ណុន (ប្រធាអង្គជំនុំជម្រះ) | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោក អាឡាំង វែនណឺ | អង់គ្លេស |
| លោកស្រី ស៊ីលឃិ ស្ទួតហ្សឺនស្គី | អង់គ្លេស |
| លោក ហ្វីលីព កាណុន | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គីម ម៉េងឃី | ខ្មែរ |
| លោក ហុង គីមសួន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:១២:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសាលាដំបូង ប្រកាសបន្តសវនាការពិភាក្សាដេញដោល លើអង្គហេតុនៃការបង្កើតមន្ទីរសន្តិបាលស-២១ និងគុកនៅមន្ទីរពេទ្យឆ្កួតនៅតាខ្មៅ ។

ក្រឡាបញ្ជីឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន អវត្តមានភាគី ដែលត្រូវចូលរួមសវនាការនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលបានចូលរួមក្នុងដំណើរការនីតិវិធីក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន លើកលែងតែមេធាវីការពារជនជាប់ចោទអវត្តមានម្នាក់គឺ លោក ហ្វ្រង់ស្វ័រ រូ ។

[០៩:១៣:៣៧]

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីចាត់បញ្ចូលនូវរបាយការណ៍ស្តីពី ស្ថានភាពវត្តមាន អវត្តមាន ភាគីចូលរួមនៅក្នុងសវនាការនៅថ្ងៃនេះទៅក្នុងប្រតិចារឹក ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទមកកាន់ឈើរាងរង្វង់ក្រចកសេះ នៅទីនេះ ។

អង្គជំនុំជម្រះសូមជម្រាប ដល់អង្គសវនាការទាំងមូលថា នៅថ្ងៃនេះយើងបន្តការពិភាក្សាដេញដោលលើអង្គហេតុនៃការបង្កើតមន្ទីរសន្តិបាលស-២១ និងគុកនៅមន្ទីរពេទ្យឆ្កួតតាខ្មៅជាបន្តទៀត។ហើយមុននឹងអង្គជំនុំជម្រះប្រគល់វេទិកានេះ ជូនទៅសហព្រះរាជអាជ្ញាបន្តនូវសំណួរសួរ ដល់ជនជាប់ចោទ ។ អង្គជំនុំជម្រះ សូមរំឭកដល់សហព្រះរាជអាជ្ញា និងភាគីដែលចូលរួមនៅក្នុងកិច្ចពិភាក្សាដេញដោលអាចតាំងសំណួរដល់ជនជាប់ចោទនៅក្នុងសវនាការនេះគឺ កម្រិតត្រឹមតែអង្គហេតុ ដែលត្រូវធ្វើសវនាការគឺការបង្កើតមន្ទីរសន្តិបាលស-២១ និងគុកនៅមន្ទីរពេទ្យឆ្កួតតាខ្មៅតែប៉ុណ្ណោះ ។

អង្គជំនុំជម្រះនឹងកាត់នូវសំណួរទាំងឡាយណាដែលមានការពាក់ព័ន្ធជាមួយនឹងអង្គហេតុក្រោយទៀត ឧទាហរណ៍ អនុវត្តគោលនយោបាយបក្សនៅក្នុងមន្ទីរស-២១ ឬក៏ជម្លោះប្រដាប់អាវុធ ឬក៏

ប្រតិបត្តិការ ស-២១ ជាដើម ។ ហើយសូមបញ្ជាក់ថា អង្គជំនុំជម្រះបានរៀបចំកាលវិភាគនៃដំណើរការសវនាការតាមអង្គហេតុនេះ ហើយភាគីទាំងអស់មានឱកាសគ្រប់គ្រាន់នៅក្នុងការសិក្សាសំណុំរឿង ក៏ដូចជាការលើកយកបញ្ហានានា មកសួរដេញដោលដល់ជនជាប់ចោទ ដល់ភាគីដែលពាក់ព័ន្ធនៅក្នុងរឿងក្តី ដើម្បីឱ្យដំណើរការប្រព្រឹត្តិទៅប្រកបដោយភាពយុត្តិធម៌ ។ ហើយអង្គហេតុ ទាំងអង្គហេតុ ទាំងភស្តុតាង គឺត្រូវលើកយកមកបង្ហាញផ្ទុះបញ្ចាំង និងការសួរដេញដោល យ៉ាងត្រឹមត្រូវនៅក្នុងសវនាការ ប៉ុន្តែ អង្គជំនុំជម្រះរៀបចំចាត់ចែងរបៀបនេះគឺ ជៀសវាងមានភាពច្របូកច្របល់ ហើយក្នុងគោលបំណងដើម្បីរៀបចំឱ្យការប្រព្រឹត្តិទៅនៃដំណើរការសវនាការបានឆាប់រហ័សផង ។

ជាកិច្ចបន្ត សូមអញ្ជើញសហព្រះរាជអាជ្ញាឡើងបន្តនូវសំណួរ ដែលសហព្រះរាជអាជ្ញាប៉ុនប៉ងសួរដល់ជនជាប់ចោទ ។ សូមអញ្ជើញ ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

អរុណសួស្តី លោកប្រធាន លោក លោកស្រីចៅក្រម ជាទីគោរព! ខ្ញុំអរគុណ គឺខ្ញុំដឹងថា ខ្ញុំចំណាយពេលវេលារបស់តុលាការច្រើនហើយទៅលើបញ្ហាឯកសារទាំងអស់នោះ ។

**ស៖** លោក កាំង ហ្គេកអ៊ាវ កាលពីម្សិលមិញយើងបានបង្ហាញចម្លើយសារភាពមួយចំនួនដែលចម្លើយសារភាពទាំងអស់នោះ គឺលោកបានសរសេរពាក្យមួយចំនួន តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលថាលោកបានលើកឡើងថាពាក្យទាំងអស់ ដែលលោកសរសេរនៅលើចម្លើយសារភាព គឺមានការបញ្ជាក់ឬក៏បង្គាប់ពី ណាត តើត្រឹមត្រូវដែរឬទេ? នេះជាសំណួរទីមួយរបស់ខ្ញុំ ។

[០៩:១៧:៥៣]

**ជនជាប់ចោទ៖**

**ឆ៖** ត្រឹមត្រូវ ។ ខ្ញុំមិនបាច់ជម្រាបភស្តុតាងទេ ឬក៏លោកព្រះរាជអាជ្ញា ទាមទារឱ្យខ្ញុំបញ្ជាក់ភស្តុតាង?

**ស៖** សូមអរគុណ គឺយើងមានភស្តុតាងបញ្ជាក់ទៅលើករណីនេះហើយ។ ខ្ញុំគ្រាន់តែចង់ឱ្យធ្វើការបំភ្លឺទៅលើចម្លើយតបនោះតែប៉ុណ្ណោះ ។ លោកមានន័យថាចម្លើយសារភាព ដែលលោកបានចារនៅលើនោះគឺ ណាត ជាអ្នកហៅឱ្យលោកសរសេរគឺ ណាត ជាអ្នកហៅឱ្យលោកសរសេរទៅតាមអ្វីដែលគាត់ចង់ឱ្យសរសេរ ។ អ៊ីចឹង តើត្រឹមត្រូវដែរឬទេ?

**ឆ៖** មិនត្រឹមត្រូវទាំងស្រុងទេ ។ គេឲ្យគោលគំនិតមកខ្ញុំ ខ្ញុំសរសេរ មិនមែនគេ *ឱចតេ* ឲ្យទេ បារាំងហៅថា *ឱចតេ* មិនមែនគេ *ឱចតេ* ឲ្យទេ គេឲ្យគោលគំនិតមកខ្ញុំ ខ្ញុំសរសេរ ។

**ស៖** លោកបានជម្រាបយើងកាលពីម្សិលមិញអំពី នៅពេលដែលលោកត្រូវបានគេសុំឲ្យ-- លោកបានជម្រាបយើងនៅថ្ងៃច័ន្ទ គេស្នើសុំឲ្យលោកពិនិត្យមើលឯកសារពីសម័យ លន់ នល់ ដូច្នេះ ខ្ញុំសូមឲ្យលោកបញ្ជាក់បានទេថា ឯកសារដែលលោកប្រមូលបានទាំងអស់នោះ គឺវាមានឈ្មោះបុគ្គលទាំងឡាយ ដែលក្រោយមកត្រូវបានគេចាប់ខ្លួន ហើយកម្ទេចចោលនៅស-២១?

[០៩:១៩:៥៤]

**ឆ៖** លោកព្រះរាជអាជ្ញា ខ្ញុំចង់ដឹងថា តើលោកមានប្រសាសន៍អំពីបុគ្គលណា? ឯកសារណា? ឯកសារ*ស៊ីប្រា* (CIPRA) មួយសន្លឹកហ្នឹង ឬក៏ឯកសារណាផ្សេងទៀត?

**ស៖** ឯកសារទាំងអស់ ដែលគេឲ្យលោកទៅប្រមូល បន្ទាប់ពីការដួលរលំនៃរបប លន់ នល់ និងមុនពេលស-២១ ដំណើរការ ។ ថាតើឯកសារទាំងអស់នោះ គឺមានឈ្មោះមន្ត្រីរដ្ឋការ ពីរបបមុនដែរឬទេ? ហើយបុគ្គលទាំងអស់នោះ ក្រោយមកត្រូវបានគេចាប់ខ្លួន ហើយកម្ទេចចោលនៅស-២១ ។ ដូច្នេះ ខ្ញុំចង់សួរតើមានឈ្មោះទាំងអស់នោះដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបបញ្ជាក់ថា ឈ្មោះពួកនគរបាលជាតិ មានតាំងពីតិញ្ចធម្មតា រហូតទៅដល់អគ្គនាយកនគរបាលជាតិ លោក ឌី ង៉ូវ ។ ប៉ុន្តែ យើងខ្ញុំអត់មានឃើញនរណាមកក្រៅពី ឈិត អ៊ីវ ម្នាក់ទេ ដែលគេឲ្យតាំងពីខ្ញុំយកមុន ដែលគេបញ្ជូនពីជនបទមកតាំងពី ដូចអាតាំងពីមុនខ្ញុំទៅយកបាន អា *អាល់ប៊ុម* របស់នគរបាលជាតិទៀត ។ ឯចំណែក *អាល់ប៊ុម* របស់ *អេតាម៉ាហ្សូរ* មាន ប៉ុន្តែគ្មានឃើញបាននរណាម្នាក់មក ។ ខ្ញុំបាទ អត់បានផ្ទៀងផ្ទាត់ទេ ។ ខ្ញុំគ្រាន់តែដឹងថាបាន*អាល់ប៊ុម អេតាម៉ាហ្សូរ* មក ខ្ញុំដឹងថា លន់ នល់ គាត់ជា *ម៉ាហ្សូរឌឺឡាព្រើមីញ៉ែឡឺប្រូមូស្យុង ។* ក្រៅពីនោះ ឈ្មោះទៅយកពី *គុយហ្សេអាអា(QGAA)* មកច្រើនណាស់ អត់បានផ្ទៀងទេ។ ហ្នឹងជម្រាបដោយត្រង់អត់បានផ្ទៀងទេ ។ សរុបមក និយាយមួយម៉ាត់ឯកសារអស់ហ្នឹង ខ្ញុំអត់បានផ្ទៀងទេ ។

**ស៖** អ៊ីចឹង តើនេះគឺជាការយល់របស់លោកទេ ដែលថាឈ្មោះរបស់មនុស្ស ដែលមាននៅក្នុងឯកសារនោះ គឺជាអ្នកដែលត្រូវតែយកទៅសម្លាប់ចោលមែនទេ?

**ឆ៖** ខ្ញុំមិនបានគិតដល់បញ្ហានេះទេ មិនអាចបញ្ជាក់ភ្លាមបានទេ ។ ក៏ប៉ុន្តែ ខ្ញុំគ្រាន់តែជម្រាបប៉ុណ្ណោះ ការសម្រិតសម្រាំងពួកទាហានចាស់ ប៉ូលិសចាស់ អ្នករដ្ឋការចាស់ គេធ្វើចាប់តាំងពី១៧ មេសា

មករហូតៗៗតមក រហូតដល់ ស-២១ ចាប់ផ្តើមចាប់ដៃគ្នាមែនទែនប្រតិបត្តិការនៅខែតុលា ហ្នឹងគេធ្វើ ខ្ញុំក្តាប់ទិសតំបន់អីអត់បានទេ មិនចង់ផ្ទៀងផ្ទាត់អីផង ។ ដូច្នេះ សរុបមកវិញ ទិសរបស់គេៗមានហើយ ក្នុងការចាប់អ្នករដ្ឋការចាស់ ។ នេះពិត ។ ក៏ប៉ុន្តែ បញ្ជីដែលប្រមូលបានមកហ្នឹង ក៏មិនបានយកទៅផ្ទៀង នឹងអាឈ្មោះ ដែលគេចាប់បានមកដែរ ។ នេះជាការពិតមួយទៀត ។

**ស៖** អ៊ីចឹង តើលោកអាចជួយប្រាប់យើងបានទេ តើអ្វីទៅជាគោលបំណងក្នុងការប្រមូលឯកសារអស់ទាំងនោះ ដែលជាឯកសារមកពីទីតាំងរបស់រដ្ឋាភិបាល ឬក៏របបមុននោះ?

**ឆ៖** សូមបញ្ជាក់ជូនលោកសហព្រះរាជអាជ្ញា វត្ថុបំណងចំពោះមុខ ខ្ញុំគ្មានបានទទួលការណែនាំទេ ។ បានន័យថា ប្រមូលមកដើម្បីតាមដានរកចាប់ពួកទាហានចាស់ ពួកប៉ូលិសចាស់ ខ្ញុំគ្មានបានការណែនាំទេ។ នេះនិយាយពីមេខ្ញុំពីលើមកធំលោកគ្រូ សុន សេន ហ្នឹង អត់បានទទួលការណែនាំផ្ទាល់ទេ ។ ក៏ប៉ុន្តែ ជាយុត្តិសាស្ត្រទៅថ្ងៃក្រោយ មិនដឹងយ៉ាងម៉េចទេ ។ នេះសូមជម្រាបប៉ុណ្ណេះ ។

[០៩:២៤:១១]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

លោកបានប្រាប់ពួកយើងថា អំពីមនុស្សជំទង់ ហើយនិងអ្នកនៅវ័យក្មេង ដែលត្រូវបានប្រើឲ្យធ្វើការនៅមន្ទីរស-២១ ។ បាទ,បើមានការអនុញ្ញាតពីលោកប្រធាន ខ្ញុំសូមឲ្យធ្វើ និយាយអំពីចម្លើយរបស់ជនជាប់ចោទ ដែលគាត់បានផ្តល់ជូនឲ្យសហព្រះរាជអាជ្ញា ឲ្យខាងសហចៅក្រមស៊ើបអង្កេត ហើយសូមឲ្យអាន ដើម្បីបញ្ជាក់ថា តើនោះគឺជាអ្វីដែលគាត់បាននិយាយមែនទេ?

តើខ្ញុំអាចសុំធ្វើការអនុញ្ញាតបង្ហាញឯកសារនេះបានទេ?

**ប្រធានអង្គជំនុំ**

អង្គជំនុំជម្រះអនុញ្ញាត សូមបង្ហាញឯកសារហ្នឹងមកក្រឡាបញ្ជី ហើយប្រាប់ចំណុចផង ថាតើត្រូវអាននៅចំណុចណា ឬក៏បន្ទាត់ណាច្បាស់លាស់ ។

[០៩:២៥:០៧]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ។ ឯកសារនោះ គឺជាចម្លើយរបស់ជនជាប់ចោទ ដែលធ្វើនៅថ្ងៃ០១ ខែមេសា ឆ្នាំ២០០៨ ដែលមានលេខ D77-67 ហើយនិងមានលេខ 0017717122 ជាភាសាខ្មែរ ។

សូមឲ្យខាងផ្នែកសោតទស្សន៍ហ្នឹង បញ្ចាំងអេក្រង់របស់លោក ហ្វង ម្តងដែលអាចបង្ហាញឲ្យ

ឃើញទាំងអស់គ្នា ។

តើលោកប្រធានចង់ឲ្យខ្ញុំឲ្យលោកក្រឡាបញ្ជីធ្វើការអានឯកសារនេះ ឬក៏ខ្ញុំឲ្យសហសេវិកលោក តាន់ សេណារ៉ុង របស់ខ្ញុំហ្នឹងគាត់ធ្វើការអានឯកសារនេះដោយផ្ទាល់?

**ប្រធានអង្គជំនុំ៖**

អនុវត្តរួចហើយ គឺក្រឡាបញ្ជីជាអ្នកទទួលខុសត្រូវក្នុងការអាននេះ ។ ហើយអាននៅចំណុចដែលគូសរង្វង់ក្រហមនេះមែនទេ? ក្រឡាបញ្ជីអាននូវចំណុចដែលមានអក្សរ ដែលមានរង្វង់បន្ទាត់ក្រហមគូសជុំវិញ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សំណួររបស់លោកសហចៅក្រមស៊ើបអង្កេត៖ តើមានមាគ៌ានយោបាយច្បាស់លាស់ទាក់ទិននឹងការជ្រើសរើសកុមារដែរឬទេ? តើពួកគេមានត្រូវបានប្រើប្រាស់ ដើម្បីលាតត្រដាងជនក្បត់នៅក្នុងក្រុមគ្រួសាររបស់ពួកគេដែរឬទេ? ឆ្លើយ៖ មាគ៌ាតែមួយគត់ គឺគេទុកចិត្តកសិករក្រីក្រ និងកសិករកណ្តាលថ្នាក់ក្រោម ។ ចំពោះកុមារដែលខ្ញុំបានជ្រើសរើស ដើម្បីធ្វើការនៅស-២១ ពួកគេមកពីប្រភពស្អាតបរិសុទ្ធ ពួកគេជាកូនចៅរបស់កសិករក្រីក្រ ដែលខ្ញុំអាចទុកចិត្តបាន ហើយបើតាមខ្ញុំដឹងមិនដែលមានការលាតត្រដាងពីជនក្បត់នៅក្នុងគ្រួសាររបស់ពួកគេនោះទេ ។ ខ្ញុំនិយាយចំពោះតែករណីរបស់ខ្ញុំតែប៉ុណ្ណោះ រឿងអ្នកផ្សេងទៀត ខ្ញុំមិនដឹងទេ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអភ័យទោសលោកប្រធាន នេះមិនមែនជាឃ្លាដែលខ្ញុំចង់ឲ្យអាននោះទេ ។

សូមឲ្យសហសេវិករបស់ខ្ញុំ គាត់បង្ហាញអំពីចំណុចដែលត្រូវអាននោះ ។

[០៩:២៨:២០]

ខ្ញុំសូមអភ័យទោសលោកប្រធាន ។ តើខ្ញុំអាចឲ្យស្មើផ្នែកសោតទស្សន៍ហ្នឹង គឺថា បិទអេក្រង់របស់លោក ស្នួត សិនបានទេ?

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍បិទអេក្រង់វិញ វិលទៅរកស្ថានភាពដើមវិញ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ។ សូមអភ័យទោសដែលធ្វើឲ្យយឺតពេលនោះ ។ អ៊ីចឹង ខ្ញុំនឹងបង្ហាញ

នូវសំណួរនៅពេលក្រោយ ។ ដោយសារលោក ហ្វង ហើយនិងខ្ញុំហ្នឹងគឺថា មិននិយាយភាសាខ្មែរ អ៊ីចឹង ហើយបានជាមិនអាចពិនិត្យមើលឯកសារ ដែលបានដាក់នៅអេក្រង់កាលពីមុននោះ ។ អ៊ីចឹង ខ្ញុំសូមឲ្យលោកប្រធានប្រាប់ខាងផ្នែកសោតទស្សន៍ហ្នឹង គឺប្តូរមកអេក្រង់កុំព្យូទ័ររបស់លោក ស្មួត ម្តង ហើយដើម្បីឲ្យខាងក្រឡាបញ្ជីគាត់ធ្វើការអានអត្ថបទនោះ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍ ប្តូរអេក្រង់ភ្ជាប់មកផ្នែកខាងសហព្រះរាជអាជ្ញាតាមការស្នើសុំ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ហើយប្រអប់ដែលមានព័ណក្រហមហ្នឹង គឺជាផ្នែកដែលត្រូវអាន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោកស្រី សែ កុលវុឌ្ឍី អាននៅចំណុចដែលអក្សរដែលមានបន្ទាត់ក្រហមគូសព័ទ្ធជុំវិញនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សំណួររបស់សហព្រះរាជអាជ្ញា៖ ជនត្រូវចោទបាននិយាយកាលពីម្សិលមិញ អំពីការប្រើប្រាស់កុមារឲ្យធ្វើការងារ ។ វាហាក់ដូចជាថា នៅទូទាំងប្រទេសកុមារក្មេងៗត្រូវបានគេប្រើឲ្យធ្វើជាអាចកងការពារ ហើយគេអាចគិតថា ក្មេងទាំងនេះត្រូវបានជ្រើសរើស ដោយពួកគេងាយស្រួលទទួលរងឥទ្ធិពល និងបញ្ចូលមនោគមន៍វិជ្ជា ។ តើជនត្រូវចោទមានអ្វីនិយាយទេទាក់ទិននឹងបញ្ហានេះ? តើនៅស-២១ មានស្ថានភាពពិតប្រាកដយ៉ាងដូចម្តេចដែរ? ឆ្លើយ៖ វាជាការពិតហើយដែលថាកុមារក្មេងៗត្រូវបានប្រើឲ្យធ្វើការនៅស-២១ ក៏ដូចជានៅកន្លែងផ្សេងទៀតដែរ ។ ពួកគេត្រូវបានប្រគល់ឲ្យធ្វើការងារប្រើកម្លាំង ហើយពេលខ្លះការងារកងការពារ ឬការងារបែកចែកម្ហូបអាហារ ។ ទាក់ទងនឹងលទ្ធភាពបញ្ចូលមនោគមន៍វិជ្ជាដោយងាយស្រួល ខ្ញុំសូមនិយាយថា ដោយសារតែពួកគេនៅក្មេង ពួកគេដូចជាក្រដាសសមួយដែលគេអាចសរសេរ ឬគូសអ្វីដែលគេចង់សរសេរ ឬគូស ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ។ សូមលោកប្រធានអនុញ្ញាតឲ្យខាងផ្នែកសោតទស្សន៍ហ្នឹង ដាក់អេក្រង់ត្រឡប់មកក្នុងសាលសវនាការវិញ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍រៀបចំកាត់មក-- បង្វែងផ្នែកខាងសោតទស្សន៍មករូបភាពប្រក្រតីឡើងវិញ ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

**ស៖** សំណួររបស់ខ្ញុំសម្រាប់ជនជាប់ចោទ បន្ទាប់ពីបានអាន បានឮនូវសំណួរចម្លើយ ដែលទើបតែបានអានអម្បាញ់មិញនេះរួចហើយ ។ តើលោកអាចបញ្ជាក់បានទេ តាមពិតកុមារក្មេងៗភាគច្រើនហ្នឹង ត្រូវបានគេប្រើជាកងការពារនៅមន្ទីរស-២១ នោះ? នេះជាសំណួរទីមួយរបស់ខ្ញុំ ។

**ឆ៖** លោកព្រះរាជអាជ្ញាជាទីគោរព! បញ្ហានេះមានចោទ ហើយនិងខ្ញុំបានបញ្ជាក់ឡើងជាបន្តបន្ទាប់។ បញ្ហាសំខាន់បំផុតដែលខ្ញុំនៅចងចាំមិនភ្លេច គឺចម្លើយដែលខ្ញុំបានជម្រាបលោកជំទាវ ខាតវ៉ាយថ៍ថា កុមារទាំងអស់នេះ ខ្ញុំផ្ទាល់ខ្លួនជាអ្នកអប់រំ ។ ឯចំណែក ជាក់ស្តែងអ្នកណាទៅឯណាខ្ញុំអត់ច្បាស់ទេ ក៏ប៉ុន្តែ និយាយអ៊ីចឹង វាអាក្រក់មើល អាក្រក់ៗស្តាប់ពេក ។ កុមារដែលចូលមក ស-២១ ពីកំពង់ឆ្នាំង មានមួយចំនួននៅតូចៗឲ្យស្មៅទន្សាយ មួយចំនួនធំពិតជាយកទៅប្រើឯទុំងហើយ មួយចំនួនធំដែលប្រើការជាកងការពារកើត គេប្រើកងការពារហើយ ។

ដូច្នេះ សរុបមកចម្លើយនៅដដែលទេ ។ ខ្ញុំជាអ្នកអប់រំពង្វក់គេទៅតាមទិសមនោគមន៍វិជ្ជាមួយច្បាស់លាស់ ។ កុមារធំ ប្រើជាកងការពារទៅ កុមារតូច រកស្មៅឲ្យទន្សាយ ។ សុំបញ្ចប់ប៉ុណ្ណេះ ។

[០៩:៣៥:០០]

**ស៖** សូមអរគុណចំពោះការបញ្ជាក់ច្បាស់នេះ ។ លោកប្រធាន! ខ្ញុំសូមនៅពេលដែលខ្ញុំសួរសំណួរហ្នឹង ប្រហែលជាមិនបានច្បាស់ទេនៅក្នុងការបកប្រែជាភាសាអង់គ្លេសហ្នឹង ដែលជនជាប់ចោទបាននិយាយថា កុមារក្មេងៗត្រូវបានប្រើជាអ្នកយាមនោះ ។

ខ្ញុំចង់សួរមួយទៀតលោក កាំង ហ្គេកអ៊ាវ ទាក់ទងទៅនឹងបទសម្ភាសដែលលោកបានធ្វើជាមួយនឹងសហចៅក្រមស៊ើបអង្កេត ។ ថាតើកុមារហ្នឹងដូចជាក្រដាសស្អាតល្អដែលនរណាម្នាក់ អាចសរសេរឬក៏គូរអ្វីបាននៅលើក្រដាសនោះ?

**ឆ៖** នេះជាគោលគំនិតពិតរបស់អ្នកនយោបាយគ្រប់ភាគី គ្រប់និន្នាការនយោបាយខ្ញុំពង្វក់កុមារខ្ញុំ តិចឬច្រើនទទួលឥទ្ធិពលពីអ្នកនយោបាយបក្សកុម្មុយនីស្ត ។ ដូច្នេះ ចាត់ទុកកុមារដូចក្រដាសស្អាតអ៊ីចឹង យើងចង់គូរ យើងចង់គូររូបដែលមាននិន្នាការបដិវត្តន៍ និន្នាការកុម្មុយនីស្តយ៉ាងម៉េច យើងគូរបានតាមចិត្តយើងចង់ស្អាត ។ ហើយបើប៉ះកុមារអ្នកក្រទៀត ខ្ញុំបានលើកពាក្យស្លោកមួយហើយគេថា “កូនអ្នកក្រនាប់ដឹងក្តី ដាក់ពូជអីដុះពូជនុំង” ។ ហ្នឹង ដែលខ្ញុំជ្រើសរើសមកហ្នឹង សុទ្ធតែកុមារជាកូនអ្នកក្រ យកគេមកពង្វក់ យកគេមកបង្វឹកមនោគមន៍វិជ្ជាមួយដែលខ្ញុំពេញចិត្ត អើយើងនិយាយថា ពេញចិត្ត

អ៊ីចេះសិនទៅចុះ ។

[០៩:៣៧:៣០]

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សូមអរគុណ ។ សំណួរចុងក្រោយ-- បញ្ហាចុងក្រោយរបស់ខ្ញុំនោះលោកប្រធាន គឺទាក់ទងទៅនឹងចម្លើយមួយទៀត ដែលជនជាប់ចោទបានផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ដែលមានលេខ D13 ហើយជាភាសាខ្មែរ គឺមានលេខ 001465525 ដល់ 26 ហើយក្នុងភាសាអង់គ្លេសគឺមានលេខ 00147569 ។ ខ្ញុំសូមឲ្យលោកប្រធានបង្គាប់ទៅខាងផ្នែកសោតទស្សន៍ឲ្យបញ្ចាំងទៅលើអេក្រង់របស់សហសេវិករបស់ខ្ញុំ របស់លោក ស្នួត ហើយសូមឲ្យក្រឡាបញ្ជីអាននូវអត្ថបទនោះ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ បង្វែរភ្ជាប់នៃរូបភាពលើអេក្រង់មកផ្នែកខាងសហព្រះរាជអាជ្ញា តាមសំណូមពរ ។

លោកស្រី សែ កុលវុឌ្ឍី អាននូវអក្សរ ដែលមាននៅក្នុងបន្ទាត់ក្របាមគូសជុំវិញនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សំណួរ៖ *អឹម.អិល(M.L)* យើងនឹងឃើញដោយគិតអំពី បរិបទនៃដំណើរការរបស់បក្សនាពេលនោះ តើលោកគិតថាបក្សអាចរក្សាទុកមនុស្សដែលអត់មានធ្វើអីដែរឬទេ? ឆ្លើយ៖ ខ្ញុំសូមរំឭកថា កាលពីលើកមុនលោកចៅក្រមបានសួរខ្ញុំថា ហេតុអ្វីបានជាគេតែងតាំងខ្ញុំឲ្យធ្វើជាប្រធាន? ខ្ញុំបានឆ្លើយនាពេលនោះថា ខ្ញុំមិនដឹងអីអំពីការតែងតាំងនោះទេ ។ នេះជាចម្លើយដែលឈរលើហេតុការណ៍ជាក់ស្តែង នៅមានចម្លើយមួយទៀត ដែលខ្ញុំមិនទាន់ប៉ានជម្រាបជូននាពេលនោះ គឺហេតុផលដែលឈរលើការវិភាគរបស់ខ្ញុំ ។ ការវិភាគនេះវាវែង តែបើលោកចៅក្រមអនុញ្ញាតខ្ញុំសូមជម្រាប ។ ឆ្លើយ៖ ទីមួយខ្ញុំសូមនិយាយអំពីមតិរបស់ វន វ៉េត ក្រោយដែលគេចាប់គាត់ ។ គាត់ថា បងប៉ុល នេះជាមនុស្សដែលយកជើងទ្រមេឃ នេះជាពាក្យបុរាណកម្ពុជា ។ ដោយឃើញខ្ញុំ វន វ៉េត កាន់ក្រសួងឧស្សាហកម្មដែលមានមនុស្សរាប់ម៉ឺននាក់ បងប៉ុល ចាប់ផ្តើមសង្ស័យខ្ញុំ ។ ខ្ញុំ [ឌុច] គិតថា ពីរ-បីថ្ងៃមុននឹងយកមតិនេះទៅប្រាប់ នួន ជា ដើម្បីចង់ដឹងប្រតិកម្មរបស់គាត់ ។ នួន ជា ឆ្លើយផ្ទួងថា វន វ៉េត វាធ្វើអីកើតព្រោះក្នុងអង្គភាពមួយៗ មានគេមានឯង ។ មតិនេះខ្ញុំជឿថា ពិតទាំងពីរ ។

ដូច្នេះ គេយកខ្ញុំមកដាក់ពីលើ៧០៣ នៅស-២១ នេះ ដើម្បីឲ្យខ្ញុំជាភ្នែកជាច្រមុះគេ ។ បើកាលណា៧០៣ ចាប់អារុធផ្ទុះកណ្ដាលទីក្រុងវិញ តើគេអាម៉ាស់ប៉ុនណា? តាមពិតនៅក្នុង ស-២១ មានតែ ៧០៣ ទេ ដែលមានលទ្ធភាពចាប់អារុធ ។ ឯចំណែក ម-១៣ ចាស់មានយុទ្ធជនមិនដល់ដប់នាក់ផង និងមិនធ្លាប់ប្រយុទ្ធ ។ ដូច្នេះ មិនមានលទ្ធភាពផ្ទុះអារុធទេ ។ នេះជាការវិភាគរបស់ខ្ញុំ ត្រូវប៉ុន្មានភាគរយ សូមតុលាការវិនិច្ឆ័យចុះ ។

[០៩:៤១:០៤]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

អរគុណលោកស្រីក្រឡាបញ្ជី ។ លោកប្រធាន តើលោកអាចបង្គាប់ឲ្យមានការផ្លាស់ប្ដូរចរន្តរូបភាពសោតទស្សន៍នេះទៅវិញ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍បង្វែររូបភាពទៅភាពប្រក្រតីឡើងវិញ ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

**ស៖** ហើយសំណួររបស់ខ្ញុំចំពោះជនជាប់ចោទពាក់ព័ន្ធទៅនឹងចម្លើយរបស់គាត់ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ។ គឺគាត់លើកឡើងអំពីជាច្រមុះ និងជាមុខរបស់បក្សនៅស-២១ ជាភ្នែក និងជាច្រមុះរបស់បក្ស ។

ដូច្នេះ គឺលោកបញ្ជាក់ថា លោកទទួលសេចក្ដីបង្គាប់សរុបពីថ្នាក់លើរបស់លោក ដើម្បីរាយ-ការណ៍ចំពោះសកម្មភាពផ្សេងៗរបស់កងពល៧០៣ ដែរឬទេ ដែលវាមានលក្ខណៈ*តាក់ទិច* និងវាលក្ខណៈ*តាក់តិច* ទៅលើបញ្ហាទាំងអស់នុង?

**ឆ៖** ជម្រាបលោកព្រះរាជអាជ្ញា! ការវិភាគរបស់ខ្ញុំនៅពេលដែលខ្ញុំឆ្លើយនឹងសំណួររបស់លោកចៅក្រម ម៉ាកសែល ឡឺម៉ុងដ៍ ជាខ្លឹមសារនៅដដែល ។ ថ្មីៗនេះ ក៏ខ្ញុំបានជម្រាបអង្គសវនាការយើងថា គេចាត់ទុកខ្ញុំជា*ប៉ែកហ្សេ* របស់គេ ។ ក៏នៅដដែល ដូចដែលខ្ញុំបានរាយការណ៍ជម្រាបលោកចៅក្រម ម៉ាសែល ឡឺម៉ុងដ៍ ហើយ ហើយក៏ដូចជាខ្ញុំបានរាយការណ៍ការជម្រាបលោកចៅក្រម ឡាវ៉ែន៍ ដែរ ។

[០៩:៤២:៥៧]

សរុបមកវិញ តើការអនុវត្តជាក់ស្ដែងយ៉ាងម៉េច? ការអនុវត្តជាក់ស្ដែងនៅពេលដែលខ្ញុំធ្វើអនុ-ប្រធានរបស់ ណាត ពីខែតុលា ដែលខ្ញុំចូលទៅចាប់ដៃពេញលេញជាមួយ ណាត ក្នុងការងារស-២១ មេ

មិនដែលហៅ ណាត ទៅតែម្នាក់ឯងទេ ហៅខ្ញុំទៅផង ។ នេះជាព្រឹត្តិការណ៍មួយ ។ ព្រឹត្តិការណ៍មួយទៀត ខ្ញុំគិតថាដល់ពេលណាមួយគង់នឹងបានខ្ញុំបានរាយការណ៍ជូនអង្គសវនាការអំពី ណាត ចាប់មនុស្សដោយអត្តនោម័តិ ដែលខ្ញុំប្រុងរាយការណ៍ជូនមេ ។ រឿងនេះវែង ។

ដូច្នេះក្រោយមក ក្រោយពី ណាត ទៅខ្ញុំធ្វើប្រធាន មិត្ត ហ៊ី ជាអនុប្រធាន ។ មិត្ត ហ៊ី គ្មានសិទ្ធិទៅប្រជុំជាមួយនឹងមេជាមួយបក្ស ទៅប្រជុំជាមួយមេ ជាមួយខ្ញុំទេ ។ តែកាលណាហៅទៅប្រជុំមានតែខ្ញុំពីរនាក់មេគត់សុទ្ធសាធ ខ្ញុំ និងមេ ។ ក៏ប៉ុន្តែខ្ញុំនៅជាអនុប្រធាន មេហៅ ណាត ទៅ គឺហៅខ្ញុំទៅដែរ នេះវាសបញ្ជាក់ឲ្យឃើញអ៊ីចឹង ក៏ប៉ុន្តែបញ្ជាឲ្យគាត់ថា "អ្នែងទៅយកការណ៍ពី៧០៣ មកឲ្យអញ" គ្មានទេ គោលការណ៍បក្សគេមិនធ្វើអ៊ីចឹងទេ គោលការណ៍បក្សគេមិនធ្វើអ៊ីចឹងទេ ប៉ុន្តែសេចក្តីទុកចិត្តរបស់គេវាសម្តែងឲ្យឃើញអ៊ីចឹង តាមការប្រតិបត្តិបែបនេះ ។ ហើយដូចខ្ញុំនិយាយជាមួយម្សិលមិញ ជាមួយនឹងលោកចៅក្រម ធូ មណី អំពីខ្ញុំក្រឡេកមើលទៅក្រោយវិញ តើរបៀបសម្លាប់ហ្នឹង របៀបសម្លាប់ជនរងគ្រោះហ្នឹង វាខុសគ្នា ហើយមេគេឲ្យខ្ញុំទៅតាមដាន ។

[០៩:៤៤:៥០]

ខ្ញុំបានសរុបជូនលោកចៅក្រម ធូ មណី គឺសរុបជូនអង្គសវនាការយើងទាំងមូល តាមរយៈលោកចៅក្រម ធូ មណី ថាគេមិនមែនមិនទុកចិត្តត្រឹមតែ ណាត ទេ គេមិនទុកចិត្ត៧០៣ ទៅទៀត ។ នេះតាមសកម្មភាពដែលយើងក្រឡេកមើលទៅក្រោយវិញ ។

សរុបមកវិញ ខ្ញុំសូមឆ្លើយជាមួយលោកព្រះរាជអាជ្ញាមួយម៉ាត់ គេមិនបញ្ជាទេថា "អ្នែងទៅយកការណ៍ពី៧០៣ មកឲ្យអញ" អត់ គោលការណ៍ចាត់តាំងរបស់បក្សផ្សេង ។ អ្នកឯងជាអនុប្រធាន អ្នកឯងមកធ្វើការមួយប្រធាន អាហ្នឹងជាមួយគ្នា ក៏ប៉ុនដល់ក្រោយមកអ្នកឯងជាប្រធាន អ្នកឯងមកធ្វើការម្នាក់ឯង អញប្រើឯងតែម្នាក់ឯង ។ នេះជារឿងពិត ។

ខ្ញុំសូមជម្រាបលោកចៅក្រមប៉ុណ្ណេះ-- លោកព្រះរាជអាជ្ញាប៉ុណ្ណេះ ។

**ស៖** ដូច្នេះលោកបញ្ជាក់ដែរឬទេ ថាលោកជាភ្នែក និងជាច្រមុះរបស់បក្ស ដូចដែលលោកបានលើកឡើងកាលពីមុន?

[០៩:៤៥:៥៣]

**ឆ៖** អរគុណលោកព្រះរាជអាជ្ញាដែលសួរបញ្ហានេះ ។ ពាក្យជាភ្នែក និងជាច្រមុះវាម្យ៉ាងទេ ពាក្យដែលថា *ប៉ែកហ្សេ* ហ្នឹងវាកាន់តែច្បាស់លាស់ណាស់ទៅទៀតហើយ ។ ដែលខ្ញុំ ពាក្យខ្ញុំរាយ-

ការណ៍ជូនលោកចៅក្រម ឡាវែន៍ ថ្មីៗនេះ ។ មិនមែនត្រឹមតែជាភ្នែក ច្រមុះទេ លោកព្រះរាជអាជ្ញាៗ ជា *ប៉ែកហ្សេ* គេណ៌ា ។

**លោក អាឡិចសាន់ឌឺ បែត៖**

អរគុណ ។ សហព្រះរាជអាជ្ញាមិនមានសំណួរចំពោះជនជាប់ចោទនៅដំណាក់នេះទេ ទោះបីជនជាប់ចោទបានលើកសេចក្តីសង្កេតមួយក៏ដោយ ហើយជនជាប់ចោទគាត់បានលើកអំពីអង្គហេតុជាច្រើនដែលវាមិនពាក់ព័ន្ធតែប៉ុណ្ណោះទៅនឹង ស-២១ ប៉ុណ្ណោះទេ ។

ដូច្នេះ យើងនឹងបង្វិលសំណួរទាំងអស់នោះដែលពាក់ព័ន្ធនឹងទៅអង្គហេតុផ្សេង នៅពេលក្រោយហើយចំណុចក្រោយ ដែលខ្ញុំចង់លើកឡើង គឺស្នើសុំការអនុញ្ញាតពីលោកប្រធាន គឺសូមឱ្យបញ្ចាំងលើសោតទស្សន៍អំពីសេចក្តីបង្ហាញរបស់ *ចន ឡេសសេក* ដែលយើងបានដាក់នៅក្នុងទម្រង់ឯកសារកាលពីថ្ងៃមុន មិនមែនជាបំណងរបស់សហព្រះរាជអាជ្ញា សុំឱ្យតុលាការបង្ហាញ បទបង្ហាញទាំងអស់នោះទេ ។ យើងគ្រាន់តែបង្ហាញ ថាតើវាមានសារសំខាន់យ៉ាងម៉េចចំពោះបទបង្ហាញមួយនេះ ចំពោះជនជាប់ចោទ និងសាក្សី? ហើយវាមិនចំណាយពេលច្រើនជាងមួយនាទី ក្នុងការបង្ហាញទៅលើបទបង្ហាញនោះទេ ។ ហើយលោកប្រធានសុំអនុញ្ញាតឱ្យធ្វើការបង្វែរទៅលើរូបភាពសោតទស្សន៍ មកកាន់អេក្រង់របស់យើងវិញ ដើម្បីយើងរៀបចំទៅលើករណីនេះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមសំណូមពរ ហើយបង្គាប់ឱ្យផ្នែកខាងសោតទស្សន៍បង្វែរភ្ជាប់មកផ្នែកខាងសហព្រះរាជអាជ្ញា ដើម្បីធ្វើកិច្ចការនេះតាមការសុំនេះ ។

**លោក អាឡិចសាន់ឌឺ បែត៖**

អរគុណលោកប្រធាន ។នេះមិនមែនជាបទបង្ហាញរបស់សហព្រះរាជអាជ្ញានោះទេ គឺជារបាយ-ការណ៍កោសល្យវិច័យរបស់ខាងសហចៅក្រមស៊ើបអង្កេត ។ ហើយបង្កើតដោយអ្នកជំនាញឯករាជ្យដែលនៅ*អាយស៊ីធីវ៉ាយ(ICTY)* ។ ហើយបទបង្ហាញទីមួយ គឺរូបភាពចាប់ពីលើ ហើយយើងឃើញមានរង្វង់ពីរ ។ ទីមួយនៅខាងស្តាំ ខាងក្រោម ហើយមួយទៀតគឺនៅខាងឆ្វេង ដែលបង្ហាញអំពីស-២១ នៅភ្នំពេញ ហើយយើងឃើញមានសញ្ញាព្រួញនៅទីនេះ អង្គសវនាការឃើញហើយ នៅពេលដែលសញ្ញាបង្ហាញចង្អុលទៅលើរង្វង់ទាំងពីរនេះ ។

ដូច្នេះ ខ្ញុំសូមឱ្យលោក ហ្វង់ គាត់ធ្វើការចង្អុលបង្ហាញទៅលើ ស-២១ នៅភ្នំពេញ ហើយយើង

ចាប់យករូបភាពឲ្យជិតទៅលើទីតាំងនៅ ស-២១ ។

អង្គសវនាការយើងឃើញមានសញ្ញាក្រហមផ្សេងៗនៅក្នុងរូបភាពនេះ៖

លេខក្រហមនេះៗ គឺតំណាងទៅលើរូបភាព ចំពោះទីកន្លែងជាក់លាក់ណាមួយ គឺទីកន្លែងដែលលើកឡើងបញ្ជាក់ដោយជនជាប់ចោទ និងសាក្សី ហើយត្រូវបានសួរចម្លើយដោយចៅក្រម ។

នៅក្នុងរូបពណ៌ផ្កាឈូក យើងឃើញមានការតំណាងឲ្យស-២១ ហើយយើងឃើញមាននៅក្នុងរង្វង់ពណ៌ផ្កាឈូកនេះ ។ ហើយខ្ញុំសូមឲ្យលោក *ហ្វូង* ធ្វើការចុចទៅលើរូបភាពដែលតំណាងស-២១ ហើយយើងអាចពិនិត្យមើលទៅលើរូបភាពនេះបាន ។

ជាថ្មីម្តងទៀត គឺជារូបភាពចាប់ពីលើ អំពីអគារទាំងប្រាំជាចម្បងនៅ ស-២១ គឺអគារ “ក” “ខ” “គ” “ឃ” និង “ង” ។

អង្គសវនាការយើងឃើញមានរង្វង់ពណ៌ខៀវនៅទីកន្លែងផ្សេងៗ នៅលើរូបភាពនេះ ។ ហើយប្រសិនបើយើងចុចនៅលើរង្វង់ខៀវណាមួយនោះ ហើយលោក *ហ្វូង* កំពុងតែចុចហើយ គឺជិតនឹងអគារ “ក” អង្គសវនាការនឹងឃើញទីតាំងអគារឃុំឃាំងនៅ ស-២១ ។

ហើយប្រសិនបើអង្គសវនាការចង់បង្ហាញឲ្យបានពិស្តារទៅដល់ជនជាប់ចោទ និងសាក្សីនោះ គឺបុគ្គលដែលគាត់ធ្វើការចាត់ចែងទៅលើកុំព្យូទ័រ គាត់អាចបង្វិលកូនកណ្តុរ ឬក៏ *ម៉ៅ* ទៅលើទីតាំងណាមួយ ។ ហើយគាត់ដាក់នៅចំកណ្តាលវានឹងក្លាយទៅជារូបសញ្ញាព្រួញ នៅពេលដែលមានសញ្ញាព្រួញនោះ គឺវាបង្ហាញថា មានរូបភាពនៅទីនេះ ដែលសញ្ញាព្រួញអាចចុចបង្ហាញ ។ ហើយខ្ញុំឲ្យលោក ហ្វូង ចុចបញ្ជាក់បង្ហាញនៅទីនេះ ។ ហើយនេះគឺជាទីតាំងនៅអគារ “ក” ដែលជាបន្ទប់មួយ ហើយយើងអាចចុចនៅលើរូបភាពនេះទៀត ហើយវានឹងបង្ហាញរូបភាពពិស្តារ ។ ហើយយើងក៏អាចចុចបន្ថែមទៀតដូចជានៅលើបង្អួច ហើយអង្គសវនាការនឹងឃើញរូបភាពមួយដែលត្រូវបានថតយកនៅពេលសម្តែងឡើងវិញ ។ ដើម្បីត្រឡប់មករូបភាពដើមវិញ គឺសញ្ញាព្រួញចុចទៅលើអេក្រង់នេះ វានឹងត្រឡប់មករូបភាពដើមវិញ ។

[០៩:៥២:១៧]

ដូចដែលខ្ញុំចង់ជម្រាប គឺយើងមិនមានបំណងបង្ហាញពិស្តារ ព័ត៌មានពិស្តារនៅទីនេះទេ ។ យើងគ្រាន់តែបញ្ជាក់ថា រូបភាពនេះគឺវានៅក្នុងសំណុំរឿង ហើយវាជារូបភាពដែលបង្កើតដោយសហចៅក្រមស៊ើបអង្កេត ហើយវាអាចជាផលប្រយោជន៍ និងជំនួយទៅដល់ភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ ។

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរតាំងចំពោះជនជាប់ចោទទៀតហើយ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍បង្វិលមករូបភាពប្រក្រតីឡើងវិញ ។ ជាកិច្ចបន្តនេះអង្គជំនុំជម្រះសូមប្រគល់វេទិកានេះជូនទៅមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលមានឱកាសក្នុងការតាំងសំណួរសួរដល់ជនជាប់ចោទ ពាក់ព័ន្ធទៅនឹងអង្គហេតុដែលយើងកំពុងតែដាក់ពិភាក្សាដេញដោលនេះ ។ ដោយចាប់ផ្តើមតាមលំដាប់ពីមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយមុន និងតាមជាបន្តបន្ទាប់ ។

សូមអញ្ជើញមេធាវីតំណាងឲ្យក្រុមមួយ ។

**សួរដោយ កញ្ញា ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។ នាងខ្ញុំឈ្មោះ ទី ស្រ៊ីនណា ជាមេធាវីជាតិនៅក្នុងក្រុមមួយ ។ ខ្ញុំមានសំណួរពីរ បីសំណួរ ដើម្បីសួរទៅជនជាប់ចោទ ។ នៅក្នុងនោះសំណួរទីមួយរបស់នាងខ្ញុំ គឺពាក់ព័ន្ធទៅនឹងបញ្ហាឧបករណ៍ នៅក្នុងការធ្វើទារុណកម្ម ។

**ស៖** នៅក្នុងសំណួរទីមួយខ្ញុំសូមសួរទៅខាងជនជាប់ចោទ នៅក្នុងពេលដែលគាត់បង្កើតនូវមន្ទីរ ស-២១ ជាលើកដំបូង តើមានការកំណត់ពីបញ្ហាឧបករណ៍ធ្វើទារុណកម្ម ដូចជាខ្នោះ ឬក៏ច្រវាក់ អីផ្សេង និងដូចជាករណីរំពាត់ ឬក៏ករណីអីផ្សេងៗ ដែលសម្ភារៈផ្សេងៗ ដែលអាចធ្វើទារុណកម្មទៅលើជនរងគ្រោះនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ តើពេលដែលបង្កើតដំបូងមានការកំណត់យ៉ាងដូចម្តេចដែរ? ឬក៏មានការប្រជុំ ដើម្បីកំណត់ថាតើត្រូវមានឧបករណ៍បែបណាសម្រាប់ប្រើប្រាស់ នៅក្នុងមន្ទីរស-២១?

សូមឲ្យលោក ឌុច មេត្តាជួយបង្ហាញពីបញ្ហាចំណុចនេះ ។

[០៩:៥៥:១៣]

**ជនជាប់ចោទ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំសូមឆ្លើយជាមួយនឹងកញ្ញា ស្រ៊ីនណា ដូចតទៅ៖

ស-២១នេះ ខ្ញុំនិយាយវាហាក់ដូចដដែលៗ វាដំណើរបន្តអំពីនគរបាលកងពល៧០៣មក ។ របៀបធ្វើទារុណកម្ម របៀបឃុំឃាំង របៀបយកចម្លើយ របៀបយកមនុស្សទៅកម្ទេច វាមានលក្ខណៈមួយជារបស់គេ ។ ហើយក៏ខ្ញុំជឿថា នគរបាលរបស់ខ្មែរក្រហមទូទាំងប្រទេស ដូចជាជៀសមិនរួចពីទារុណកម្មធ្វើគ្រប់តែគ្នាតាំងពី៧០ មក ។ ក៏ប៉ុន្តែដោយឡែក សូមជម្រាបបញ្ជាក់កញ្ញា ស្រ៊ីនណា ថា

នៅពេលដែលខ្ញុំចូលទៅកាន់កាប់កិច្ចការហ្នឹង ណាត និង ខ្ញុំ មាននិយាយគ្នាពីរឿងទម្រង់ធ្វើទារុណកម្ម។

ទម្រង់ទារុណកម្ម ណាត គាត់ចូលចិត្តណាស់ អានក់អគ្គីសនី ទូរស័ព្ទរវៃនេះ ។ នេះជារូបភាពដែល ណាត គាត់ពេញចិត្ត ។ ជាគោលការណ៍កំណត់ត្រឹមប៉ុណ្ណឹងទេ ទូរស័ព្ទរវៃ ក៏ប៉ុន្តែ អ្នកអនុវត្តមិនមានទូរស័ព្ទរវៃឯណា ភ្លើងជញ្ជាំងអា២២០ វ៉ុល ។ នេះច្បាស់ៗ ។

ទីពីរ ខ្ញុំនិយាយថា អ្ហឺ! ទៅរកស្អីឯណាទេ ញ៉ុញញ៉ុញច្រើន គេប្រើតែរំពាត់ទេ ។ នេះទីពីរ ។

ទីបី ទៀតខ្ញុំក៏រំឭកដែរថា កាលដែលខ្ញុំនៅម-១៣ នោះបង វន គឺ វន វេត គាត់ពេញចិត្តណាស់នឹងច្រក ស្បោងផ្លាស្ទិក ប៉ុន្តែជំនាន់នោះយើងទៅរកស្បោងឯណាបាន ហើយខ្ញុំនិយាយជាមួយ ណាត ។ ខ្ញុំថាអា ស្បោងហ្នឹងឆាប់គ្រោះថ្នាក់ណាស់ ភ្លេចខ្លួនបន្តិចងាប់ឥឡូវហ្នឹង មិនបានទេ វរៗដាច់ចម្លើយអស់ហើយ រឿងដល់យើងទៀត ។ នេះវិធីទីបី ។

ឯចំណែកវិធីទីបួន គឺវិធីរបស់អធិការនគរបាលជាតិ ប៉ូលិសរបស់ លន់ នល់ និយាយឲ្យចំ ដាក់កន្សែងលើច្រមុះអីចេះហើយ យកទឹកកំសៀវច្រួចចូលច្រមុះ កខិកកខក់ៗ មួយសន្ទុះសន្ទប់ ទាញអូសចុះឡើងអាទឹកចេញមក បានៗគេចាប់ផ្តើមសួរចម្លើយតទៅទៀត ។ អានេះ មនុស្សគ្មានពិសោធន៍ក៏សន្លប់ដែរ អ្ហូស! ក៏ដាច់ដង្ហើមងាប់ដែរ មិនបានទេ ។ ដូច្នេះ វិធីដែលយើងខ្ញុំពិគ្រោះ ជាមួយនឹង ណាត ប៉ុណ្ណេះ ។

ការអនុវត្តតមកទៀត នៅពេលដែល ណាត ធ្វើប្រធាន មិនដឹងជាគាត់ឲ្យអនុវត្តប៉ុនណាទេ ប៉ុន្តែខ្ញុំជឿ ថាវិធីដែលប្រើជាទូទៅនៅពេលដែល ណាត គាត់ធ្វើជាប្រធាន ប្រហែលជាពីរ ទីមួយ គឺវិធីបែបវ៉ៃដែល មានលក្ខណៈទូទៅពេញផ្ទៃប្រទេស ហើយនិងវិធីទីពីរ អាឆក់ ។ ឆក់ខ្សែភ្លើង ដោយរវៃទូរស័ព្ទដៃ ។ នេះទីពីរ ។ នេះសូមបញ្ជាក់ប៉ុណ្ណេះ ។ ឯចំណែកវិធីទីបី ដូចមិនមាននរណាប្រើទេ អាច្រកទឹកតាមច្រមុះនេះ ហើយអាច្រកស្បោងផ្លាស្ទិក អាចមានអ្នកធ្វើខ្លះ ។ នេះខ្ញុំសូមបញ្ជាក់អំពីវិធីធ្វើទារុណកម្ម ដែលយើងខ្ញុំពិគ្រោះជាមួយនិង ណាត ។

ឯចំណែកអ្នកសួរមានប៉ុន្មានប្រភេទ អាហ្នឹងខ្ញុំបានជម្រាបអង្គសវនាការ ច្បាស់លាស់ហើយ ខ្ញុំសូមនិយាយតែអំពីវិធីធ្វើទារុណកម្មឲ្យស្របទៅតាមសំណួររបស់កញ្ញា ស៊្រីនណា ប៉ុណ្ណេះ ។

សូមលោកប្រធានជ្រាប ។

**ប្រធានអង្គជំនុំ៖**

រំឭកឡើងវិញ ដូចជាអាចមានការភាន់ច្រឡំ ហើយសំណួរប្រហែលជាមានការប៉ុនប៉ងសួរទៅ

ជនជាប់ចោទអំពី ការគិតគូរអំពី ឧបករណ៍ ឧបករណ៍សម្ភារៈទេ មិនមែនរបៀបទេ ។ ឧបករណ៍ ដូចថាជាខ្នោះ ជាកន្លែងបង្គោលសម្រាប់ចងព្យួរ ឬក៏ជាដំបងអីៗផ្សេង យើងវិធីក្នុងការគិតគូរពីឧបករណ៍ទាំងអស់យកមកប្រើប្រាស់ យើងបានគិតគូរគ្នាទេ? ហើយប្រភពនៃឧបករណ៍ហ្នឹង យើង រៀបចំយ៉ាងម៉េច? ព្រោះវាពាក់ព័ន្ធនឹងសំណួររៀបចំបង្កើតស-២១ ។ អ៊ីចឹងសំណួរប្រហែលជា បើតាមខ្ញុំស្តាប់យល់គឺសំណួរប៉ុនប៉ងសួរ គឺរបៀបនេះ ខ្លីគឺរបៀបនេះ ។ អ៊ីចឹង សូមបញ្ជាក់ឡើងវិញ តើសំណួរបំណងនៃការសួរត្រឹមត្រូវទេ ដែលការសង្ខេបរបស់ខ្ញុំនេះ ។ កញ្ញា មេធាវី ?

**កញ្ញា ទី ស្រ៊ីនណា៖**

របស់ខ្ញុំគោលបំណង គឺដូចលោកប្រធានបានមានប្រសាសន៍អំមិញហ្នឹង ។

[១០:០០:១២]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងសូមជនជាប់ចោទឆ្លើយនឹងសំណួរនេះ ការរៀបចំនូវឧបករណ៍សម្ភារៈដែលសម្រាប់ប្រើប្រាស់នៅក្នុងការអនុវត្តភារកិច្ចនៅ ស-២១ ការរៀបចំដំបូង ។

**ឆ៖** អរគុណលោកប្រធាន ។ ដូច្នេះខ្នោះ ច្រវាក់ មិនមែនជាឧបករណ៍ធ្វើទារុណកម្មទេ អានេះជាឧបករណ៍ ឃុំឃាំង វាមានលក្ខណៈទូទាំងប្រទេសហើយ ។ ឯចំណែកឧបករណ៍ដែលអនុញ្ញាតឲ្យប្រើដំបូងៗហ្នឹង គឺមានរំពាត់ ហើយនិង អាទូរស័ព្ទដៃ សម្រាប់រវៃឲ្យឆក់ ឯប៉ូតូសម្រាប់ចងព្យួរ អីនោះគ្មានទេ ហើយក៏ខ្ញុំមិនជឿទាល់តែសោះរហូតឥឡូវនេះ ថាមានការព្យួរអីៗ ច្រកទឹកក្បាលក្នុងអាងអីអត់ទេ ។

ដូច្នេះ ការកកើតដំបូងកំណត់ប៉ុណ្ណោះឯង មានតែទូរស័ព្ទរវៃ រំពាត់ ហើយនិងអាចអ្នកខ្លះយកស្បោងផ្លាស្ទិក យកទៅប្រើបាន នេះដំបូងគឺបីហ្នឹង ។ សូមបញ្ចប់ ។

[១០:០១:២៧]

**ប្រធានអង្គជំនុំ៖**

បើកក្បាលមេក្រូ ។

**សួរដោយកញ្ញា ទី ស្រ៊ីនណា៖**

សូមអរគុណ ។ ខ្ញុំសូមបន្តទៀតទាក់ទងទៅនឹងបញ្ហាឧបករណ៍ទៅលើការឃុំឃាំងវិញម្តង ។

**ស៖** ទាក់ទងទៅនឹងបញ្ហាខ្នោះ ក៏ដូចសម្ភារៈផ្សេងៗ ដូចជាមានគ្រែ នៅក្នុងរូបភាពដែលលោក

ព្រះរាជអាជ្ញាបានបង្ហាញពីអម្បាញ់មិញនេះ យើងក៏បានឃើញដែរ ដូចជាមានគ្រែ មានដែកអី ដែកអីផ្សេងៗ ដើម្បីឃុំឃាំងទៅលើជនអ្នកទោសនៅក្នុងមន្ទីរស-២១ ។ តើឧបករណ៍ទាំងហ្នឹង តើលោកយកមកពីខាងណាដែរ? ឬមួយក៏មានការប្រជុំពិភាក្សាដើម្បីកំណត់ ថាតើនឹងយកឧបករណ៍ហ្នឹង សម្រាប់មកឃុំឃាំងហ្នឹង តើមានការប្រជុំគ្នារវាងមេថ្នាក់លើ ឬមួយក៏គ្រាន់តែរវាងត្រឹមតែប្រធាន លោក ណាត ឬក៏ជាមួយនឹងលោកផ្ទាល់ ឬមួយក៏មានថ្នាក់លើដូចជាលោក សុន សេន អីគាត់បានចូលរួមពិភាក្សាដេញដោលគ្នាដើម្បីបង្កើតឲ្យមានទម្រង់នៅក្នុងការឃុំឃាំងហ្នឹង ដោយយកឧបករណ៍ហ្នឹងយកមក ហើយឧបករណ៍ហ្នឹងបានមកពីកន្លែងណា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមឆ្លើយនឹងសំណួរកញ្ញា ស្រ៊ុនណា ដូចតទៅ៖

ឃុំឃាំងដាក់ខ្នោះ វាជារូបភាពមួយ ក្រោយ១៧ មេសា ដែលយើងមានលទ្ធភាពធ្វើខ្នោះបាន ។ ដែលហៅថាខ្នោះនោះ វាមានរនងដែកវែងអ៊ីចេះទៅ ហើយមានកងដាក់ជើងពេលដេក ។ កាលពីសម័យ យើងខ្ញុំនៅមន្ទីរ-១៣ អមលាំង ដូចរកខ្នោះ អ្នករកបានៗ ។ ក៏ប៉ុន្តែដោយឡែក ខ្នោះនៅស-២១ នេះមានតាំងពីគុកតាខ្មៅមក ហើយមិនដឹងគេយកពីណាថែមទៀត ធ្វើថែមទៀតក៏មិនដឹង ក៏ប៉ុន្តែអាចខ្នោះមួយចំនួនយកពីគុកធំមក គុកធំ ភ្នំពេញ ក៏មានខ្នោះដែរ ។ នេះប្រភព ខ្ញុំអត់បានដឹងទេ ហើយកញ្ញាស្រ៊ុនណា ចង់ដឹងថា តើនេះជាការសម្រេចរបស់ខ្ញុំ និង ណាត ក្នុងគណៈកម្មាធិការស-២១ នេះឬក៏ជាការសម្រេចពីលើមក? សូមជម្រាបបញ្ជាក់ជូនអង្គសវនាការថា រឿងអស់នេះអត់មានអំពល់រវល់ដល់មេទេ ។ ជាភារកិច្ចដែលមេកំណត់មក ឃុំឃាំងឲ្យជាប់កុំឲ្យរត់រួច ឃុំឃាំងឲ្យជាប់កុំ ឲ្យសម្លាប់ខ្លួនបាន សួរចម្លើយចប់ហើយរង់ចាំសេចក្តីសម្រេចចំពោះជាមនុស្ស មនុស្សសំខាន់ មនុស្សមិនសំខាន់ ស-២១ យកចេញខ្លួនឯង ។

[១០:០៥:១០]

សរុបមកវិញ រឿងខ្នោះ រឿងច្រវាក់ រឿងអីៗនេះ ជារឿងដែលខ្ញុំពីរនាក់ក្នុងគណៈកម្មាធិការម្ចាស់ការជាមួយ ណាត ជាពិសេសគេម្ចាស់ការរួចមុនខ្ញុំចូលទៅធ្វើជាអនុប្រធាននោះទៅទៀត ។ អត់អំពល់រវល់ដល់មេទេ ។ សូមបញ្ជាក់ប៉ុណ្ណោះ ។

**ស៖** សូមអរគុណ ។ ឥឡូវនាងខ្ញុំសូមបន្តសំណួរ ទៅសំណួរទីពីរ ដែលពាក់ព័ន្ធទៅនឹងប្រភេទអ្នកទោស ។ ខ្ញុំចង់សួរថា តើនៅក្នុងមន្ទីរ ស-២១ ដែលរៀបចំឡើងហ្នឹង មានការកំណត់ថា តើប្រភេទអ្នកទោសបែបណា ដែលបញ្ជូន គួរតែបញ្ជូនមក ស-២១? និងអ្នកទោសប្រភេទបែបណា ដែលគួរតែ

បញ្ជូនទៅមន្ទីរផ្សេងៗទៀត? តើមានការកំណត់បែបហ្នឹងដែរឬទេ?

**ឆ៖** សូមជម្រាបកញ្ញា ស្រ៊ីនណា តាមចម្លើយដែលសួរខ្ញុំនេះ ។ ដំបូង ស-២១ នេះវាជាមន្ទីរនគរបាលកងពល៧០៣ ។ រយៈកាលដំបូង គឺជារយៈកាលសម្រិតសម្រាំងអ្នករដ្ឋការចាស់ ទាហានចាស់ និងប៉ូលិសចាស់របស់ លន់ នល់ ។ រយៈកាលដំបូងនេះ សហាចៅក្រមស៊ើបអង្កេតក៏វិភាគ ហើយនិង សន្និដ្ឋានដែរ គឺជាឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយកងពលនានា ។ រយៈកាលដំបូងនេះគេជម្លៀសប្រជាជន គេលួចចាប់នាយទាហាន យកទៅកម្ទេចសម្ងាត់ ហើយបន្ទាប់មកទៀត ណាត មានផលប្រយោជន៍ផ្ទាល់ខ្លួនផងពីរ ដើរសុំច្បាស់មេ យកពាក្យស្លោកថា “ទៅសុំដើររើសយកមនុស្សសំខាន់ៗយកមករៀនសួរចម្លើយ” ។ តែតាមពិត ណាត ក៏មានផលប្រយោជន៍ទៅរក ឲ្យគេទៅរកឪពុកក្មេក ចុងក្រោយរបស់គាត់ គាត់គឺឪពុកនាង អៀន នីម នេះ ។ ទន្ទឹមនឹងនេះ គាត់ក៏ទៅរកសង្សារដើមរបស់គាត់នោះ រកចុះរកឡើងទៅឃើញនៅបារាយណ៍ ងួន គឹមប៊ាង នេះ ។

ដូច្នេះ ឆ្លៀតពេលអាដែលទៅដើម្បីសុំមេ ទៅដើម្បីជាផលប្រយោជន៍ការងារបក្សបដិវត្តន៍អង្កាលហ្នឹង អាយើងហៅថា បដិវត្តន៍អ៊ីចេះទៅចុះ តាមពិតវាជាការងារឧក្រិដ្ឋ ក្នុងការដើរចាប់គេយកមកដាក់គុក ហើយមកវៃចោល ។ ណាត គាត់ដើរពាសពេញដែរ ទៅប្រមូលពីនេះ ទៅប្រមូលពីនោះមក ឲ្យតែមេទាហាន ឲ្យតែមេប៉ូលិស ឲ្យតែស្អីហ្នឹង ប្រមូលចុះប្រមូលឡើងដោយទាំង *ម៉ុងស្សឺអារីហ្សេ* ទិព្វ ម៉ម ដោយទាំង ដុកទ័រ វ័ន្ត គត់ បងធម៌ខ្ញុំ មក ហ៎មិនមែនតែប៉ុណ្ណឹងទេច្រើន ។

[១០:០៧:១៧]

ដូច្នេះ ទិសតំបន់វាច្របូកច្របល់អស់ នេះជាការពិត ដំបូងច្របូកច្របល់ណាស់ ប៉ុន្តែទិសរបស់គេនៅដដែលទេ នឹងនទេ ។ អ្នករាជការចាស់ ទាហានចាស់ ប៉ូលិសចាស់ ចូលហើយ ចូលមកហ្នឹងហើយ ។ ក៏ប៉ុន្តែ ដល់រយៈកាលទីពីរ នៅពេលដែលខ្ញុំឡើងកាន់កាប់ សម្តីជាសំខាន់ផ្ទៃក្នុង ។

ដូច្នេះ ផ្ទៃក្នុងដែលចូលមក ស-២១ ទាល់តែមេខ្ញុំលោកគ្រូ សុន សេន ស្នើសុំពីភូមិភាគផ្សេងទៀត ។ ដោយឡែក ភូមិភាគនិរតីរបស់ខ្មោច តាម៉ុក ទោះបីមេខ្ញុំស្នើសុំក៏ដោយ គាត់មិនឲ្យៗ នេះជារឿងពិត ។

សរុបមកវិញ មួយរយៈកាលដំបូងវាមានអាខាងពីនោះគេបញ្ជូនមក ឧទាហរណ៍ ដូចយ៉ាង ឈិត អ៊ីរ អ៊ីហ្នឹង ខាងមូលដ្ឋានគេចាប់បាន គេបញ្ជូនមក ។ ក៏ប៉ុន្តែ មានអ្នកទៅស្នើសុំដែរ ឧទាហរណ៍ ទិព្វ ម៉ម ខ្ញុំសង្ស័យថា ណាត គាត់ទៅស្នើសុំ, វ័ន្ត គត់ អ៊ីខ្ញុំសង្ស័យ ។ នេះដំបូងអ៊ីចឹង ។ ឯចំណែកចាប់

តាំងពីខ្ញុំប៉ិបឡើងចូលធ្វើជាប្រធាន ទិសដៅ គឺសម្រិតសម្រាំងផ្ទៃក្នុង មេបញ្ជូនមកបាន ទទួលបាន ទោះបីមេបញ្ជូនមកហើយក៏ដោយ ដោយឡែកនិរតីអត់ចូលមកដល់នេះទេ គេម្ចាស់ការនៅខាងនោះរបស់គេ ។ សូមជម្រាបលោកប្រធានប៉ុណ្ណោះ ។

**ស៖** សូមអរគុណលោកពូ ។ ខ្ញុំសូមបន្តសំណួរទីបី របស់ខ្ញុំទាក់ទងទៅនឹងការធ្វើរបាយការណ៍នៅក្នុងដំណាក់កាលដំបូងនៃការបង្កើតមន្ទីរស-២១ ។ តើលោកមានការប្រជុំដើម្បីរៀបចំជាការបង្កើតទម្រង់របាយការណ៍ដើម្បីធ្វើការរាយការណ៍ទៅថ្នាក់លើរបស់លោកពូផ្ទាល់ ឬមួយក៏យ៉ាងម៉េច? សូមលោកពូជួយបំភ្លឺកន្លែងនឹងបន្តិចមក?

[១០:០៩:៣០]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ។ ខ្ញុំសូមអនុញ្ញាតឆ្លើយនឹងសំណួរ កញ្ញា ស្រ៊ីនណា ដូចតទៅ៖

នៅពេលដែលខ្ញុំចូលដំបូង របៀបធ្វើរបាយការណ៍គឺ ណាត គេអនុម័តណែនាំ។ បន្តិចទៀតយើងនឹងឃើញហើយ របៀបសួរចម្លើយ និងយកចម្លើយអំពីអ្នកស្រី ជូឡុង រង្សី ខុសអំពីរបៀបសួរចម្លើយរបស់ខ្ញុំ ។ ដល់ក្រោយមក សួរចម្លើយពួកអគ្គីសនីផ្សារតូច អត់មានសួរអីច្រើនទេ មកដល់ធ្វើ *អូរហ្គាន* ធ្វើអង្គការលេខមួយ មេគេអ្នកណា? ឧទាហរណ៍មេគេអ្នកនេះទៅ បន្ទាប់មកចុះក្រោមអ្នកណា? ប្រគល់ទៅឲ្យមេខាងលើ ឲ្យមេខាងលើចាត់ចែង ឬក៏តាមចាប់ ។ នេះជារបៀបរាយការណ៍មុនដែលខ្ញុំឡើងធ្វើជាប្រធាន ព្រោះទិសដៅពេលនុ៎ងអត់មានគិតអីច្រើនទេ ឲ្យតែអ្នករាជការចាស់នេះចាស់ខាងលើគេតាម គេឲ្យតាមរកហើយ ។ នេះជាមាគ៌ា ជាគោលការណ៍ជំនាន់នុ៎ង ។ នៅពេលដែលខ្ញុំកាន់កាប់ធ្វើជាប្រធានរបៀបរាយការណ៍ទៅផ្សេង ដូចសំណល់នៅមានទាំងអស់រាប់ម៉ឺន រាប់ពាន់សន្លឹកនេះ ជាឧទារហណ៍ស្រាប់ ។

ដូច្នេះ របៀបរាយការណ៍ហ្នឹងក៏វិវត្តដែរ ម្យ៉ាងវាវិវត្តទៅតាមសមត្ថភាពរបស់មេស-២១ តែម្យ៉ាងទៀត វាវិវត្តទៅតាមតម្រូវការនៃការសម្រិតសម្រាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ពីជំនាន់មួយទៅជំនាន់មួយ ។ នេះសូមបញ្ជាក់ជូនលោកប្រធាន នៅចម្លើយ ទី ស្រ៊ីនណា ប៉ុណ្ណោះ ។

[១០:១១:១៦]

**ស៖** សូមអរគុណ ខ្ញុំសូមបន្តទៅចំណុច ពីរ-បីចំណុចទៀត ប៉ុន្តែពុំមែនជាសំណួរទេ គឺចំណុចដែលខ្ញុំសូមបញ្ជាក់បន្ថែម ដែលលោកពូបានឆ្លើយកាលពីម្សិលមិញ ក៏ដូចជាម្សិលម៉្ងៃ ។ ខ្ញុំសូមបញ្ជាក់

មួយពាក់ព័ន្ធទៅនឹងបញ្ហាគុកនៅតាខ្មៅ ម្សិលមិញហ្នឹងលោកពូថា គុកនៅតាខ្មៅហ្នឹងគឺ បង្កើតឡើងនៅថ្ងៃទី០១ មិថុនា ឆ្នាំ-- (សូមទោស) ថ្ងៃ១៧ មេសា ១៩៧៥ និងបញ្ចប់ទៅវិញនៅថ្ងៃ០១ មិថុនា ឆ្នាំ ១៩៧៦ តើមែនឬក៏មិនមែន?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ហើយជម្រាបប្រសាសន៍ កញ្ញា ស្រ៊ីនណា ថា មិនច្បាស់ដល់ទៅ១៧ មេសា ហើយ ០១ មិថុនា ទេ ។ អាចក្រោយ ១៧ មេសា មួយថ្ងៃពីរ ហើយមេសា អ៊ូ!សុំទោស ឧសភា អ្អឺ! មិថុនា? មិថុនា មិនចំថ្ងៃ០១ទេ មិនដឹងថ្ងៃណាទេ ព្រោះយើងវិភាគទៅតាមការដែរ ណាត គាត់ចុះឡើងមកស-២១ ដើម្បីបង្ហើយការងារនៅគុកតាខ្មៅនេះ ។ ដូច្នេះ--

**ស៖** *(មិនឮសំឡេង)*

**ឆ៖** បាទ! យើងសន្មតអ៊ីចឹងទៅចុះ នេះនៅត្រឹមសន្មតនៅឡើយទេ ។

**ស៖** អ៊ីចឹងខ្ញុំសូមបន្តថា តើនៅពេលដែលពន្ធនាគារនៅ-- នៅពេលដែលមន្ទីរនៅតាខ្មៅហ្នឹងត្រូវបានបញ្ចប់ តើមន្ទីរហ្នឹងគេយកទៅធ្វើអ្វី ឬមួយក៏គេនៅតែរក្សាដើម្បីបន្តការឃុំខ្លួនតទៅទៀត ឬមួយក៏យ៉ាងម៉េចដែរ?

[១០:១២:៤៩]

**ឆ៖** អរគុណ កញ្ញា ទី ស្រ៊ីនណា ។ សូមជម្រាបប្រសាសន៍លោកប្រធានថា រឿងនេះខ្ញុំសូមបញ្ជាក់ម្តងទៀត ខ្ញុំនិយាយម្សិលមិញអាចមិនច្បាស់ ។ ក្រោយដែល ណាត គាត់មកទាក់ទងនឹងមិត្តហ៊ី នៅពេលដែលគាត់ចេញផុតទៅ ខ្ញុំឃើញគាត់មកប្រហែលដល់ក្នុងខែមិថុនាហ្នឹង គាត់ចាប់ពេលហ្នឹងមកគាត់ឈប់មក ។ ដូច្នេះគុកនៅតាខ្មៅហ្នឹងទុកចោល ពេទ្យឆ្កួតនៅតាខ្មៅហ្នឹងទុកចោល ហើយដល់ក្រោយមក ថ្ងៃខែមិនចាំទេ មិនដឹងជាចុង៧៦ ឬដើម៧៧ បើតាមរំឭកឡើងវិញអាចនៅក្នុងឆមាសទី១ ១៩៧៧ ដែលមេទូរស័ព្ទមកឲ្យខ្ញុំប្រគល់អាគុកតាខ្មៅនេះទៅឲ្យក្រសួងសង្គមកិច្ច គេប្រើជាមន្ទីរពេទ្យឡើងវិញ ។ ហើយពេលហ្នឹងហើយដែលខ្ញុំបានសុំពន្យារពេលដើម្បីគាស់កកាយយកអដ្ឋិធាតុយកទៅដុតឲ្យអស់សិនសឹមប្រគល់ ។

សរុបមក តាំងពីពេលគុកនេះចប់ប្រើ ឈប់លែងឃុំឃាំងមនុស្ស គុកនេះទុកចោល ។

**ស៖** សូមអរគុណ ខ្ញុំសូមបញ្ជាក់នូវចំណុចទី២ ។ ម្សិលមិញ លោកបានមានប្រសាសន៍ថា មុននៅពេលដែលលោកមកដល់ភ្នំពេញដំបូង លោកបានរៀន ទទួលវគ្គការបណ្តុះបណ្តាលចប់ លោកក៏មានរយៈពេលប៉ុន្មានថ្ងៃដើម្បីរង់ចាំទទួលភារកិច្ចថ្មី ។ ហើយទន្ទឹមនឹងនោះដែរ លោកក៏បានស្នើទៅមេថា សុំ

ទៅកាន់ខាងមន្ទីរឧស្សាហ៍កម្ម តើការដែលលោកស្នើទៅកាន់មន្ទីរឧស្សាហ៍កម្មហ្នឹង តើលោកៗបានស្នើសុំប៉ុន្មានលើកប៉ុន្មានសារដែរ ប៉ុន្មានដងដែរ? មុននឹងប្រធានរបស់លោក ថ្នាក់ដឹកនាំរបស់លោកសម្រេចឱ្យលោកទៅធ្វើជាប្រធានមន្ទីរស-២១?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន កញ្ញា ស្រ៊ុនណា នៅតែច្រឡំថ្ងៃខែ នៃការដែលខ្ញុំសុំខ្ញុំសុំទៅឧស្សាហកម្មនេះ នៅពេលដែលបង ចេង អន ចុះទៅប្រមូលកម្មករពីជនបទចូលមកក្រុងភ្នំពេញវិញ ។ សូមជម្រាបអង្គសវនាការទាំងមូលថា ក្រោយ១៧ មេសា បក្សកុម្មុយនីស្តជម្លៀសចេញទាំងអស់ហើយ ។ កម្មករក៏ជម្លៀសចេញ អ្នកមន្ត្រីរាជការក៏ជម្លៀសចេញ នាយទុនក៏ជម្លៀសចេញ ជាងកាត់សក់ក៏ជម្លៀសចេញដែរ តែទាំងអស់ អត់មានសល់ទេ ។ អ្នកដែលមករស់នៅភ្នំពេញបន្ទាប់ពីនោះមក គឺពួកកងទ័ពបដិវត្តន៍ ។ នៅក្នុងខែឧសភា នៅពេលដែលដោះស្រាយបញ្ចប់ការងារនៅមន្ទីរ១៣ ចប់ហើយ ខ្ញុំឧស្សាហ៍ជិះម៉ូតូ ។

[១០:១៥:៥៥]

ដូចកញ្ញាជ្រាបហើយ អង្គជំនុំជម្រះជ្រាបហើយ ថាខ្ញុំបានម៉ូតូថ្មីមួយជិះមកផ្ទះបង អន ចាស់ផ្ទះបងកន ហើយនិងផ្ទះ បងកែវ ដើម្បីរង់ចាំក្រែងលោអង្គការហៅ ។ នៅពេលដែលរង់ចាំហ្នឹងហើយគេមកភ្នំពេញស្ងាត់អស់ ពេទ្យក៏មកភ្នំពេញ មន្ទីរជុំវិញ មន្ទីរបងខៀវ ក៏មកភ្នំពេញអស់ ពួកអង្គភាពភូមិភាគពិសេសមកអស់ ។ ខ្ញុំឆ្ងល់ដែរ យីម៉េចចេះអញ គេទុកចោលកំបុតកទេដឹង? អាហ្នឹងគិតដែរអ្ហែអាហ្នឹងគ្រាន់តែគិតទេ ។ ដល់ពេលឃើញបងអន ទៅអង្វរគាត់ ។ ចេង អន ចុះទៅប្រមូលកម្មករអង្វរគាត់ ខ្ញុំថា “ខ្ញុំទៅធ្វើរោងចក្រជាមួយនឹងបងដែរ ខាងថាបងជួយសុំខាងលើឱ្យខ្ញុំផង” បងអន ថា “អឺៗ ឥឡូវថ្ងៃនេះចាំ” បើតាមខ្ញុំចាំថ្ងៃដែលខ្ញុំជួប បងអន ហ្នឹងប្រហែលជាថ្ងៃ២៣ ឧសភា ឆ្នាំ១៩៧៥ ។ ហើយគាត់ឱ្យខ្ញុំចាំមួយអាទិត្យទៀត គឺថ្ងៃ៣១ ឧសភា ។ ថ្ងៃ៣១ ឧសភា ជួបគ្នា ខ្ញុំក៏អរ ដល់ខ្ញុំទៅថ្ងៃ៣១ ឧសភា មិនជួបបងអន ជួបនីរសារបងអន មិត្តសៀ ឱ្យសំបុត្របងអន មកថា “អង្គការអត់ឱ្យមិត្តមកឧស្សាហកម្មទេ មិត្តនៅរង់ចាំភារកិច្ចដែលអង្គការចាត់តាំង” ។ ដូច្នេះ តាំងពីចុងខែឧសភាម្ល៉េះ ។

ខ្ញុំសូមបញ្ជាក់ម្តងទៀតណា មិនកំណត់ថ្ងៃឱ្យច្បាស់ចំដូចខ្ញុំជម្រាបអង្គប្រជុំនៅពេលនេះប៉ុណ្ណឹងពេកទេ ។ សូមកញ្ញាកុំប្រកាន់ ។ ក៏ប៉ុន្តែមុនតែងតាំងខ្ញុំបង្កើតស-២១ ។ ដល់បង្កើតស-២១ ដូចខ្ញុំជម្រាបអង្គសវនាការម្សិលមិញអ៊ីចឹង ។ ក្រោយពីឧទ្ទេសនាមហើយ គាត់ថា អើ! ខ្ញុំក៏ទៅឃោធាតទៅទៀត មិត្តក៏នៅសន្តិបាលតទៅទៀត អាហ្នឹងគេល្បងលោមយើងប៉ុណ្ណឹង ដល់គេល្បងលោមយើងប៉ុណ្ណឹងថ្នាក់ដឹកនាំ

ហើយយើងប៉ាានប្រកែក កំបុតកណំា ។ ហ្នឹងខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** សូមអរគុណលោក ។ មុននឹងឈានចូលទៅដល់ការបញ្ជាក់នៅចំណុចមួយ ជាចំណុចចុងក្រោយ នាងខ្ញុំក៏សូមជ្រាបជូនលោកពូដែរ ទាក់ទងនឹងការបញ្ជាក់របស់នាងខ្ញុំនេះ ខ្ញុំសូមឲ្យឆ្លើយឲ្យខ្លីបំផុតដើម្បីងាយយល់ទាំងអស់គ្នា ។ ម្សិលមិញហ្នឹងលោកពូបានមានប្រសាសន៍ថា លោកពូ គោលបំណងរបស់លោកពូពិតប្រាកដ គឺចប់ធ្វើជាគ្រូបង្រៀន តើមែនឬក៏មិនមែន?

**ឆ៖** សូមជម្រាបលោកប្រធានជាទីគោរព! សំណួររបស់ ទី ស្រ៊ីនណា បញ្ជាក់នេះ ខ្ញុំសូមឆ្លើយតែមួយម៉ាត់តាមសំណូមពររបស់នាង។ ពិតៗ តែវង់ចាំភារកិច្ចអីជាគ្រូនោះវាមិនបានមួយជាតិហើយ ។

[១០:១៨:៥៩]

**ស៖** ខ្ញុំបន្តទៅទៀត ពេលអំឡុងពេលដែលលោកពូបានមកនៅភ្នំពេញ ដែលបញ្ចប់វគ្គបណ្តុះបណ្តាលហើយនៅភ្នំពេញប៉ុន្មានថ្ងៃ ដែលបានម៉ូតូជិះ ហើយលោកពូបាននិយាយថា លោកពូបានទៅឃើញវិទ្យាល័យមួយ ហៅថាវិទ្យាល័យពញាយ៉ាត និងមួយទៀតទៅឃើញនៅវិទ្យាល័យព្រះស៊ីសុវត្ថិ តើមែន ឬក៏ពុំមែន? ហើយពេលនោះលោកពូក៏កើតមានគំនិតមួយថា វិទ្យាល័យទាំងពីរហ្នឹង គឺជាកន្លែងមួយងាយស្រួល នៅក្នុងការឃុំឃាំងមនុស្ស ក៏ដូចជាងាយស្រួលនៅក្នុងការសួរចម្លើយ តើមែន ឬក៏ពុំមែន?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន កញ្ញា ស្រ៊ីនណា បែបច្រឡំហើយ ។ ច្រឡំនឹងវិទ្យាល័យស៊ីសុវត្ថិ ខ្ញុំអត់ដែលមាននិយាយដល់សោះ វិទ្យាល័យស៊ីសុវត្ថិ ។ ខ្ញុំធ្លាប់នៅរៀនវិទ្យាល័យស៊ីសុវត្ថិពីរឆ្នាំក៏ប៉ុន្តែកន្លែងដែលខ្ញុំយកប្រើធ្វើគុកនោះ គឺវិទ្យាល័យពញាយ៉ាត ។ សូមបញ្ជាក់ជូនកញ្ញាថា វិទ្យាល័យពញាយ៉ាតនេះ ជាពាក្យដែលប្រើក្នុងជំនាន់សង្គមរាស្ត្រនិយម បន្ទាប់មកជំនាន់ លន់ លន់ បើតាមខ្ញុំចាំគេហៅថា វិទ្យាល័យទួលស្វាយព្រៃ បន្ទាប់មកសម័យខ្មែរក្រហម គឺខ្ញុំយកប្រើជាគុកស-២១ ។

**ស៖** ខ្ញុំសូមបញ្ជាក់ម្តងទៀត ពេលដែលលោកឃើញវិទ្យាល័យពញាយ៉ាតដំបូងភ្លាមលោកកើតមានគំនិតថា គឺជាកន្លែងមួយដែលងាយស្រួលនៅក្នុងការឃុំឃាំង ក៏ដូចជាងាយស្រួលនៅក្នុងការសួរចម្លើយ តើមែន ឬពុំមែន? ខ្ញុំសូមតែចម្លើយដែលខ្លីបំផុត ។

**ឆ៖** កញ្ញា ស្រ៊ីនណា! ខ្ញុំយកកន្លែងនេះធ្វើជាកន្លែងឃុំឃាំងប្រហែលជា នៅក្នុងខែមេសា ឆ្នាំ ១៩៧៦ កើតមានអារម្មណ៍យកអាកន្លែងហ្នឹងធ្វើ គឺនៅពេលក្រោយខ្ញុំឡើងធ្វើប្រធានហើយទេ ដើមឡើយខ្ញុំអត់គិតទេ ធ្វើអីធ្វើទៅ ។ អាណាម៉េចៗទៅ រួចគេទទួលខុសត្រូវ ។ នេះសូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** តើពេលនោះលោក ពេលដែលលោកឃើញវិទ្យាល័យពញាយ៉ាតដំបូង តើលោកអត់មានគំនិតមួយថា តើចង់បង្កើតឲ្យទៅជាសាលារៀនមួយឡើងវិញ ដែលស្របទៅគោលបំណងរបស់លោកកាលពីដំបូងអើយ ដែរឬក៏យ៉ាងម៉េច?

**ឆ៖** ចលនាបង្កើតសិក្សាធិការ គឺបក្សសម្រេច សមត្ថភាពខ្ញុំម្នាក់ឯង ទោះបីចង់ទៅធ្វើគ្រូយ៉ាងម៉េចក៏ដោយ ក៏មិនបានទៅដែរ ។ សូមបញ្ជាក់ថា រដ្ឋមន្ត្រីក្រសួងអប់រំជាតិប្រពន្ធមេខ្ញុំហ្នឹងតែម្តង *ម៉ាដាម* សុន សេន តែការងារគាត់ផ្សេង ការងារប្តីគាត់ផ្សេង ។ ខ្ញុំនៅក្រោមការគ្រប់គ្រងរបស់ប្តីគាត់ ។ ខ្ញុំអត់មានប៉ាននឹកនាទៅដល់ ចង់អាធ្វើអាវិទ្យាល័យនេះឡើងវិញឲ្យទៅជាស្អីនោះទេ ។ អត់មានអារម្មណ៍អត់លទ្ធភាព ។

**ស៖** តើលោកមិនមានបំណងចង់ស្នើសុំ សាកល្បងស្នើសុំដូចកាលដែលលោកបានសាកល្បងឲ្យស្នើសុំឲ្យវិទ្យាល័យពញាយ៉ាតហ្នឹងទៅជាមន្ទីរឃុំឃាំង?

**ឆ៖** (ឮមិនច្បាស់) កញ្ញា ។

*(លោកចៅក្រមប្រធាន អ្នកបកប្រែសុំឲ្យកញ្ញា ទី ស្រ៊ីនណា សាឡើងបន្តិច)*

[១០:២២:៣៥]

**ប្រធានអង្គជំនុំ៖**

មេធាវី និយាយសាឡើងវិញ ហើយមានការប្រយ័ត្នប្រយែងក្នុងការប្រើប្ញូតុងក្នុងការបើក ឬក៏បិទមេក្រូនេះ ពីព្រោះប្រព័ន្ធវាទាក់ទិនជាមួយនឹងប្រព័ន្ធនៃការបកប្រែ ហើយបើយើងនិយាយទៅអត់ចុចខាងណោះស្តាប់អត់បានទេ ។ ហើយកាលណានិយាយរួចហើយ បើអត់អត់បិទទេ ដល់ពេលខាងជនជាប់ចោទគាត់បើកដើម្បីឆ្លើយក៏អាចវាកុងគ្នា វាមានបញ្ហាសំឡេងអត់បានល្អទេ ឬក៏នាំឲ្យមានឮសូរស្តាប់មិនបាន ។ ឥឡូវបកក្រោយបន្តិចនូវសំណួរ ពីព្រោះខាងអ្នកបកប្រែស្តាប់អត់បាន ។

**កញ្ញា ទី ស្រ៊ីនណា៖**

សូមអភ័យទោសលោកប្រធាន ក៏ដូចជាអង្គសវនាការ ដោយសារខ្ញុំអត់ធ្លាប់ប្រើ ដល់អ៊ីចឹងទៅមានបញ្ហាមួយវាពិបាកបន្តិច ។ ហើយចំណុចមួយទៀត សូមអរគុណដែលលោកប្រធានជួយរំឭក ។ ខ្ញុំនឹងសុំចាប់ផ្តើមសំណួរខ្ញុំសាជាថ្មី ។

**ស៖** សំណួរខ្ញុំចង់សួរថា នៅពេលដែលលោកបានទៅឃើញវិទ្យាល័យពញាយ៉ាតដំបូង តើលោកមានធ្លាប់សាកល្បងនៅក្នុងការស្នើសុំទៅថ្នាក់លើ ដើម្បីបង្កើតជាសាលារៀន តាមគោលគំនិតរបស់

លោក ដូចការស្នើសុំរបស់លោកដែលលោកធ្លាប់បានស្នើសុំទៅថ្នាក់លើរបស់លោក ដើម្បីបង្កើត-- យកវិទ្យាល័យពញាយ៉ាតនេះ ដើម្បីបង្កើតទៅជាមន្ទីរឃុំឃាំងក៏ដូចជាមន្ទីរសួរចម្លើយ ។

**ឆ៖** ជម្រាបអង្គសវនាការជាទីគោរព! ជម្រាបកញ្ញា ស្រ៊ុនណា ជាទីគោរពថា ខ្ញុំអត់បាននឹកនាដល់នុ៎ងទេ អាហ្នឹងជម្រាបត្រង់ណា អត់មាននឹងនាដល់នុ៎ងទេ ។ ចលនាសិក្សាធិការអត់ទាន់ចាប់ផ្តើមទេ ទើបនឹងតែងសៀវភៅសិក្សា១ទេ គម្រោងការសិក្សាធិការជំនាន់នុ៎ង បឋមសិក្សា៤ឆ្នាំ ។ មធ្យមសិក្សា៤ឆ្នាំ ឧត្តមសិក្សា៤ឆ្នាំ ទើបតែងសៀវភៅបានមួយពីរប៉ុណ្ណោះ ។

ដូច្នេះ ខ្ញុំគ្មាននឹកនាប៉ានផ្ទេរវិទ្យាល័យពញាយ៉ាតទៅជាវិទ្យាល័យឡើងវិញទេ ។ គ្មានសោះអត់ប៉ានសោះ ។ នេះវាជាអារម្មណ៍ដែលយើងត្រូវតែបត់ទៅតាមចលនាជំនាន់នុ៎ង ។ ចលនាជំនាន់នុ៎ងគេមិននឹកនាដល់សិក្សាធិការ យើងក៏អត់ប៉ាន ក៏អត់បាននឹកនា អត់ប៉ាននឹកនា អត់បាននឹកនាដែរ ។ សូមទោស នេះជាកំហុសមួយខាងផ្លូវចិត្តចំពោះមនុស្សជាតិ អារ្យធម៌មនុស្សជាតិយើង ។

[១០:២៥:៣៧]

**កញ្ញា ទី ស្រ៊ុនណា៖**

សូមអរគុណចំពោះការឆ្លើយតបរបស់លោកពូ ហើយខ្ញុំក៏សូមអរគុណចំពោះអង្គសវនាការនិងសូមអរគុណលោកប្រធាន ។ ខ្ញុំសូមចប់សំណួរត្រឹមប៉ុននេះ ។ ហើយនិងសូមបន្តសំណួរនេះឲ្យទៅមេធាវីអន្តរជាតិ ដែលនៅក្នុងក្រុមមួយរបស់នាងខ្ញុំ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ។

**សួរដោយ លោក អាឡាំង វ៉ែនណឺ៖**

អរគុណលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំនឹងធ្វើយ៉ាងណាមិនចំណាយពេលរបស់អង្គសវនាការច្រើនទេ ។ តាមចម្លើយដែលខ្ញុំទទួលបានគឺ ខ្ញុំនឹងបញ្ចប់សំណួររបស់ខ្ញុំនៅក្នុងរយៈពេលម្ភៃទៅម្ភៃប្រាំនាទី ។ តើខ្ញុំអាចសួរបានដែរឬទេ?

អរគុណលោកប្រធាន។

អរុណសួស្តី! ឈ្មោះរបស់ខ្ញុំគឺអាឡាំង វ៉ែនណឺ ជាមួយនឹង ទី ស្រ៊ុនណា ខ្ញុំតំណាងក្រុមជនរងគ្រោះទីមួយ ។ ខ្ញុំមានសំណួរចំពោះជនជាប់ចោទ ។

**ស៖** សំណួរទីមួយ នេះគឺជាអង្គហេតុដែលបានព្រមព្រៀងរវាងសហព្រះរាជអាជ្ញា និងខាង

ការពារក្ដីនៅក្នុងខែមីនា គឺតាំងពី ហ៊ ជាជំនួយការរបស់លោកនៅស-២១ ហើយគាត់ទទួលខុសត្រូវចំពោះការងារប្រចាំថ្ងៃនៅ ស-២១ វានៅក្នុងចំណុចទី៣៦ នៃអង្គហេតុដែលបានព្រមព្រៀងគ្នារវាងសហព្រះរាជអាជ្ញា និងការពារក្ដី ។ នៅក្នុងសវនាការ លោកបានបញ្ជាក់យ៉ាងច្បាស់ ហើយនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ លោកលើកឡើងថា ហ៊ ជាអ្នកទទួលខុសត្រូវ ។ នៅពេលដែលលោកធ្វើការនៅ ស-២១ ហ៊ គាត់ធ្វើការខាងយោធា គឺគាត់ធ្វើការចាប់ខ្លួន ហើយនិងធ្វើការឃុំខ្លួនសួរចម្លើយផ្សេងៗនៅជើងឯក ។ ហើយទាក់ទងទៅនឹងសំណួរម្សិលមិញរបស់ចៅក្រមឡាវែន៍ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០០៩ លោកនិយាយថា "នៅក្នុងឆ្នាំ១៩៧៦ លោកបានលើកឡើងជូនលោកចៅក្រម ឡាវែន៍ ពីខែមីនាទៅដល់ខែមិថុនា ហ៊ គាត់ទទួលខុសត្រូវទៅលើការងារនៅគុកតាខ្មៅ ។ ហើយក្នុងអំឡុងពេលនុំង ណាត មកពីខេត្ត ។ ហើយនេះជាសំណួររបស់ខ្ញុំ ថាតើ ហ៊ គាត់ទទួលខុសត្រូវការងារប្រចាំថ្ងៃនៅ ស-២១ ទាក់ទងការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់យ៉ាងម៉េច? ហើយគាត់ទទួលខុសត្រូវជាន់គ្នាទៅលើការងារនៅគុកតាខ្មៅយ៉ាងម៉េច នៅខែបី ទៅដល់ខែមិថុនាឆ្នាំ១៩៧៦?

**ជនជាប់ចោទ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំសូមឆ្លើយនឹងសំណួររបស់លោក វ៉ែនណឺ ដូចតទៅ៖

ការងារនៅភ្នំពេញក៏ដោយ ដែលនៅក្រោមបញ្ជារបស់ខ្ញុំ ពីខែបីដល់ខែប្រាំមួយ ហ៊ មានភារកិច្ចយកគ្រប់កិច្ចការទៅបញ្ជា ផល ឲ្យអនុវត្ត ។ គេជាអ្នកត្រួតពិនិត្យពីលើ ។ ក៏ប៉ុន្តែ បើគ្មានបញ្ជាខ្ញុំ គេក៏មិនទៅបញ្ជា ផល ពាសវាលពាសកាលដែរ ។ នេះការពិតមួយ ។ ការពិតពីរ ណាត គាត់មិនមែនមករាល់ថ្ងៃទេ ដើម្បីបង្ហើយការងារនៅគុកតាខ្មៅ យូរៗខ្ញុំឃើញគាត់មកម្ដង ដោយបានអនុញ្ញាតពីមេច្បាស់លាស់មកទាក់ទងជាមួយនឹង ហ៊ ឲ្យបង្ហើយការងារចាស់ ។

ដូច្នេះ រឿងនៅគុកតាខ្មៅក៏ដោយ ហ៊ គាត់អត់ចុះទៅខ្លួនគាត់ទេ គាត់អាចប្រើគេ ជាពិសេសអាចប្រើ ហ៊ុយ ឬប្រើ ប៉េង ។ នេះសូមឆ្លើយបញ្ជាក់ប៉ុណ្ណេះ ការងារនេះអត់ជាន់គ្នារត់មិនរួចទេ រត់រួច ព្រោះគេជាអ្នកបញ្ជា ។

**ស៖** ចំពោះករណី ហ៊ លោកឆ្លើយជូនលោកចៅក្រម ឡាវែន៍ នៅថ្ងៃច័ន្ទទី ២៧ ខែមេសា ថា ប្រសិនបើ ហ៊ ធ្វើអ្វីខុស គាត់នឹងទទួលទណ្ឌកម្មដោយថ្នាក់លើជាអ្នកដាក់ទោស ។ ហើយលោកក៏និយាយដូចគ្នាដែរនៅចំពោះមុខចៅក្រមស៊ើបអង្កេត ។ ខ្ញុំសូមយោងទៅដល់កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរចម្លើយក្នុងឯកសារ D20 ខែតុលា ឆ្នាំ២០០៧ លោកលើកឡើងថា "គឺ ហ៊ គាត់

នឹងទទួលការដាក់ទោស ពីព្រោះគាត់ជាអ្នកទទួលខុសត្រូវចំពោះមុខបក្ស" ហើយខ្ញុំចង់លើកឡើងថា ប្រសិនបើ ហ៊ី ជាអ្នករត់ គាត់ធ្វើខុស តើវាមានការប៉ះពាល់ទៅដល់លោកដែរឬទេ?

[១០:៣១:៤៩]

**ឆ៖** លោកប្រធានជាទីគោរព! ខ្ញុំសូមឆ្លើយខ្លីមួយម៉ាត់មុននឹងអធិប្បាយឲ្យច្បាស់ ។ បើកំហុសនុំងធ្ងន់ធ្ងរ ពិតជាប៉ះពាល់ដល់ខ្ញុំ ។ ឧទាហរណ៍ បើសិនជា ហ៊ី ក្បត់បក្ស ចាប់អាវុធសម្លាប់ខ្ញុំ នាំអ្នកទោសរត់ទៅ ខ្ញុំស្លាប់ ។ បើសិនជាគាត់មិនបានសម្លាប់ទេ គាត់គិតតែនាំតែគ្នាគាត់រត់ចេញទៅ ខ្ញុំក៏ទទួលខុសត្រូវក្នុងនុំងដែរ ដែលមើលមិនដិតដល់ គ្រប់គ្រងមិនដិតដល់ឲ្យ ហ៊ី រត់រួច ។ នេះជាកំហុសធ្ងន់ធ្ងរ ។ ក៏ប៉ុន្តែ កំហុសដែលមានមក បើតាមខ្ញុំចាំមានបីលើក ។ ទីមួយ គឺយើងខ្ញុំនាំគ្នាដើរលេងបីនាក់ទៅក្រៅ ទៅសុំមាន់គេយកមកចិញ្ចឹម អ្នកទោសរត់រួចម្នាក់ ។ ខ្ញុំ ហើយនិងមិត្ត ហ៊ី មេអត់ហ៊ានថា អត់ស្តីឲ្យថាម៉េចមួយម៉ាតទេ ។ ក៏ប៉ុន្តែ ស្បថរៀងខ្លួនអត់ចេញដើរទៅណាយូរពេកទេ ទាំងពីរនាក់ទេ ។

កំហុសលើកទីពីរ អាចារ្យ កង យកកាំភ្លើងបាន ក៏មេមិនស្តីឲ្យ តែយើងខ្ញុំពីរនាក់ប្រឹងរៀងខ្លួនហើយ ធ្វើម៉េចកុំឲ្យកើតបញ្ហានេះទៀត ។ នេះខ្ញុំសូមលើកឧទាហរណ៍អ៊ីចឹង ។ កំហុសបែបនេះ ហ៊ី អត់មាន-- ហ៊ី ក៏មិនបានមេស្តីឲ្យ ហើយខ្ញុំក៏អត់មានប៉ះពាល់ តែកំហុសមួយទៀត ហ៊ី ប៉ះពាល់ ។ កំហុស ហ៊ី ធ្វើឲ្យបែកការណ៍សម្ងាត់នៃចម្លើយ ពេលនុំងមនុស្សកំពុងតែឆ្លើយដាក់ សោ ភឹម ។ បង សោ ភឹម លេខាភូមិភាគបូព៌ានេះ ហ៊ី ធ្វើឲ្យបែកការណ៍ដឹងដល់មេ ។ ខ្ញុំអត់ដឹង ។ មេដឹង មេប្រាប់ថាមិត្តឌុច ឈប់ឲ្យមិត្ត ហ៊ី មើលឯកសារសម្ងាត់ ។ ខ្ញុំឈប់ ។

ដូច្នេះ រឿងប៉ះពាល់ដល់ខ្ញុំមានពេលខ្លះប៉ះពាល់-- មានពេលខ្លះមិនប៉ះពាល់ មេមិនស្តីឲ្យ តែយើងខ្ញុំភ័យ ត្រូវតែខំប្រឹងកុំឲ្យវាមានកំហុសនេះតទៅទៀត ។ ក៏ប៉ុន្តែ រឿងខ្លះប៉ះពាល់ត្រឹមតែ ហ៊ី ទេ ។

**ស៖** លោកបានលើកឡើងនៅថ្ងៃម្សិលមិញ នៅពេលដែលលោកទទួលខុសត្រូវលើស-២១ លោកមានទូរស័ព្ទទាក់ទងជាមួយមេរបស់លោក សុន សេន ។ សំណួររបស់ខ្ញុំនោះគឺថា នៅពេលដែលស-២១ ដំណើរការនៅខែតុលា ឆ្នាំ១៩៧៥ ថាតើ ណាត គាត់ទទួលបានទូរស័ព្ទក្នុងការទាក់ទងជាមួយមេរបស់គាត់ដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ណាត ជាជំនួយការសេនាធិការ ។ ចេញពីខ្ញុំទៅគាត់ទៅគ្រប់គ្រងគមនាគមន៍យោធា ។ គមនាគមន៍យោធានេះ វាជាអ្នកទទួលបញ្ជាពីមេឲ្យផ្តល់ទូរស័ព្ទពិសេសមួយហ្នឹងមកឲ្យខ្ញុំ ។ ក៏ប៉ុន្តែ ខ្លួនវា វាអត់មានអាទូរស័ព្ទពិសេសហ្នឹងប្រើទេ ។ ស្តង់ដារទូរស័ព្ទ

ពិសេសនេះនៅទីតាំងអក្សរ “B” ដែលខ្ញុំចារទុកក្នុងផែនទីភ្នំពេញរបស់ខ្ញុំ ។ ដូច្នេះ ណាត អត់មានទូរស័ព្ទពិសេសហ្នឹងប្រើដូចខ្ញុំទេ ។

ប៉ុន្តែ សូមបន្ថែម គេនៅជាប់ជាមួយនឹងមេ ។ ចេញពីខ្ញុំទៅគេនៅជាមួយនឹងមេ នៅនឹងការិយាល័យ “B”ក្នុងឋានៈជាជំនួយការសេនាធិការ ។

[១០:៣៥:៥៣]

**ស៖** ចំពោះក្រុមខុសៗគ្នា ដែលជាបុគ្គលិកនៅស-២១ នៅពេលចាប់ផ្តើម លោកឆ្លើយប្រាប់លោកចៅក្រមឡាវែន៍ នៅថ្ងៃអង្គារ ថ្ងៃទី២៨ គឺអ្នកដែលមកពីភ្នំពេញ និងមកពី៧០៣ គឺមានការសម្រិតសម្រាំង ហើយលោកបានលើកឡើងថា មានក្រុមមកពីម-១៣ គឺបុគ្គលទាំងឡាយដែលមកពីទីនោះមិនមានការសម្រិតសម្រាំងនោះទេ ។ ដូច្នេះ សំណួររបស់ខ្ញុំនោះគឺថា ដោយសារតែលោកទទួលការការពារពី សុន សេន និង នួន ជា ដែលធ្វើឱ្យលោក និងក្រុមរបស់លោកមកពីទីនោះមិនមានការសម្រិតសម្រាំងនៅស-២១ ឬយ៉ាងម៉េច?

**ឆ៖** លោកប្រធានជាទីគោរព! ខ្ញុំសូមឆ្លើយបញ្ជាក់នឹងសំណួររបស់-- ខ្ញុំសូមបញ្ជាក់ថា បាតុភាពជាក់ស្តែង បុគ្គលិករបស់មន្ទីរ១៣ មកពីអមលាំងអត់មានប៉ះពាល់ទេ ។ ទីពីរ ពួកក្មេងៗដែលយកមកក្រោយពីតំបន់៣១ ក៏អត់ប៉ះពាល់ដែរ ។ ចំណែកពួកកងពលមកពី៧០៣ អ្នកណាដែលជាកូនចៅចាស់របស់មិត្ត ហ៊ី ក៏មិនប៉ះពាល់ដែរ ។ ពីព្រោះក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា កូនវាស្តាប់មេ មេវាយឺតយោងកូន វាការពារកូន ។ នេះវាយឺតយោងគ្នាទៅវិញទៅមកអ៊ីចឹង ។ និយាយយ៉ាងនេះមិនមែនបានន័យថា ខ្ញុំទម្លាក់កំហុសទៅលើអ្នកស្លាប់ ថាមិនគោរព ហ៊ី ។ រឿងពិត គឺសកម្មភាពដែលប្រព្រឹត្តហើយយើងខ្ញុំអប់រំម្តងហើយម្តងទៀតៗ មិនស្តាប់ ។ បក្ស បើសិនជាយើងទុកទៅក៏អាចមិនស្រួលដល់ខ្លួនឯងអាហ្នឹងត្រូវតែរាយការណ៍ទៅខាងលើហើយៗ ។

ខ្ញុំបានលើកឧទាហរណ៍ម្សិលមិញពីរនាក់ គឺមិត្តហាក់ ហើយនិងមិត្ត ភ សួរចម្លើយហើយរឺឱ្យទាល់តែដាច់ចម្លើយអស់ ម្តងហើយម្តងទៀត ។ ដូច្នេះទ្រាំមិនបានខ្ញុំរាយការណ៍ទៅខាងលើ ។ ហើយឱ្យតែខ្ញុំរាយការណ៍ទៅហើយ មានហេតុផលច្បាស់លាស់ហើយ-- ហើយមុននឹងរាយការណ៍ ខ្ញុំសុទ្ធតែគិតដែរ ការដើងអុកខ្លួនឯងដែរ ការដើងព្រួលខ្លួនឯងដែរ កុំឱ្យមេស្តីឱ្យថា ដោយសម្អប់ ដោយចេះតែជឿគេរាយការណ៍ពីក្រោមមិនបានពិនិត្យពិច័យ ខ្ញុំគិតខ្លាចខ្លួនដែរ ។

ហើយសរុបមក ម្សិលមិញខ្ញុំបានរាយការណ៍ជម្រាបលោកចៅក្រមឡាវែន៍ថា ខ្ញុំអត់ដាក់កំហុស

ថាអ្នកដែលស្លាប់ទៅគ្នាសុទ្ធតែខុស បានជាគេកាត់ទោសគ្នាប្រហារជីវិតទេ ។ ខ្ញុំទទួលស្គាល់ថា ខ្ញុំជាលេខា ជាអ្នកអប់រំគេ ខ្វះការពុះពារ ខ្វះការពិនិត្យពិច័យបញ្ហានេះឲ្យហ្មត់ចត់ ។ ដូច្នេះខ្ញុំមានតួនាទីមួយៗក្នុងឧក្រិដ្ឋកម្មទៅលើកូនចៅខ្លួនឯងជាប្រាកដ អត់ប្រកែក ។ ដូច្នេះនិយាយថា ខ្ញុំអា ងសុន សេន ឬខ្ញុំអាង នួន ជា អើយើងមើលពីចម្ងាយទៅ វាឃើញជាហាក់ដូចអ៊ីចឹងមែន ព្រោះប៉ុន្មាននាក់ហ្នឹងគេទុកខ្ញុំដូចភ្នែកគេ គេជឿទុកចិត្តខ្ញុំមែន ។

[១០:៤៣:៥០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់មួយអញ្ជើញចូលវិញ ។ ហើយលោកមេធាវីអាឡាំង វ៉ែនណឺ បើមានសំណួរអ្វីត្រូវសួរបន្ត ចាំពេលចូលត្រឡប់មកវិញសឹមបន្តទៀត ។

*[សវនាការសម្រាកពីម៉ោង ១០:៤៣ នាទី ដល់ម៉ោង ១១:១៥ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ យើងបន្តការពិភាក្សាដេញដោលបន្តទៅទៀត ហើយជាកិច្ចចាប់ផ្តើមបន្តនេះគឺ សូមអញ្ជើញលោកមេធាវី អាឡាំង វ៉ែនណឺ ជាមេធាវីអន្តរជាតិតំណាងឲ្យដើមបណ្តឹងក្រុមមួយឡើងបន្តសំណួរដល់ជនជាប់ចោទ ។ សូមអញ្ជើញមេធាវី ។

**សួរដោយ លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន ។ សហសេវិករបស់ខ្ញុំហើយនិងខ្ញុំខ្លួនឯងផ្ទាល់ បានដាក់នូវសំណួរដល់លោក ហើយមិត្តរបស់ខ្ញុំបានដាក់រួចហើយ ហើយក្នុងនាមយើងជាក្រុមទីមួយហ្នឹង គឺថាយើងបានសួរលោកមុនក្រុមដទៃ ។ អ៊ីចឹង ដើម្បីកុំឲ្យខាតពេលសម្រាប់ដល់ក្រុមដទៃទៀត ខ្ញុំនឹងព្យាយាមធ្វើសំណួរហ្នឹងឲ្យបានខ្លីទៅតាមការដែលអាចធ្វើបាន ។ ហើយខ្ញុំក៏សូមឲ្យលោកធ្វើការឆ្លើយតបយ៉ាងខ្លីដែរទៅនឹងសំណួរដែលខ្ញុំនឹងសួរនោះ ។

ខ្ញុំមានសំណួរមួយទៀតទាក់ទងទៅនឹងបច្ចេកទេសនៃការសួរ ។ កាលពីថ្ងៃ២៧ សប្តាហ៍មុនលោកបានបង្ហាញថា កាលពីឆ្នាំ៧៥ លោកបានបង្រៀនអ្នកយាមនៅស-២១ ឲ្យធ្វើការសួរចម្លើយហើយថ្ងៃនេះ ទី ស្រ៊ីនណា បានសួរលោក ហើយលោកបាននិយាយថា គឺថាមានកើតឡើងកាលពីជំនាន់លោក

ណាត ម្ល៉េះទាក់ទងទៅនឹងបច្ចេកទេសនៃសួរចម្លើយនោះ ។ អ៊ីចឹងខ្ញុំសូមអានឲ្យលោកស្តាប់ ។ នេះជាសំណួរចម្លើយដែលលោកបានផ្តល់កាលពីថ្ងៃ២៨ ខែមេសា ។ លោកប្រធាន នេះគឺជាចម្លើយទាក់ទងទៅនឹង ម-១៣ ។ ខ្ញុំយល់ថា វាជាអត្ថប្រយោជន៍ណាស់សម្រាប់ខ្ញុំក្នុងការប្រើ ដើម្បីឲ្យខ្ញុំសួរសំណួរទៅជនជាប់ចោទ អំពីអ្វីដែលយើងបាននិយាយនៅថ្ងៃនេះ ទាក់ទងទៅនឹងបច្ចេកទេសសួរចម្លើយនៅម-១៣ នោះ លោកបាននិយាយថា នេះគឺជាកំណត់ត្រាប្រតិចារឹកនៃការពិភាក្សាកាលពីថ្ងៃទី៧ ខែមេសា នៅទំព័រទី៦៨ លោកបាននិយាយថា៖ ខ្ញុំគួរតែធ្វើការចងអ្នកទោសហ្នឹង ទៅនឹងបង្គោល ដើម្បីឲ្យដឹងថាគេឆ្លើយ ឬមិនឆ្លើយ បើសិនមិនឆ្លើយទេហ្នឹង គឺថាយើងនឹងធ្វើការវ៉ៃអ្នកទោសនោះ ។ អ៊ីចឹងជាទម្លាប់នោះ បច្ចេកទេសនៃការធ្វើទារុណកម្មនោះត្រូវបានធ្វើ ឬក៏ធ្វើឲ្យបានប្រសើរឡើងដោយខ្លួនខ្ញុំផ្ទាល់ ។ ដូចដែលខ្ញុំបានប្រាប់លោកចៅក្រម ឡាវែន៍ កាលពីម្សិលមិញអ៊ីចឹង គឺថាខ្ញុំមិនធ្វើការជាមួយនឹងខាងកិច្ចការប៉ូលិសហ្នឹងទេ ប៉ុន្តែលោក ឆាយ គឹមហ៊ៃ បាននិយាយថា បច្ចេកទេសធ្វើទារុណកម្មនោះ គឺជាកិច្ចការសម្ងាត់ ។ ហើយប្រសិនបើយើងព្យាយាមការពារតំបន់រំដោះនោះ យើងត្រូវប្រើបច្ចេកទេសនោះ ។ បច្ចេកទេសនោះ គឺមិនមានណែនាំពីខាងលើទេ ប៉ុន្តែគឺថាខ្ញុំផ្ទាល់ជាអ្នកបង្កើតនូវបច្ចេកទេសនេះហើយក៏ខ្ញុំព្រមទទួលយកនូវប្រភេទ ។ ខ្ញុំជាអ្នកទទួលខុសត្រូវចំពោះប្រភេទនៃឧក្រិដ្ឋកម្មដ៏ឃោរឃៅបែបនេះដែរ ។ នេះគឺជាអ្វីដែលមាននៅក្នុងប្រតិចារឹក ដែលលោកបាននិយាយកាលពីពីរអាទិត្យ ។ លោកបាននិយាយថា លោកគឺជាអ្នកបង្កើតបច្ចេកទេសសួរចម្លើយ និងធ្វើទារុណកម្មនៅម-១៣ ហើយនេះជាសំណួររបស់ខ្ញុំ ។

**ស៖** ដូច្នេះតើជាការពិតទេ នៅពេលដែលលោកនិយាយជាមួយ ណាត គឺមុនការបង្កើត ស-២១ នោះ ណាត ហ្នឹង គឺពឹងផ្អែកទៅលើលោកក្នុងប្រើបច្ចេកទេសសួរចម្លើយនេះ ពីព្រោះគឺលោក ការពិតជាអ្នកដែលបានបង្កើតនូវបច្ចេកទេសអស់ទាំងនេះ តាំងពីនៅម-១៣ ម្ល៉េះ?

**ឆ៖** លោកប្រធានជាទីគោរព ខ្ញុំសូមឆ្លើយនឹងសំណួររបស់លោក វ៉ែនណឺ ដូចតទៅ៖

ទីមួយ សូមញែកបញ្ហាជាពីរដាច់ពីគ្នាស្រឡះ។ បច្ចេកទេសធ្វើទារុណកម្ម ដាច់ពីបច្ចេកទេសសួរចម្លើយ ។ បញ្ហាសួរចម្លើយមិនមានអ្នកណាល្ងង់សោះនោះទេ នេះជាការពិត ។ បញ្ហាមួយទៀត ណាតនេះចូលចិត្តការងារនគរបាលខ្លាំងណាស់ ទោះបីគាត់ធ្វើជាប្រធានវរសេនាតូចក៏ដោយ ក៏អង្គាល់នៅតំបន់៣៣ គាត់ក៏ដើរតួជាអ្នកចាប់ចង ។ គ្រូអាបធ្មប់ យកមកសួរចម្លើយខ្លួនឯងដែរ នេះអង្គាល់នៅតំបន់៣៣ ខ្ញុំសូមរំឭកប្រវត្តិនេះ ប៉ុន្តែវាអត់មានឯកសារនៅសល់ទេ ។

សរុបមក គាត់មិនមានពិសោធន៍ដូចខ្ញុំពិតមែនក្នុងរឿងសួរចម្លើយ ក៏ប៉ុន្តែ មេហើយនិងកូនហើយមានប្រវត្តិជាប់គ្នាពីដើមមក វាពិតជាមានការពិគ្រោះគ្នាខ្លះ ប៉ុន្តែ អ្នកដែលដើរតួក្នុងបង្រៀន គឺខ្ញុំមិនមែនគាត់ទេ ខ្ញុំជាអ្នកបង្រៀនរបៀបសួរចម្លើយ ។ អាហ្នឹងសូមបញ្ចប់ប៉ុណ្ណេះ ។

[១១:២១:៤៥]

**ស៖** សូមអរគុណចំពោះការឆ្លើយដ៏ច្បាស់លាស់របស់លោក ។ នៅថ្ងៃទី២២ ខែមេសា ក្នុងការឆ្លើយតបទៅនឹងសំណួររបស់លោកចៅក្រម យ៉ា សុខន លោកបានលើកឡើងថា នៅពេលដែលលោកបង្រៀនអ្នកយាមនៅស-២១ ហើយលោករៀបចំរបាយការណ៍សម្រាប់មេរបស់លោក ហើយរបាយ-ការណ៍ទាំងអស់នោះ គឺវាទាក់ទងទៅនឹងជនក្បត់ ។ ដោយមានការអនុញ្ញាតលោក លោកស្រីចៅក្រម ខ្ញុំចង់អានអត្ថបទនេះជាភាសាអង់គ្លេស ដោយសារតែ-- ខ្ញុំចង់អានជាភាសាអង់គ្លេស ហើយវាមានតែមួយឃ្លាទេនៅក្នុងភាសាអង់គ្លេសនេះ ដើម្បីឲ្យជ្រាបជាព័ត៌មាន ។ នេះគឺចេញពីប្រតិចារឹក នៅថ្ងៃទី២២ ខែមេសា ទំព័រទី៨៥ ជាភាសាអង់គ្លេស "ដូច្នេះមនុស្សដែលសួរចម្លើយ ហើយខ្ញុំរៀបចំរបាយការណ៍ទៅមេរបស់ខ្ញុំ ទាក់ទងទៅនឹងខ្សែក្បត់" ។

ដូច្នេះខ្ញុំសូមបន្ត ដើម្បីជៀសវាងការលើកឡើងទៅលើអត្ថបទនេះទៀត គឺខ្ញុំសូមលើកសំណួរថា តើត្រឹមត្រូវដែរឬទេ ដែលលោករៀបចំរបាយការណ៍សម្រាប់ថ្នាក់លើរបស់លោក ទាក់ទងទៅនឹងខ្សែក្បត់?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធានៗ ខ្ញុំសូមឆ្លើយបញ្ជាក់នឹងសំណួររបស់លោក វ៉ែនណឺ ដូចតទៅ៖ ការងាររបស់ខ្ញុំកាលនៅអនុប្រធាន ហើយនិងចាប់កកើតស-២១ ដំបូង ខ្ញុំមានភារកិច្ចច្រើន ។ ភារកិច្ចទីមួយ រៀបចំឯកសារដែលប្រមូលបានមកទុកដាក់ឲ្យបានស្រួលបួល ។ ខ្ញុំសូមបញ្ជាក់កន្លែងហ្នឹងមិនសូវត្រូវទេ ខ្ញុំសូមបញ្ជាក់ឡើងវិញណ៎ា ទីមួយ គឺរៀបចំទុកដាក់ឯកសារ ដែលប្រមូលបានពីក្រោមកពីផ្ទះអ្នកធំ និងពីស្ថាប័នរដ្ឋរបស់លន់ នល់ នុំង ។ ហើយទីពីរ ដកស្រង់ចំណុចខ្លះដែលចំបាច់រាយការណ៍ទៅលើ ។ ហើយទីបី នៅពេលដែលចាប់ផ្តើមចាប់ដៃគ្នាដំបូងនេះ ខ្ញុំបង្រៀនពួកអ្នកសួរចម្លើយ ។ ទីបួន រាយការណ៍សេចក្តីសារភាពរបស់ជនរងគ្រោះទៅលើ ។

នេះសរុបមក តួនាទីរបស់ខ្ញុំសំខាន់ៗនៅពេលដែលចាប់ផ្តើមកកើតស-២១ ។ សរុបសូមនិយាយថា បង្រៀនសួរចម្លើយ ជាភារកិច្ចមួយរបស់ខ្ញុំ ។ ភារកិច្ចទីពីរ របស់ខ្ញុំគឺរាយការណ៍សេចក្តីសារភាពទៅលើ ។ ដូច្នេះ សំណួររបស់លោក វ៉ែនណឺ ចំពោះរូបខ្ញុំត្រឹមត្រូវ ។

**ស៖** ដើម្បីបញ្ជាក់ឱ្យបានច្បាស់ទៅលើចំណុចនេះ ចំពោះភារកិច្ចរបស់លោក ដែលមានការរៀបចំរបាយការណ៍ ។ នៅពេលនោះគឺ លោករៀបចំរបាយការណ៍ស្តីពីខ្សែក្បត់ ថាតើខ្ញុំយល់ត្រឹមត្រូវដែរឬទេ?

**ឆ៖** លោកចៅក្រមទីគោរព! ខ្ញុំសូមបញ្ជាក់ជូនលោក វ៉ែនណឺ បន្តិច ។ រាយការណ៍សេចក្តីសារភាពទៅលើ គឺរាយការណ៍អំពីខ្សែក្បត់ហ្នឹងឯង ។ រាយការណ៍ទៅលើ តាមសេចក្តីសារភាពអំពីខ្សែក្បត់ដែលបារាំងគេហៅថា រ៉េហ្សូ នុំង ។

**ស៖** ឌុច ថាតើនរណាគេជាអ្នកឱ្យលោកសរសេររបាយការណ៍ឡើងទៅលើ?

**ឆ៖** សំណួររបស់លោកដាច់មួយកំណាត់ ស្តាប់អត់បានទេណា? លោក វ៉ែនណឺ សំណួររបស់លោកដាច់មួយកំណាត់ ខ្ញុំស្តាប់អត់បានទេ?

[១១:២៨:០៩]

**ស៖** ថាតើបុគ្គលណាដែលបង្គាប់លោក ឬក៏ឱ្យលោកសរសេររបាយការណ៍នេះបញ្ជូនទៅលើ?

**ឆ៖** សូមបញ្ជាក់ជូនលោក វ៉ែនណឺ ដូចតទៅ៖

សេចក្តីរាយការណ៍ដែលខ្ញុំជូនទៅលើមិនមែនតែមួយទេ ដូច្នេះអត់មាន *រ៉ាប់ព័រ ប្រេស៊ី* ឯណាទេ ។ ខ្ញុំរាយការណ៍ តាមពិតរឿងទៅលើទាំងប៉ុន្មាន ខ្ញុំរាយការណ៍តាំងពីខ្ញុំនៅជាអនុប្រធានម្ល៉េះ គ្រាន់តែពេលខ្ញុំនៅជាអនុប្រធាន ខ្ញុំរាយការណ៍ជូនទៅមេ ។ គ្រាន់តែដែលខ្ញុំនៅជាអនុប្រធាន ខ្ញុំរាយការណ៍ជូនមេ គឺលោកគ្រូ សុន សេន នៅនឹងមុខ ណាត ដែលជាប្រធានចំពោះមុខរបស់ខ្ញុំហ្នឹង ។

**ស៖** របាយការណ៍ដែលលោកនិយាយអំពីនោះ គឺខ្ញុំមានការបកប្រែនៅក្នុងកាសរបស់ខ្ញុំ គឺខ្សែក្បត់ ។ តើមានបុគ្គលណាស្នើសុំឱ្យលោកធ្វើរបាយការណ៍នេះទៅលើដែរឬទេ? ឬក៏លោកសរសេរដោយខ្លួនឯង?

**ឆ៖** លោក វ៉ែនណឺ សូមលោកបញ្ជាក់ជូនអង្គសវនាការទាំងមូលទៅ តើ*រ៉ាព័រ*ណាមួយដែលលោកចង់ឱ្យខ្ញុំបញ្ជាក់នោះ? បើលោកចង់ឱ្យខ្ញុំបញ្ជាក់ អំពីថា*រ៉ាព័រ* ណាមួយជាចំពោះ ជាច្បាស់ សូមលោកបង្ហាញឱ្យៗអង្គសវនាការឃើញ ។

**ស៖** ខ្ញុំជឿថា ខ្ញុំមិនសូវយល់ចំពោះអ្វីដែលជនជាប់ចោទបានលើកឡើង ។ នៅពេលនោះ ខ្ញុំលើកឡើងសាជាថ្មី នៅពេលដែលលោកបង្រៀនអ្នកសួរចម្លើយនៅស-២១ គឺនៅក្នុងឆ្នាំ១៩៧៥ ។ នៅក្នុងឆ្នាំ១៩៧៥ តើលោកបានសរសេររាយការណ៍ណាមួយជាក់លាក់ស្តីអំពីខ្សែក្បត់ដែរឬទេ? ខ្ញុំយល់ថាបន្ទាប់

ពីពេលនោះមក នៅក្នុងដំណើរការស-២១ លោកបានសរសេររាយការណ៍ទៅលើចម្លើយសារភាព ។ ប៉ុន្តែខ្ញុំចង់សួរនៅពេលលោកបង្រៀនអ្នកសួរចម្លើយ នៅពេលនោះ ថាតើលោកបានសរសេរ ឬក៏ធ្វើរាយការណ៍ជាក់លាក់ណាមួយស្តីអំពីខ្សែក្បត់ដែរឬទេ?

**ឆ៖** នៅពេលខ្ញុំធ្វើអនុប្រធានគេ ធម្មតាយើងធ្វើរង តែកាលណាមេគេប្រើ យើងធ្វើហើយ ។ (សុំទោស)មិនមែនទេខ្ញុំ-- សុំទោសណ៎ា មេដែលខ្ញុំលើកក្រោយនេះ មួយម៉ាត់ចុងក្រោយនេះគឺសំដៅណាត ទេ មិនមែនសំដៅដល់ខាងលើ លោកគ្រូ សុន សេន ទេ ។ យើងធ្វើ-- ខ្ញុំសូមបញ្ជាក់ណ៎ា អាសម្តីមួយម៉ាត់ដែលខ្ញុំនិយាយចុងក្រោយ ដូច្នេះ ក្នុងឋានៈយើងជាអនុប្រធាន បើកាលណាប្រធានគេប្រើ យើងត្រូវតែធ្វើ ។

**ស៖** សូមអភ័យទោស ក្នុងការកាត់សម្តីរបស់លោក ប៉ុន្តែខ្ញុំចង់ចូលទៅដល់សំណួរមួយទៀត ។

**ឆ៖** បើគេប្រើឲ្យយើងធ្វើ យើងត្រូវតែធ្វើ គេមិន *ឌីកតេ* ឲ្យយើងទេៗ គេឲ្យគោលគំនិតមក យើងធ្វើ យើងធ្វើ ។

**ស៖** សំណួររបស់ខ្ញុំបន្ទាប់ទៀត ក្នុងពេលសវនាការលោកបានជម្រាបអំពីគោលគំនិតមួយចំនួនលើកឡើងដោយខ្លួនឯង ហើយនៅក្នុងសវនាការមុន គឺទាក់ទងទៅនឹងក្រុមសួរដែលជាស្ត្រី ហើយម្សិលមិញថ្ងៃអង្គារ លោកនិយាយអំពីគំនិតផ្តួចផ្តើមក្នុងការផ្លាស់ទីតាំងស-២១ ពីចំណុច “ក” ទៅចំណុច “ខ” ហើយផ្លាស់ប្តូរទីតាំងសម្លាប់ទៅជើងឯក ហើយបង្កើតបន្ទប់នៅស-២១ ស្នើសុំ សុន សេន ឲ្យយកកូនក្មេងៗតូច ដែលមានសមាសភាពល្អ និងជីវប្រវត្តិល្អ ហើយទាំងអស់នេះគឺជាគោលគំនិតផ្តើមរបស់លោក ហើយគ្មានបុគ្គលណាដែលបង្គាប់លោកទេ ហើយលោកជាអ្នកសម្រេចធ្វើទៅលើករណីនេះ ។

ហើយសំណួររបស់ខ្ញុំ អ៊ីចឹងប្រសិនបើលោកមិនពេញចិត្តនូវអ្វីដែលលោកធ្វើនៅស-២១ ហើយលោកចង់ធ្វើអ្វីផ្សេង ហេតុអ្វីនៅពេលនោះលោកបង្កើតជាគំនិតផ្តួចផ្តើមច្រើនដូច្នោះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន សំណួររបស់ អាឡាំង វ៉ែនណឺ ច្របូកច្របល់ណាស់ គិតមិនយល់ ហើយដល់ចុងបញ្ចប់ចង់ប្រទាញទម្លាក់ថា ខ្ញុំប្រកាសថា អត់ចង់ធ្វើការងារនគរបាលទេ ម៉េចក៏មានគំនិតផ្តើមច្រើនម្ល៉េះ? ឥឡូវ សូមលោកទុកអាភស្តុតាងទាំងប៉ុន្មានដែលលោកពន្យល់មកនុំងវាច្របូលច្របល់ហើយ ។ ខ្ញុំសូមនិយាយ “មែន! ខ្ញុំពិតជាមិនចង់ធ្វើ” ប៉ុន្តែឲ្យខ្ញុំប៉ានតវ៉ាប្រកាសជាជំហរថា ខ្ញុំស្អប់ការងារនគរបាលបែបនេះណាស់ ខ្ញុំអត់ប៉ានទេ ។ នេះគេមិនមែនហៅថា យើងស្មោះត្រង់រាយការណ៍ជូនខាងលើទេ គេហៅថាវាយប្រហាររបបបក្សកុម្មុនីស្តកម្ពុជាដែលយើងកំពុងតែរស់

នៅជាមួយហ្នឹង ។ ហើយបើសិនជាយើង គេដាក់ភារកិច្ចឲ្យមក យើងត្រូវតែធ្វើការងារណាដែលយើងមិនបានធ្វើ ត្រូវប្រាប់គេថាខ្ញុំអត់បានធ្វើទេ ។ ដូច្នេះ ការងារណាមួយចំនួនដែលគេយល់ថា យើងបានធ្វើ ហើយយើងក៏ជឿថាខ្លួនយើងធ្វើកើត យើងត្រូវតែធ្វើៗ ។ វាគ្រាន់តែភស្តុតាងដែលលោកលើកឡើងមកហ្នឹង សូមរៀបចំឲ្យទៅតាមលំដាប់កាលវេលា អត់ទេ វានៅស្ថិតនៅក្នុងក្របខ័ណ្ឌនៃសេចក្តីបញ្ជាក់ហ្នឹង ។

**ប្រធានអង្គជំនុំ៖**

រំឭកលោកមេធាវីផងដែរ ការកត់សម្គាល់របស់អង្គជំនុំជម្រះឃើញថា ភាគីដែលមានសិទ្ធិតាំងក្នុងសំណួរដល់ជនជាប់ចោទ ឃើញថាតែងតែបញ្ជាក់ឲ្យជនជាប់ចោទហ្នឹងឆ្លើយឲ្យបានខ្លី ប៉ុន្តែរបៀបតាំងសំណួររបស់អ្នកដែលសួរវិញ គឺតែងតែអូសបន្លាយវែងអន្លាយ មុននឹងសួរនោះ ធ្វើឲ្យជនជាប់ចោទដែលត្រូវប្រឈមនឹងការទទួលរងនូវសំណួរពីភាគីជាច្រើននោះ កាន់តែមានបញ្ហាទៀត អ៊ីចឹងសូមមានការប្រយ័ត្នប្រយែង ហើយប្រឹងប្រែងរៀបចំសំណួរឲ្យបានជាក់លាក់ ឲ្យបានច្បាស់លាស់ ដើម្បីស្តាប់យល់ ហើយឆ្លើយចំបញ្ហា ។

[១១:៣៩:២៩]

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

ហើយខ្ញុំនឹងព្យាយាម ធ្វើដូច្នេះតាមសេចក្តីបង្គាប់របស់លោកប្រធាន ។

**ស៖** លោកជនជាប់ចោទ បន្ទាប់ពីលោកត្រូវបានតែងតាំងជាអនុប្រធាននៅស-២១ នៅឆ្នាំ១៩៧៥ លោកបាននាំយកអតីតបុគ្គលិកពីម-១៣ មកធ្វើការនៅ ស-២១ ។ ហើយនៅខែមេសា គឺលោកគឺជាអ្នកទៅរកមនុស្សមកពីអមលាំង ហើយលោកក៏បានលើកឡើងផងដែរថា មេរបស់លោកគឺស្នើឲ្យលោកទៅរកមនុស្សមកពីម-១៣ តើអ្វីទាំងអស់នេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រូវហើយ កម្លាំងដែលនៅមន្ទីរ១៣ គឺ មិត្តមាស គាត់ជាអ្នកទៅនាំមក ។ នេះពិត ។

**ស៖** តើលោកខ្លួនឯងផ្ទាល់ហ្នឹងបានស្នើទៅមេរបស់លោក ដើម្បីទៅរកមើលអតីតជាអ្នកយាមដើម្បីឲ្យពួកគេមកធ្វើការនៅស-២១ នោះឬ?

**ឆ៖** វ៉ែនណឺ សំណួរលោកដាច់មួយកំណាត់ទៀតហើយ ។ សូមមេត្តា អានសំណួរលោកឡើងវិញ ។

**ស៖** ពិតហើយ ខ្ញុំអាចអាន ។ តើលោកខ្លួនឯងផ្ទាល់មានបានស្នើ ឬក៏ធ្វើសំណូមពរទៅមេរបស់លោក គឺលោក មាស ដើម្បីទៅរកមើលមនុស្សអស់ទាំងនោះនៅម-១៣ ដើម្បីពួកគេអាចមកធ្វើជាមួយលោកនៅក្រោយនៅស-២១ នោះ?

**ឆ៖** នៅពេលដែលកកើតស-២១ ឧទ្ទេសនាមឲ្យកកើត ស-២១ នៅថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៥ នុំង មេប្រាប់ខ្ញុំថា មិត្តឯងឲ្យគេនាំកម្លាំងពីអមលាំងឲ្យមកចូលភ្នំពេញមក ។ អានេះវាជាបញ្ជា ខ្ញុំអនុវត្ត ។

**ស៖** នេះជាសំណួរយ៉ាងសាមញ្ញបំផុត ។ គឺនេះជាបញ្ជាដែលបានទទួល ។ តើលោកមានបានធ្វើការពិភាក្សាជាមុនទេជាមួយនឹងមេរបស់លោក? ឬក៏ដែលលោកបានស្នើដើម្បីឲ្យធ្វើដូច្នេះ?

**ឆ៖** លោក វ៉ែនណឺ កម្លាំងខ្ញុំនៅអមលាំង មេដឹង។ ដូច្នេះ នៅពេលដែលគាត់សម្រេចបង្កបង្កើត ស-២១ នេះ គាត់ប្រាប់ភ្លាម មិត្តឌុច មិត្តឯងឲ្យគេទៅនាំកម្លាំងវានោះ យកមកចូលភ្នំពេញមក ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណ លោកបានឆ្លើយនឹងសំណួររបស់ខ្ញុំហើយ ។ លោកប្រធានគឺថាខ្ញុំមានចំណុចពីរទៀតទេ ដែលខ្ញុំចង់លើកឡើង ហើយប្រហែលជាមិនហួសពីប្រាំនាទីទេ បើសិនជាលោកប្រធានអនុញ្ញាត ។

[១១:៤៣:៥៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

ព្យាយាមធ្វើម៉េចឲ្យបានខ្លី ព្រោះដូចជាចំណាយពេលច្រើន លើសពីអ្វីដែលលោកប៉ុនប៉ងនិយាយតែដំបូងថា២៥មីនុតទេនែ៎ ឥឡូវហ្នឹងឃើញមានចំណាយពេលវេលាច្រើន បើភាគីផ្សេងទៀតចំណាយពេលវេលាដូចនេះ ការដែលនិយាយថា ចំណាយពេលវេលាខ្លីនុំង វាផ្ទុយជាមួយនឹងសកម្មភាពជាក់ស្តែងទង្វើដែលបានប្រព្រឹត្ត ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

បាទ, ខ្ញុំយល់ច្បាស់ណាស់ លោកប្រធាន សូមអរគុណ ។

**ស៖** លោកជនជាប់ចោទ កាលពីខែ៤ ថ្ងៃទី២៣ លោកបានបញ្ជាក់ថា បើទាក់ទងទៅនឹង ស-២១ និងមណ្ឌលសន្តិសុខដទៃទៀត លោកបានពន្យល់យ៉ាងច្បាស់ថា គឺថាមិនមានខ្សែបណ្តោយនៃ

ការទាក់ទងគ្នាទេ ។ តើលោកទទួលស្គាល់នូវការពិតទេដែរថា មន្ទីរស-២១ គឺមិនមែននៅត្រឹមកម្រិតដូចគ្នានៃមន្ទីរសន្ដិសុខដទៃទៀតទេ ពីព្រោះស-២១នេះ បានទទួលកម្មាភិបាលពីគណៈមជ្ឈិមដែលគណៈអចិន្ត្រៃយ៍បានសម្រេចធ្វើការចាប់នោះ ។ តើនេះជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំសូមអនុញ្ញាតបញ្ជាក់សាជាថ្មីម្តងទៀតជូនលោក វ៉ែនណឺ ថា ស-២១ មិនដែលបានទាក់ទងតាមខ្សែទទឹងទៅមន្ទីរនគរបាលណាមួយទេ ទាល់តែសោះ ។ ឯចំណែក ដែលមនុស្សស-២១ ទទួល គឺសុទ្ធតែជាមនុស្សដែលអចិន្ត្រៃយ៍មជ្ឈិមបក្សប្រគល់មកឲ្យស-២១ តាមរយៈខ្ញុំ ។

**ស៖** អ៊ីចឹង តើលោកព្រមទទួលថាអ្វីដែលលោកនិយាយហ្នឹង គឺធ្វើឲ្យមន្ទីរស-២១ ហ្នឹង វាមានលក្ខណៈពិសេសដោយឡែក ប្លែកជាងមន្ទីរសន្ដិសុខផ្សេងៗនៅតាមខេត្តនានានោះ?

**ឆ៖** ឥឡូវយើងនិយាយថាពាក្យ "អ៊ុយនិក" តើអ៊ុយនិកក្នុងន័យអី? បើសិនជាយើងលើកយកឯកសារសេចក្ដីសម្រេចចិត្តមួយចំនួនរបស់មជ្ឈិមបក្សមកពិនិត្យ យើងឃើញថា ស-២១ មិនមែនជាមន្ទីរនគរបាល "អ៊ុយនិក" ទេ ពីព្រោះអ្នកដែលមានសិទ្ធិបញ្ជាទៅលើមន្ទីរនគរបាលទូទាំងប្រទេស គឺពួកមនុស្សបួនក្រុម ។ ក្រុមទីមួយ លេខាភាគ ភាគទាំងអស់មានប្រាំពីរ ដូច្នេះមានប្រាំពីរនាក់ ។ ពួកទីពីរ ក្រុមទីពីរគឺលេខា ឬក៏ប្រធានគណៈកម្មាធិការមន្ទីរ៨៧០ ។ ហើយក្រុមទីបី អចិន្ត្រៃយ៍មជ្ឈិម ។ ហើយក្រុមទីបួន គឺសេនាធិការ នាយសេនាធិការគឺ សុន សេន ។

សរុបមក បើសិនជាយើងឈរលើមូលដ្ឋានឯកសារនេះ អាមនុស្សណាម្នាក់ក្នុងចំណោមអាៗបួនក្រុមហ្នឹង វាបញ្ជាហើយ មន្ទីរនគរបាលទាំងអស់ក្នុងស្រុកខ្មែរត្រូវតែគោរពវា ។ អាហ្នឹងវាឲ្យអ្នកណារស់បាន វាឲ្យអ្នកណាស្លាប់បាន ទៅតាមផលប្រយោជន៍នយោបាយរបស់ពួកវា ។ គឺពួកអាបួនក្រុមនេះហើយដែលគេហៅថា "អ្នកទទួលខុសត្រូវ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម" តាមច្បាប់កម្ពុជា ។ សុំៗបញ្ជាក់ទៀតៗបកប្រែនឹងអត់ទាន់ចំន័យរបស់ពាក្យខ្ញុំទេ ។ គឺពួកអាបួនក្រុមហ្នឹងហើយ ដែលគេហៅថា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម" ទៅតាមច្បាប់កម្ពុជា ។ សរុបមកវិញ ខ្ញុំសូមបញ្ជាក់ថា បើយកមាត៌ាៗដែលកំណត់ដោយ ប៉ុល ពត នៅថ្ងៃ៣០ មីនា មកនិយាយ ស-២១ មិនមែន "អ៊ុយនិក" ទេ ។ ខ្ញុំសូមប្រើពាក្យបារាំងថា ស-២១ មិនមែនអ៊ុយនិកទេ ហើយបើអ្នកឯងយកពាក្យថា អ៊ូ! បើអ្នកឯងយកពាក្យថា "ស-២១ សម្លាប់សុទ្ធតែកម្មាភិបាលមជ្ឈិម" ។ កម្មាភិបាលមជ្ឈិមៗដែល-- ខ្ញុំបានបញ្ជាក់ជូនអង្គសវនាការម្សិលមិញហើយថា កាលដែលស-២១ កម្ទេចកម្មាភិបាលមជ្ឈិមមិនមែនជាគុណសម្បត្តិដែលស-២១ ដោះទុក្ខប្រជាជន

កម្ពុជាទេ គឺជាបញ្ហា “ពាលស៊ីពាល” នៅក្នុងមជ្ឈិមបក្សខ្លួនឯងហ្នឹង “ពាលស៊ីពាល” ។ ដូច្នេះបើយើងកុំយកគោលការណ៍ហ្នឹងមកចាត់ទុកស-២១ ជាៗអ៊ុយនិក ដោយសារសម្លាប់កម្មាភិបាលមជ្ឈិម ។ អាហ្នឹងខ្ញុំសូមបន្តតិចទៅទៀតចុះ បើសិនជាយើងឲ្យៗតម្លៃតែជិវិតកម្មាភិបាលមជ្ឈិមម្នាក់ ស្មើនឹងប្រជាជនសាមញ្ញ៥០០នាក់ៗ ។ ឥឡូវខ្ញុំសុំសួរថា បញ្ញាជនដែលស្លូតត្រង់ តើយើងទុកជាស្អី គេអត់មានបាតដៃប្រឡាក់ឈាមប្រជាជនកម្ពុជាផង ។ ដូច្នេះ លោក វ៉ែនណឺ ខ្ញុំសូមបញ្ចប់ចម្លើយខ្ញុំ ។ ស-២១ ជាអ៊ុយនិក ដោយសារមូលហេតុខ្ញុំសម្លាប់កម្មាភិបាលមជ្ឈិម ។

[១១:៥៤:០៥]

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទនិយាយឃ្លាចុងក្រោយនេះម្តងទៀត ពីព្រោះដាច់អត់មានឮសំឡេងទាំងស្រុងទេ។ និយាយអាឃ្លាមិញចុងក្រោយនេះម្តងទៀត ដើម្បីធ្វើការបកប្រែ ហើយនិងប្រតិចារឹក ។

**ជនជាប់ចោទ៖**

នៅចុងបញ្ចប់នេះ លោក វ៉ែនណឺ ខ្ញុំសូមលោកកុំចាត់ទុកស-២១ ថា “អ៊ុយនិក” ដោយសារកម្មាភិបាលមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាទាំងប៉ុន្មានមកស្លាប់នៅស-២១ ។

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធាន ខ្ញុំមានសំណួរចុងក្រោយ ។ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

លោក វ៉ែនណឺ សួរឲ្យចប់ទៅ ហើយបើមានបញ្ហាអីសឹមលោកសហព្រះរាជអាជ្ញាមានយោបល់ជាក្រោយ ។ លោក វ៉ែនណឺ អនុញ្ញាតឲ្យចុងក្រោយ ព្រោះម៉ោងអស់ហើយ ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

**ស៖** សូមអរគុណលោកប្រធាន ។ កាលពីថ្ងៃព្រហស្បត៍មុនលោកបានបញ្ជាក់ច្បាស់ថា នៅពេលដែលលោកទទួលបន្ទុកនៅស-២១នេះ គឺថាលោកបានដឹងថាមន្ទីរសន្តិសុខតែពីរទៀតទេ នៅក្នុងប្រទេសនោះ គឺមួយនៅកំពង់ធំនិងមួយទៀតគឺមន្ទីរសន្តិសុខ៩៩ ឬក៏ម-៩៩ នៅតំបន់៣២ ហើយលោកបាននិយាយថា សុន សេន បានស្នើឲ្យលោកធ្វើអ្វីមួយទាក់ទងទៅនឹងមន្ទីរសន្តិសុខនោះ អ៊ីចឹងហើយបានជាលោកកន្លែងនោះ ។ អ៊ីចឹងសំណួររបស់ខ្ញុំ គឺថាចន្លោះពីឆ្នាំ៧៥ ដល់ ៧៩ ហ្នឹងគឺថា លោកមិនបានដឹងថា មានមន្ទីរសន្តិសុខនៅសៀមរាប នៅក្នុងអតីតពន្ធនាគារនោះ ដែលជាមន្ទីរសន្តិសុខដ៏ធំជាងគេ

នៅប៉ែកខាងជើងនោះ ដែលដឹកនាំដោយ តាយ ហុក*(ស៊ិក,កែ ពក)* ឬក៏គ្រប់គ្រងដោយ តាយ ហុក *(ស៊ិក)* នោះ ។ អ៊ីចឹងតើលោកមិនបានដឹងពីមន្ទីរសន្តិសុខដ៏ធំនៅសៀមរាបនេះទេឬ?

[១១:៥៦:៥៥]

**ឆ៖** ខ្ញុំចាំអាពីរនេះច្បាស់ព្រោះខ្ញុំ-- ខ្ញុំចាំអាពីរនេះច្បាស់ ព្រោះទីមួយខ្ញុំឃើញនឹងភ្នែកនគរបាលតំបន់កំពង់ធំ ព្រោះហើយទីពីរអាម-៩៩ នេះ ខ្ញុំបានបញ្ជូនមនុស្សទៅតាមបញ្ជាមេ ។ ចាប់តាំងពីធ្វើការងារៗមក ខ្ញុំសូមចែកបញ្ហាជាពីរ ។ ទីមួយ *ដេឌុចស្មុង* របស់ខ្ញុំ សេចក្តីសន្និដ្ឋានរបស់ខ្ញុំៗ ខ្ញុំគិតថាទូទាំងប្រទេសមាននគរបាលគ្រប់ភូមិភាគ មានមន្ទីរនគរបាលគ្រប់ភូមិភាគ មានមន្ទីរនគរបាលគ្រប់តំបន់ មាននគរបាលគ្រប់ស្រុក ។ ខ្ញុំជឿថាសម្តីនេះ ខ្ញុះបានរាយការណ៍ជូនលោកចៅក្រមស៊ើបអង្កេត ។ បន្ទាប់មកទៀត ក្នុងការធ្វើការងារ វាចេះតែដឹងហើយ ក៏ប៉ុន្តែវាជាងសាមសិបឆ្នាំហើយមិនដឹងជាយើងបានដឹងដំណឹងនគរបាលណាខ្លះទេ ។ ឥឡូវនេះ នៅពេលដែលឆ្លងការសួរចម្លើយនិងការបានមើលឯកសារចាស់ៗ ខ្ញុំឃើញមានមន្ទីរនគរបាលខ្លះដែលមានឯកសារនៅសល់នៅនឹងស-២១ នេះ ។ ដូចជានគរបាលនៅភូមិភាគបស្ចិមរបស់មិត្តរី ឈ្មោះដើម អ៊ឹម វឿន ។ នគរបាលនៅសៀមរាបដែលលោកវែនណឺ សួរខ្ញុំគ្រប់គ្រងដោយមិត្តពៅ យ៉ង់ ពៅ ដែលនៅពីលើនុំងមាន បងពកៗ ។ ហើយនៅបូព៌ាមាននគរបាលតំបន់-២១ មួយនោះ ឯកសារសួរចម្លើយ លី ផែន នៅនឹងខ្ញុំទេឥឡូវនេះ ។ ដូច្នេះ វាចេះតែដឹងហើយធ្វើការនៅស-២១ វាចេះតែដឹងហើយ ។ ប៉ុន្តែ វាសាមសិបឆ្នាំមកហើយវាភ្លេច សាមសិបឆ្នាំហ្កាយមកហើយវាភ្លេច ។

**លោក អាឡាំង វែនណឺ៖**

ខ្ញុំអត់មានសំណួរអីទៀតទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា មានប៉ុនប៉ងក្នុងការដែលនិយាយបញ្ហាអីទេ?

សូមអញ្ជើញ ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

អរគុណលោកប្រធាន ខ្ញុំធ្វើការសង្កេតដោយសង្ខេប ។ សហព្រះរាជអាជ្ញាជម្រាបអង្គសវនាការថា នៅពេលសវនាការបន្ទាប់ទៀត យើងនឹងចោទសួរជនជាប់ចោទអំពីឋានានុក្រមនៃមន្ទីរសន្តិសុខនៅក្នុងសម័យរបបកម្ពុជាប្រជាធិបតេយ្យដែលយើងសហព្រះរាជអាជ្ញាចោទប្រកាន់ថាស-២១ ស្ថិតនៅក្នុង

ឋានានុក្រមខ្ពស់បំផុត ។ ទីពីរ យើងមានបំណងក្នុងការដាក់ជូនឯកសារជូនជនជាប់ចោទ ចំពោះអ្នកដែលត្រូវបានចាប់ខ្លួនជុំវិញប្រទេស ។ ហើយយើងមិនមានបំណងលើកឡើងអំពីករណីនេះនៅពេលនេះទេ ប៉ុន្តែយើងជម្រាបអង្គសវនាការថា យើងនឹងលើកបញ្ហានេះនៅពេលដំណាក់កាលសវនាការក្រោយៗទៀត ។

[១២:០១:៣៩]

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញាដែលបានផ្តល់ព័ត៌មាននេះជាមុន ហើយដោយឥឡូវនេះដល់ពេលត្រូវពិសារអាហារថ្ងៃហើយ អង្គជំនុំជម្រះសាលាដំបូងប្រកាសសម្រាក ដើម្បីពិសារអាហារថ្ងៃត្រង់ហើយរហូតដល់ម៉ោងមួយកន្លះរសៀល បន្តដំណើរការសវនាការ ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំវិញ ហើយបង្គាប់ឲ្យនាំគាត់ត្រឡប់មកកាន់ទីនេះនៅម៉ោងមួយរសៀល ម៉ោងមួយសាមសិបនាទីរសៀលនេះ ។ ហើយភាគីចូលរួមនៅក្នុងនីតិវិធីសវនាការក៏សូមអញ្ជើញមកកាន់កន្លែងរៀងៗខ្លួនឲ្យបានមុនម៉ោងមួយកន្លះរសៀល ។

*[សវនាការសម្រាកពីម៉ោង១២:០២ នាទី ១៣:៣៣ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ សូមអញ្ជើញសហព្រះរាជអាជ្ញា តើចង់មានយោបល់អីទៅ?

**លោក អាឡិចសាន់ឌឺ ប៊េត៖**

អរគុណលោកប្រធាន ។ ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ចំពោះលេខឯកសាររបស់លោក ស្វាន់ដែលខ្ញុំបានលើកឡើងកាលពីព្រឹកមិញនោះ ។ ខ្ញុំសូមបញ្ជាក់ថា របាយការណ៍របស់ ចនឡេស៊ីក គឺនៅក្នុងឯកសារD45/1 ហើយនិងឌីវីឌី ដែលខ្ញុំបង្ហាញជូនអង្គសវនាការគឺនៅក្នុង D45/1/1។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ សូមអញ្ជើញមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ បើមានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទ, សូមអញ្ជើញ ។

**សួរដោយ លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

អរគុណលោកប្រធាន ។ សូមគោរពលោក លោកស្រីចៅក្រម ។ ខ្ញុំសូមជម្រាបលោក លោកស្រីចៅក្រមនិងភាគីថា ខ្ញុំនឹងប្រើប្រាស់ឯកសារចំនួនបីនៅពេលនេះ ។ ទីមួយគឺតារាងពីរ គឺអង្គការលេខចំនួនពីរ ដែលយើងបានយកមកពិភាក្សាដេញដោលកាលពីថ្ងៃមុនលេខ ERN00154198 ហើយឯកសារទីពីរ អង្គការលេខគឺ 0019199 គឺជាតារាងដូចដែលយើងយកមកពិភាក្សាដេញដោលនៅថ្ងៃមុន ។ នាពេលនេះខ្ញុំចង់សួរជនជាប់ចោទតារាងអង្គការលេខទីមួយ គឺមានចំណងជើងថា "អង្គការលេខរបស់គណៈកម្មាធិការស-២១" ហើយបានបង្ហាញថាជាអង្គការលេខមុនពេលចាប់ នុន ហ៊ុយ ។ តារាងអង្គការលេខទីពីរ គឺមានចំណងជើងថា "ជាអង្គការលេខដែលរៀបចំឡើងបន្ទាប់ពីការចាប់ នុន ហ៊ុយ" ។ ខ្ញុំចង់ពិនិត្យមើលទៅលើតារាងអង្គការលេខទីមួយ ។ ហើយសំណួររបស់ខ្ញុំនោះគឺ៖

**ស៖** ថាតើរចនាសម្ព័ន្ធបានអនុវត្តដែរឬទេ ចាប់តាំងពីលោកចាប់ផ្តើមបំពេញការងារនៅស-២១ ក្នុងនាមជាប្រធាន?

**ឆ៖** រចនាសម្ព័ន្ធអី?

*(មានបញ្ហាបច្ចេកទេស) (សូមគោរពលោកចៅក្រម អត់បើកម៉ាក្រូហ្វូន)*

**ស៖** លោកប្រធាន សូមលោកប្រធានធ្វើការឲ្យធ្វើការស្នើសុំឲ្យមន្ត្រីតុលាការដាក់ឯកសារនេះនៅលើម៉ាស៊ីនបញ្ចាំង ។

[១៣:៣៨:៥៣]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការចាត់ការយកឯកសារពីមេធាវីក្រុមពីរ យកមកដាក់បញ្ចាំងនៅលើអេក្រង់ទូរទស្សន៍។

**សួរដោយ លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

**ស៖** សំណួររបស់ខ្ញុំទៅលើតារាងអង្គការលេខទីមួយ អង្គការលេខនេះ ។ សំណួររបស់ខ្ញុំគឺថា គេបានប្រើប្រាស់អង្គការលេខនេះដែរឬទេ? ថាតើអង្គការលេខនេះត្រូវបានយកមកប្រើប្រាស់ដែរឬទេ? តាំងពីពេលដែលលោកទទួលតួនាទីជាប្រធាននៅស-២១ រហូតដល់ពេលការចាប់ខ្លួន នុន ហ៊ុយ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** លោកប្រធានជាទីគោរព! ខ្ញុំបានរាយការណ៍ជូនលោកចៅក្រមពីមុនច្បាស់លាស់អស់ហើយ រចនាសម្ព័ន្ធដែលខ្ញុំរៀបចំជាអង្គការលេខនេះ គឺរៀបចំក្រោយទេ តាមការចាំ ។ នៅពេលដែលខ្ញុំទទួល

ភារកិច្ចជាប្រធាន ខ្ញុំអត់ប៉ាានរើរុះរចនាសម្ព័ន្ធចាស់ទេ ដូច្នេះកិច្ចប្រតិបត្តិការគឺយើងរក្សាចាស់ ។ ចំណែកអង្គការលេខនេះជាការរំឭកឡើងវិញអាចខ្វះខាតមិនត្រឹមត្រូវតាមរចនាសម្ព័ន្ធដែលយើងខ្ញុំប្រើប្រាស់ ។ ក៏ប៉ុន្តែ អ្វីដែលមាននៅក្នុងអង្គការលេខនេះ គឺវាមាននៅក្នុងការប្រតិបត្តិជាក់ស្តែង ។ ឯចំណែក អង្គភាពនីមួយៗមានប៉ុន្មាននាក់នឹកអត់ឃើញទេ អត់មានឯកសារនឹកអត់ឃើញទេ ។ សរុបមកមួយម៉ាត់សូមឆ្លើយថា អង្គការលេខនេះឈរនៅលើសភាពជាក់ស្តែងដែលយើងខ្ញុំប្រើប្រាស់ ហើយតាមចាំ ។

**ស៖** ខ្ញុំសូមឲ្យមានការបកប្រែម្តងទៀតនៅក្នុងប្រយោគចុងក្រោយរបស់ជនជាប់ចោទដែលបានលើកឡើង ។ តើលោកជនជាប់ចោទអាចនិយាយប្រយោគចុងក្រោយដែលលោកបានលើកឡើងសាជាថ្មីដែរឬទេ? ខ្ញុំស្តាប់អត់បានតាមរយៈការបកប្រែ ។

**ឆ៖** សេចក្តីសរុបរបស់ខ្ញុំនៅលើអង្គការលេខទីមួយនេះ គឺកម្លាំងដែលខ្ញុំចាត់តាំងខ្ញុំប្រើប្រាស់ ខ្ញុំប្រើប្រាស់--

**ស៖** សូមអនុញ្ញាតឲ្យជនជាប់ចោទធ្វើការនិយាយសាជាថ្មី ដោយសារតែឧបករណ៍ស្តាប់របស់ខ្ញុំមានបញ្ហា?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថារចនាសម្ព័ន្ធស-២១ ទោះបីខ្ញុំឡើងធ្វើប្រធានក៏ដោយ ក៏ខ្ញុំអត់ប៉ាានដូររចនាសម្ព័ន្ធរបស់គេទេ ខ្ញុំប្រើប្រាស់រចនាសម្ព័ន្ធចាស់របស់គេតទៅទៀត ។ ដូច្នេះ ជាក់ស្តែង គឺអង្គការលេខនេះវាត្រូវតាមកម្លាំងដែលយើងខ្ញុំមាន យើងខ្ញុំប្រើប្រាស់ ។ ក៏ប៉ុន្តែ វាខ្វះហ្នឹងចំនួនមនុស្ស ឈ្មោះមនុស្សខ្ញុំអត់ចាំ ។ ហ្នឹងខ្ញុំសូមនិយាយប៉ុណ្ណេះ ។

[១៣:៤៣:២៩]

**ស៖** អរគុណ ។ មានន័យថា អង្គការលេខដែលលោកបានមើលនៅក្នុងកញ្ចក់នេះ គឺជារចនាសម្ព័ន្ធអង្គការលេខចាប់តាំងពីស-២១ បានបង្កើតឡើង? តើលោកអាចបញ្ជាក់ចំណុចហ្នឹងដែរ ឬទេ?

**ឆ៖** ទទួល ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមធ្វើការសួរដេញដោលចំពោះជនជាប់ចោទទាក់ទងទៅនឹងចម្លើយដែលលោកបានលើកឡើងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧ គឺឯកសារលេខ D20 លេខ ERN ជាភាសាខ្មែរគឺ 00146657 រហូតដល់ 00146667 ។ លេខ ERN ជាភាសាបារាំងគឺ 00149920 រហូតដល់ 00149931 ។

នៅក្នុងចម្លើយនោះលោកបានជម្រាបជូនសហចៅក្រមស៊ើបអង្កេតថា វាមាននៅក្នុងទំព័រទី៥នៃ

ភាសាអង់គ្លេស ។ នៅក្នុងដំណាក់កាលចុងក្រោយ មានការបញ្ចូលអ្នកស្សួរចម្លើយស្ត្រីម្នាក់បន្ថែមទៀត ខ្ញុំសូមឱ្យបញ្ចាំងនូវតារាងអស់នោះអម្បាញ់មិញម្តងទៀត ដើម្បីបង្ហាញជូនជនជាប់ចោទ អង្គសវនាការ និងសាធារណជន ។ លោកបានបញ្ជាក់នៅត្រង់នេះថា នេះជាសមាជិកបន្ថែមមួយទៀតដែលបានបញ្ចូលហើយវាមានចំនួនប្រាំនាក់ចំពោះអ្នកស្សួរចម្លើយស្ត្រីនោះនៅពេលចាប់ផ្តើម ។ តើមែនដែរឬទេ? ថាតើជនជាប់ចោទនៅរក្សាជំហរដដែលថា មានអ្នកស្សួរចម្លើយស្ត្រីចំនួនប្រាំនាក់មែនដែរឬទេ? ដែលត្រូវបានជ្រើសរើសមកធ្វើការងារនៅពេលចាប់ផ្តើមការងារនៅស-២១? ឬក៏ជាអ្វីៗដែលលោកជម្រាបសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧ ដែលថា នៅដំណាក់កាលចុងក្រោយនោះគឺមានការបញ្ចូលអ្នកស្សួរចម្លើយស្ត្រីម្នាក់បន្ថែមទៀត ។ តើមែនដែរឬទេ? ជនជាប់ចោទអាចបញ្ជាក់ទៅលើចំណុចនេះដែរ ឬទេ?

**ឆ៖** លោកប្រធានជាទីគោរព! ការបកប្រែចុះឡើងៗរដិបរដុបណាស់ ខ្ញុំសូមបញ្ជាក់ថា រឿងដែលខ្ញុំបាទបានរាយការណ៍ជូនលោកចៅក្រមស៊ើបអង្កេត វាភ្លេចស្ត្រីម្នាក់ដែលស្សួរចម្លើយស្រី ។ ខ្ញុំភ្លេចឈឹងភ្លេចមិត្តពឿន ។ ដល់ទៅពេលធ្វើការតទល់គ្នា ខ្ញុំទៅឃើញមុខប្អូនថ្លៃ មិត្តពឿន គឺ មិត្តម៉េត សោម ម៉េត ជាជនរងគ្រោះម្នាក់ដែលយើងខ្ញុំកម្ទេចបងបង្កើតហើយនិងបងថ្លៃ បានខ្ញុំនឹងឃើញតារាងនេះវាខ្វះបុគ្គលិកស្សួរចម្លើយស្ត្រីម្នាក់នៅពេលរាយការណ៍ជូនអង្គសវនាការនាពេលនេះ ខ្ញុំបន្ថែម ដូច្នេះមិនមែនជ្រើសរើសបន្ថែមទេ ខ្ញុំនឹកឃើញមនុស្សម្នាក់នេះ ខ្ញុំដាក់បន្ថែម។ សូមលោកប្រធានជ្រាប ។

[១៣:៤៨:០៨]

**ស៖** គឺត្រឡប់ទៅលើចំណុចមួយ ខ្ញុំបានអានប្រយោគមួយប្រយោគនៅក្នុងសេចក្តីប្រកាសរបស់លោកនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ។ ខ្ញុំអានសាជាថ្មី នៅក្នុងដំណាក់កាលចុងក្រោយមានការបញ្ចូលបន្ថែមចំនួនមួយរូប មានការបញ្ចូលអ្នកស្សួរចម្លើយស្ត្រីចំនួនមួយរូបបន្ថែម ។ ដូច្នេះ តើលោកអាចបញ្ជាក់ទៅលើសេចក្តីប្រកាសមួយនេះ ដែលលោកបានធ្វើឡើងជូនសហចៅក្រមស៊ើបអង្កេតចំពោះ អង្គហេតុមួយនេះបានដែរឬទេ?

**ឆ៖** កញ្ញាស្ទួតហ្សីនស្គី សូមឱ្យបញ្ចាំងចម្លើយរបស់ខ្ញុំ សូមៗកញ្ញា សូមអនុញ្ញាតលោកប្រធានឱ្យគេបញ្ចាំងចម្លើយរបស់ខ្ញុំចំពោះចៅក្រមស៊ើបអង្កេតទៅ ពីព្រោះការបកប្រែនៅរដិបរដុបយើងស្តាប់គ្នាអត់បានទេ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារមិញនេះ ដែលមានការចង់អានមិញដោយសារមានការបកប្រែមិនច្បាស់យកមកដាក់បញ្ចាំងនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

[១៣:៥០:៣០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញជនជាប់ចោទ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ខ្ញុំសូមអនុញ្ញាតលោកប្រធាន ឲ្យគេបញ្ចាំងជាភាសាខ្មែរ ជាភាសាច្បាប់ដើមដែលយើងប្រើប្រាស់នៅក្នុង អ.វ.ត.ក ។

*(ដំណើរការរៀបចំបញ្ចាំងឯកសារទៅលើអេក្រង់)*

[១៣:៥៤:៤៩]

**ប្រធានអង្គជំនុំ៖**

បង្រួមឲ្យតូចបន្តិច ជាងហ្នឹងទៀតបាន១ មើលអត់អស់ ។ តូចពេកហើយ ពង្រីកមកវិញមើលអតិបរមាមក! ប៉ុន្តែកុំឲ្យវាដល់តែមបាត់អក្សរ បាន១ ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្ពី៖**

សូមឲ្យមន្ត្រីតុលាការធ្វើការអាន ការបកប្រែជា ភាសាអង់គ្លេស ដែលមានដូចខាងក្រោមនេះ៖ នៅដំណាក់កាលចុងក្រោយហ្នឹង គឺមានការបន្ថែមអ្នកសួរចម្លើយស្ត្រីមួយនាក់ទៀត សូមលោកអានផ្នែកហ្នឹង ដែលជាភាសាខ្មែរនៅលើអេក្រង់ ។

**ប្រធានអង្គជំនុំ៖**

លោកស្រី សែ កុលវុឌ្ឍី អានទាំងនូវសំណួររបស់ចៅក្រម យូ ប៊ុនឡេង ហើយនិងឆ្លើយនូវចំណុចដែលមានគូសនូវសំណួរខាងលើនេះ នៅទំព័រនេះ គឺសំណួរខាងលើបង្អស់នេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សំណួរលោក--

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្ពី៖**

លោកប្រធាន សុំទោស! ខ្ញុំចង់ឲ្យអានតែនៅឃ្លាមួយ ដែលជាភាសា មានការបកប្រែជាភាសា

អង់គ្លេស ដែលជាភាសាខ្មែរថា នៅដំណាក់កាលចុងក្រោយហ្នឹង គឺមានការបញ្ជូលអ្នកសួរចម្លើយជាស្រីម្នាក់ទៀត ។

**ប្រធានអង្គជំនុំ៖**

អានតាមការស្នើសុំនេះចុះ ក្រឡាបញ្ជី ។

[១៣:៥៦:៥៤]

**លោកស្រី សែ កុលវុឌ្ឍី៖**

នៅគ្រាចុងក្រោយមានការបញ្ជូលអ្នកសួរស្រី ដែលជាប្រពន្ធរបស់កម្មាភិបាលនៅស-២១បន្ថែមដើម្បីសួរយកចម្លើយ ។ តាមការជ្រើសរើសរបស់ខ្ញុំ ព្រោះមានអ្នកសួរបុរសម្នាក់ធ្វើបាបស្ត្រីជនរងគ្រោះ ។ ខ្ញុំមិនបានយកចិត្តទុកដាក់លើចំនួនអ្នកសួរចម្លើយទាំងអស់ទេ ។

**សួរដោយ លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

សូមអរគុណ ។

**ស៖** ឥឡូវនេះ ខ្ញុំវិលត្រឡប់មកជនជាប់ចោទវិញ តើលោកអាចបញ្ជាក់បានទេ លោកបានបញ្ជាក់អំពី ចំណុចនេះដល់ចៅក្រមស៊ើបអង្កេតនោះ?

**ឆ៖** លោកប្រធានជាទីគោរព! ខ្ញុំសូមអនុញ្ញាតបញ្ជាក់ជូនកញ្ញា ស្ទួតហ្សីនស្គី ដូចតទៅ (បាត់ៗពីអេក្រង់នោះបាត់ហើយ) សូមៗ--

**ស៖** អ៊ីចឹង គឺខ្ញុំចង់ឲ្យលោកធ្វើការអានប្រយោគហ្នឹង តើលោកអាចធ្វើការបញ្ជាក់បានទេ លោកមានបានសរសេរ ឬក៏និយាយប្រាប់ដូច្នេះ ដល់ខាងចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** កញ្ញា ស្ទួតហ្សីនស្គី សូមកញ្ញាកុំអន្ទះសារពេក ខ្ញុំអានជូន ។ សូមកុំអន្ទះសារពេក ។ នៅគ្រាចុងក្រោយមានការបញ្ជូលអ្នកសួរស្រី ភាសាខ្មែរ អ្នកសួរស្រី អត់មានវចនៈទេ មិនដឹងជាចំនួនប៉ុន្មានទេ ហើយដល់ទៅបកប្រែជាភាសាអង់គ្លេស ថាសួរស្រីម្នាក់ បញ្ជូលស្រីម្នាក់ ខុសពីន័យដើមហើយ ។ នេះហើយដែលធ្វើឲ្យយើងស្តាប់គ្នាមិនបាន ដោយសាររឿងបកប្រែ ។ មានបញ្ជូលអ្នកសួរចម្លើយ អ្នកសួរស្រី ដែលជាប្រពន្ធរបស់កម្មាភិបាលនៅស-២១បន្ថែម ដើម្បីសួរយកចម្លើយ គឺបន្ថែមទៅលើអ្នកសួរប្រុសៗ ។ នេះជាការពិត ពីលើកមុនវាមានតែប្រុសទេ ដល់ក្រោយមានរឿងរ៉ាវមក ខ្ញុំបញ្ជូលកម្មាភិបាលសួរចម្លើយភេទស្រី ។ ប៉ុន្តែ នៅក្នុងនេះខ្ញុំអត់បញ្ជាក់ចំនួនទេ ហើយដល់ទៅបកប្រែជាអង់គ្លេសថាមួយ ។ ខ្មែរហើយនិងអង់គ្លេស លែងត្រូវគ្នាហើយ នេះសូមបញ្ជាក់ជូនកញ្ញា ដោយៗ

ឲ្យច្បាស់លាស់ ។

**ស៖** អ៊ីចឹង ជាថ្មីម្តងទៀត តើលោកអាចបញ្ជាក់បានទេ នៅដំណាក់កាលចុងក្រោយ ឬក៏នៅគ្រាចុងក្រោយ?

[១៥:០០:០៣]

**ឆ៖** គ្រាចុងក្រោយក្នុងន័យនេះ ដែលខ្ញុំនិយាយជា ភាសាខ្មែរ សំដៅក្រោយពីបាតុភាព ដែលកម្មាភិបាលប្រុសម្នាក់នោះរំលោភលើរាងកាយរបស់អ្នកគ្រូខ្ញុំ ។ គ្រាចុងក្រោយ គឺក្រោយបាតុភាពរំលោភលើរូបរាងកាយ ។ ដូច្នេះ ឆ្នាំខែយើងអត់បានបញ្ជាក់ទេ ។

**ស៖** តើលោកនៅចាំទេ នៅកាលបរិច្ឆេទ ឬក៏ឆ្នាំ នៅពេលដែលមានការរំលោភនោះកើតឡើង? ខ្ញុំប្រើពាក្យរំលោភ ដោយខ្ញុំមិនប្រើពាក្យដែលថា រឿងហេតុមួយបានកើតឡើងនោះ នៅពេលដែលមានកិច្ចការនោះកើតឡើង រឿងហេតុកើតឡើងនោះ តើវានៅថ្ងៃណាដែរ?

**ឆ៖** មិនចាំទេ បើសិនជាយើងមានឯកសារបញ្ជីអ្នកទោសស-២១ យើងអាចប៉ាន់ប្រមាណបានថា ក្នុងអំឡុងណាទៅអំឡុងណា? ប៉ុនតែឡូវវាអត់មានឯកសារនេះនៅក្នុងដៃទៀត ។ ឯចំណែកព្រឹត្តិការ-នេះកើតឡើង គ្មានអ្នកណាបានកត់ត្រាទេ ។ ហើយខ្ញុំនិយាយអម្បាញ់មិញហ្នឹង មុននឹងកញ្ញាសួរខ្ញុំ ក៏ខ្ញុំនិយាយបានតែថ្ងៃមិនចាំ ខែមិនចាំ បើតាមខ្ញុំចាំប្រហែលជាឆ្នាំ១៩៧៧ ប្រហែលជាក្នុងឆ្នាំ៧៧។

**ស៖** បើអ៊ីចឹង ខ្ញុំលើកពីចំណុចមួយទៀត ។ បើនិយាយអំពីការចាត់តាំងការងាររបស់លោកកាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ ហើយខ្ញុំចង់ដឹងថាតើ សុន សេន បានប្រាប់លោកនៅថ្ងៃនុ៎ងគឺថ្ងៃដែលមានការចាត់តាំងនុ៎ង អំពីតួនាទីរបស់លោក ក្នុងនាមជាអនុប្រធានមន្ទីរស-២១ នោះ តើត្រូវមានតួនាទីធ្វើអ្វីខ្លះ?

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការដកឯកសារហ្នឹងចេញទៅ ដើម្បីឲ្យរូបភាពទៅប្រក្រតីវិញ ។

ជនជាប់ចោទ ឆ្លើយនឹងសំណួរហ្នឹងបន្ត ។

**ជនជាប់ចោទ**

**ឆ៖** សូមគោរព អរគុណលោកប្រធាន ។ ថ្ងៃដែលចាត់តាំងនោះ អត់មានបាននិយាយអីគ្នាច្រើនទេ គ្រាន់តែប្រាប់ថា ទីមួយ មិត្តណាត ប្រធាន មិត្តឌុច អនុប្រធាន ហើយសមាជិក ផ្សេងទៀត គឺមានមិត្តហ៊ី និងមិត្តហ៊ុយ ។ បច្ចុប្បន្ននេះ មិត្តណាត ត្រូវបង្ហើយការងារចាស់ ។ ឯចំណែក មិត្តឌុច ឲ្យគេ

ទៅយកកម្លាំងពីអមលាំងមក ។ ទិសដែលត្រូវមិត្តទៅនៅរៀបចំមន្ទីរនគរបាលហ្នឹង គឺនៅខាងកប់ស្រូវ មិត្តពឹងពាក់ខាងនីរសារឲ្យគេជូនទៅ នេះនិយាយជាជម្រៅសាច់ការប៉ុណ្ណឹង ។ ហើយក៏និយាយពីរឿង ឈ្មោះ មន្ទីរស-២១ នេះ ។ ខ្ញុំសូមនិយាយម្ដងទៀតចុះ ឈ្មោះ ស នេះវាមកពីពាក្យ --

**ស៖** ខ្ញុំសូមទោសបើខ្ញុំសុំកាត់ នេះមិនមែនជាសំណួររបស់ខ្ញុំទេ ។ ខ្ញុំនឹងព្យាយាមសួរម្ដងទៀត។ អ៊ីចឹងនៅក្នុងតួនាទីរបស់លោកជាអនុប្រធាន តើតួនាទីរបស់លោកនៅពេល ដែលលោកឡើងធ្វើជំនួស ឲ្យ ណាត នៅពេលដែល ណាត គាត់ឈឺ ឬក៏មិនមានវត្តមាន ឬក៏គាត់មានភារកិច្ចត្រូវទៅធ្វើការងារនៅ កន្លែងណាផ្សេងនោះ តើលោកមានភារកិច្ចធ្វើអ្វីទៅ?

[១៤:០៥:០៣]

**ប្រធានអង្គជំនុំ៖**

សូមបញ្ជាក់លោកស្រី ស្ទួតហ្វឹនស្គី ពេលដែលសួរចប់ សូមបិទមេក្រូ អ៊ីចឹងវាលាន់សំឡេងនៅ ក្នុងការស្ដាប់ហ្នឹង គឺវាប្រឆាំងគ្នា។ ហើយអ៊ីចឹង សូមមានការចាប់អារម្មណ៍បញ្ហានេះ វាអាចមិនធ្លាប់ទេ អ្នកទាំងអស់គ្នា ទាំងខ្ញុំមិនធ្លាប់ដែរ ប៉ុន្តែឥឡូវនេះទម្លាប់ប្រើង ដើម្បីឲ្យបញ្ហាហ្នឹង វាច្បាស់លាស់ ។

សូមអញ្ជើញលោក កាំង ហ្កេកអ៊ាវ ឆ្លើយនឹងសំណួរនេះ ។

**ឆ៖** អរគុណលោកប្រធាន ។ ម្នាក់ចង់បានទ្រឹស្ដី ម្នាក់ចង់រាយការណ៍អំពី កិច្ចដំណើរការជាក់ ស្ដែង ។ ជាទ្រឹស្ដី គ្មានការប្រាប់ច្បាស់លាស់ថា មិត្តត្រូវអីទេ ហើយបើ ណាត ឈឺមិត្តត្រូវធ្វើអីខ្លះនោះ ទេ។ ការចាត់តាំងអ៊ីចឹងហើយ យើងខ្ញុំនាំគ្នាខំធ្វើការទៅ តាមភារកិច្ចដែលចែកឲ្យបណ្ដើរៗបន្តបន្ទាប់ ។ ដូច្នេះ យើងខ្ញុំមិនអាចបំពេញចិត្តកញ្ញា ទៅតាមទ្រឹស្ដី ដែលកញ្ញាចង់បាននោះបានទេ ។ សូមទោស ជាក់ស្ដែងវាផ្សេង ។

**ស៖** តើជាការត្រឹមត្រូវទេ បើសិនជាខ្ញុំនិយាយថា នៅពេលនោះគឺថាមិនមានច្បាប់អ្វីទេ ដែល ថា អនុប្រធានត្រូវតំណាងឲ្យប្រធានគឺ ណាត នៅពេលដែលគាត់ជាប់រវល់នោះ?

**ឆ៖** ខ្ញុំមិនឃើញច្បាប់ជាលាយលក្ខណ៍អក្សរទេ ក៏ប៉ុន្តែប្រសិនជាគេឈឺ ឬគេរវល់ទៅណាមក ណី គេប្រាប់ឲ្យខ្ញុំធ្វើអីខ្លះ ។ អានេះមែនមាន ។

**ស៖** កាលពីថ្ងៃទី២៣ លោកបានប្រាប់យើងថា លោកមិនចង់ដឹង ឬក៏មិនចង់យល់អំពីកង កម្លាំង ពីកងកម្លាំងនោះទេ ពីព្រោះកងកម្លាំងអស់ទាំងហ្នឹង គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ណាត

គឺថាលោកមិនចង់ដឹងអ្វីទាំងអស់អំពីរចនាសម្ព័ន្ធចាត់តាំងនៅពេលនោះ ។

អ៊ីចឹង ខ្ញុំចង់ដឹងថា ក្នុងនាមជាអនុប្រធាននោះ ហើយដែលលោកនៅពេលដែលលោកត្រូវបំពេញការងារជំនួសឲ្យ ណាត នោះ នៅក្នុងករណីដែលគាត់ត្រូវតែមិនអាចបំពេញការងារបាន ហើយបើសិនជាលោកមិនដឹងពីអ្វីទាំងអស់នោះ តើលោកធ្វើយ៉ាងម៉េចទៅ?

**ឆ៖** ចុះមានអីទៅពិបាក ។ អត់ពិបាកទេ បាតុភាពអីកើតឡើង ខាងក្រោមគេមកស្នើយោបល់យើងឲ្យយើងសម្រេច ។ យើងជាអ្នកសម្រេច មិនមែនទៅចាត់ចែងការងារអីថ្មីខុសធម្មតាឯណា ។ យើងជំនួសមេ យើងជំនួសប្រធានក្នុងឋានៈយើងជាអនុប្រធានយើងជំនួសប្រធាន យើងជាអ្នកសម្រេច យើងអត់ទៅចាត់ចែងការងារផ្ទាល់ទេ ។

[១៤:០៩:១៦]

**ស៖** បន្ថែមលើនេះ លោកបានពន្យល់កាលពីថ្ងៃទី២៧ថា លោកចង់បន្តធ្វើការងារជាអនុប្រធាន ហើយមិនចង់ក្លាយជាប្រធានស-២១ ទេ ។ តើលោកអាចបញ្ជាក់បានទេ ថានេះជាអ្វីដែលលោកបានបញ្ជាក់ប្រាប់នោះ ពីព្រោះនេះគឺជាអ្វីដែលខ្ញុំបានឃើញនៅក្នុងប្រតិចារឹកកាលពីថ្ងៃទី២៧ នេះ?

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំសូមឆ្លើយបញ្ជាក់បន្ថែមជាចុងក្រោយជូនកញ្ញា ស៊្វតហ្សីនស្គី រឿងខ្ញុំមិនចង់ធ្វើប្រធាន និយាយឲ្យរួមមូលដ្ឋាន គឺខ្ញុំមិនចង់ធ្វើការងារស-២១ ប៉ុន្តែគេចវាមិនរួច ដូច្នេះឆក់ឱកាសដែលមេដក ណាត ចេញ ខ្ញុំឡើងធ្វើប្រធាននេះ ខ្ញុំទាមទារសុំយកកម្មាភិបាលចាស់របស់ខ្ញុំយកមកធ្វើប្រធាន ។ រឿងនេះជារឿងពិតគឺ សុំយកកម្មាភិបាលចាស់របស់ខ្ញុំឈ្មោះ ឆាយ គឹមហ៊ៃ មកធ្វើប្រធាន រឿងនេះជារឿងពិត ជាមួយនឹងចៅក្រមស៊ើបអង្កេតក៏ខ្ញុំបានរាយការណ៍ជម្រាបគាត់--

**លោកស្រី ស៊ីលឃីស្វត ហ្សីនស្គី៖**

*(មិនមានការបកប្រែ)*

**ជនជាប់ចោទ៖**

អូយ! កុំអាលកាត់ខ្ញុំ ឲ្យខ្ញុំនិយាយឲ្យចប់មើល!

រឿងនេះវាជារឿងពិត ដូច្នេះជាមួយនឹងចៅក្រមស៊ើបអង្កេត ក៏ខ្ញុំបានជម្រាបលោកដោយស្មោះត្រង់ ដោយត្រឹមត្រូវជាមួយនឹងអង្គសវនាការនេះ ក៏ខ្ញុំបានជម្រាបលោកអស់ហើយ ។ ដូច្នេះ កញ្ញាសួរទៀតហ្នឹង ជាន់ណាស់ សំណួរនេះជាន់ហើយជាន់ទៀតណាស់ ។ បើតាមពិតខ្ញុំមានសិទ្ធិមិនឆ្លើយបានណា នេះសូមជម្រាបបញ្ជាក់ ។

**លោកស្រី ស៊ីលឃីស្វូត ហ្សីនស្គី៖**

ខ្ញុំចង់ស្នើសួរ ស្នើសុំដល់ប្រធាន លោកប្រធានឲ្យជម្រាបទៅដល់ជនជាប់ចោទឲ្យឆ្លើយតប ទៅនឹងសំណួររបស់ខ្ញុំ ។ ហើយជាថ្មីម្តងទៀត សំណួរមួយនេះ គឺថាតើអាចបញ្ជាក់ឬទេថា លោកបាននិយាយឡើងនៅថ្ងៃទី២៧ ពីរថ្ងៃមុន នៅក្នុងសវនាការនេះ? នេះគឺជាសំណួរដែលចង់ខ្ញុំចង់បញ្ជាក់ទៅលើប្រតិចារឹក ថាតើនៅថ្ងៃនោះលោកបាននិយាយអ៊ីចឹងមែនដែរឬទេ? ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានឲ្យជនជាប់ចោទធ្វើការឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ ។

ខ្ញុំសូមឲ្យលោកប្រធានធ្វើការបង្គាប់ទៅលើបញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទអាចឆ្លើយនឹងសំណួរនេះបានទេ? បើអាចឆ្លើយបានឆ្លើយ ឆ្លើយមិនបានជាសិទ្ធិរបស់ជនជាប់ចោទ សិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ គឺសិទ្ធិនេះមានសម្រាប់ជនជាប់ចោទគ្រប់ពេល ។

[១៤:១៣:០៤]

**ជនជាប់ចោទ៖**

លោកប្រធានអរគុណលោកប្រធានជាទីគោរព! ខ្ញុំសូមគោរពបញ្ជាក់ថា សំណួរនេះវាវិលដូចអាចម៍ចូលឈ្នាងអ៊ីចឹង ខ្ញុំសូមមិនឆ្លើយទេ ។

**ប្រធានអង្គជំនុំ៖**

មេធាវីបន្តសំណួរថ្មីផ្សេងទៀត ហើយអង្គជម្រះរំឭកសាជាថ្មីម្តង គឺប្រឹងប្រែងឲ្យអស់លទ្ធភាពដែលអាចធ្វើទៅបាន ជៀសវាងនឹងការតាំងសំណួរច្រំដែល ។

**លោកស្រី ស៊ីលឃីស្វូត ហ្សីនស្គី៖**

អរគុណលោកប្រធាន ។ ប៉ុន្តែ សូមអនុញ្ញាតឲ្យអង្គសវនាការជ្រាបទៅលើបញ្ហា ។ សំណួរនេះគ្រាន់តែចង់ឲ្យជនជាប់ចោទធ្វើការបញ្ជាក់ទៅលើឃ្លាដែលបានលើកឡើងដោយជនជាប់ចោទ ។

**ប្រធានអង្គជំនុំ៖**

អង្គជម្រះជម្រាបមេធាវីហើយថា សួរសំណួរផ្សេងទៀត សំណួរនេះជនជាប់ចោទបានរក្សាសិទ្ធិមិនឆ្លើយតបរួចហើយ ។ ហើយអង្គជម្រះសូមរំឭកថា មិនគប្បីយកបញ្ហាផ្សេងៗយកមកលើកឥតប្រយោជន៍នាំឲ្យរំខានពេលវេលាដំណើរការសវនាការទេ ។ ជាច្រើនដងហើយការដែលលើកឡើងបញ្ហា

គ្រាន់តែតតាំងចុះឡើងហ្នឹងចំណាយដប់ប្រាំមីនុត ម្ភៃមីនុត នេះជាតាំងពីដើមដែលយើងកត់សម្គាល់មក។ អ៊ីចឹងប្រឹងប្រែងចំណាយពេលវេលាដែលមាន ដើម្បីធ្វើការដេញដោលអង្គហេតុ ដែលវាមាននៅចំពោះមុខ ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទូតហ្សិនស្គី៖**

**ស៖** អរគុណលោកប្រធាន ។ ខ្ញុំសង្ឃឹមថា អង្គសវនាការនឹងទាញសន្និដ្ឋានថា ជនជាប់ចោទមិនបានឆ្លើយតបទៅនឹងសំណួរនេះ ។ នៅពេលនេះខ្ញុំចូលទៅដល់ចំណុចមួយទៀត ។ លោកបានប្រាប់យើងខ្ញុំថា លោកគេជ្រើសរើសលោកឲ្យជំនួស ណាត ដោយសារលោកពូកែសួរចម្លើយ ។ ខ្ញុំចង់សួរថា ហេតុអីបានលោកមិនធ្វើការសួរចម្លើយនៅ ស-២១ ដោយខ្លួនឯងនៅទីនោះ? គឺវាលើកលែងតែករណីកុយ ធួន ដែលលោកធ្វើការសួរចម្លើយដោយខ្លួនឯង ចុះហេតុអ្វីបានជាលោកមិនធ្វើការសួរចម្លើយនៅ ស-២១ ដោយខ្លួនឯងក្រៅពីករណីនេះ ។

**ប្រធានអង្គជំនុំ៖**

ស្ទូតហ្សិនស្គី បិទមេក្រូហ្វូនក្រោយពីនិយាយចប់ ដើម្បីទុកពេលឱកាសជូនទៅជនជាប់ចោទឆ្លើយ ។ អ៊ីចឹងលាន់ឮរហូត អានេះដូចជាវំពូកដូចច្រើនហើយ ។

អញ្ជើញជនជាប់ចោទឆ្លើយនឹងសំណួរនេះ ។

[១៤:១៦:៤៥]

**ជនជាប់ចោទ៖**

**ឆ៖** សូមអរគុណលោកប្រធាន ។ ពាក្យសួរមួយម៉ាត់ខ្លី ប៉ុណ្ណឹងសមរម្យណាស់ទៅហើយ មិនបាច់វំពូករឿងផ្សេងវែងឆ្ងាយទេ ។ ម៉េចបានជាអ្នកឯងធ្វើប្រធាន ក៏មិនសួរចម្លើយខ្លាំងដោយខ្លួនឯងហើយទទួលស្គាល់ថា សួរតែម្នាក់ មែន ការងារខ្ញុំដែលមេប្រគល់ឲ្យគឺ ចារលើសេចក្ដីសារភាព ។ នេះជាការងារធំៗមែនទែនរវល់ទាំងយប់ទាំងថ្ងៃ ។ ខ្ញុំសូមទាញអារម្មណ៍កញ្ញាមួយម៉ាត់ ក្នុងប៉ូលិសសង្គមចាស់ *កុងត្រូល័រ* វាធំជាង *កុំមីស៊ែ* *កុំមីស៊ែ* វាធំជាង *អាំងស្ពិចទ័រ* ប៉ូលិសសង្គមចាស់ *អាំងស្ពិចទ័រ* ទេគេសួរចម្លើយ ។ ខ្ញុំចាត់ទុកខ្លួនឯងថា *កុំមីស៊ែ* ខ្ញុំអត់សួរចម្លើយទេ លើកលែងតែមានបញ្ហាជាពិសេសមក ។ នេះសូមបញ្ជាក់អ៊ីចឹង ។

**ស៖** អរគុណ ប៉ុន្តែលោកអត់បានឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំនោះទេ ។ សំណួររបស់ខ្ញុំបន្ទាប់ទៀត គឺលោកបាននិយាយថា លោកបង្រៀនអ្នកសួរចម្លើយអំពីរបៀបសួរចម្លើយ ។ ថាតើលោកបាន

បង្រៀនពួកគេផងដែរឬទេ? គឺអ្នកសួរចម្លើយនោះអំពីរបៀបនៃការធ្វើទារុណកម្មផងដែរ តើលោកមានដែលបង្រៀនពួកគេដែរឬទេ?

**ឆ៖** អារឿងធ្វើទារុណកម្មមិនបាច់បង្រៀនទេ ប្រាប់ថា ចំពោះបញ្ហាជនណ៌ា ប្រាប់ថា នេះអ្នកសួរចម្លើយជាបញ្ហាជនខ្ញុំនិយាយជាពីរអ៊ីចឹង ។ មនុស្សដែលបក្សចាត់មកហើយត្រូវតែចាត់ទុកជាខ្មាំងបានសួរចម្លើយចេញ នេះជាបញ្ហាជន ។ ក៏ប៉ុន្តែ ជាកសិករដែលចង់បង្ហាញថា ខ្លួនឯងវាដាច់ខាតប្រយ័ត្នវ៉ៃងាប់មនុស្ស នេះទិដ្ឋភាពពីរនេះ ដែលយើងខ្ញុំជាកម្មាភិបាលផង ជាកម្មាភិបាលដឹកនាំមន្ទីរស-២១ ផងត្រូវគិត ។ នេះខ្ញុំនិយាយពីការជាក់ស្ដែង ហើយវាអត់ចំ ពិតជាអត់ចំសំណួររបស់កញ្ញា កញ្ញាធ្វើ *អុបសឺវ៉ាស្យុង* ថា ខ្ញុំមិនឆ្លើយនឹងសំណួរទៀតហើយ ។

[១៤:១៩:៣២]

**ស៖** ជាអកុសលគឺ លោកនិយាយនឹងត្រូវត្រឹមហើយ គឺលោកមិនឆ្លើយចំទៅនឹងសំណួររបស់ខ្ញុំនោះទេ ហើយខ្ញុំសន្និដ្ឋានថា នៅពេលដែលលោកនិយាយថា ពួកគេអាច មិនអាច-- គាត់វ៉ៃគេឲ្យស្លាប់។ ដូច្នេះ ហើយពួកគេត្រូវតែទទួលការបណ្ដុះបណ្ដាលខាងផ្នែកនុង ។ ដូច្នេះហើយ គឺការបង្រៀន ទៅលើបញ្ហាធ្វើទារុណកម្មនេះ គឺលោកបានរៀបចំឡើង និងបង្រៀនចំពោះការសួរចម្លើយ ។

**ឆ៖** អុញ! នេះសំណួរហើយហ្នឹង? កញ្ញាចង់សួរខ្ញុំថាម៉េច?

**ស៖** សូមនិយាយសាជាថ្មី ។ សេចក្ដីសន្និដ្ឋានរបស់ខ្ញុំ ហើយប្រហែលជាលោកអាចបញ្ជាក់ថាត្រឹមត្រូវដែរឬទេ? ឬក៏មិនត្រឹមត្រូវ? គឺអ្នកស្រែដែលមិនមានការបណ្ដុះបណ្ដាល គាត់ត្រូវការវគ្គបណ្ដុះបណ្ដាលខាងផ្នែកទារុណកម្ម ។ ដូច្នេះលោកអាចបញ្ជាក់ទេ ថាលោកបានធ្វើការបណ្ដុះបណ្ដាល ឬក៏បង្រៀនអ្នកកសិករដែលមិនបានទទួលការបង្រៀនទាំងអស់នោះ?

**ឆ៖** កសិករតាមព្រៃភ្នំ ពួកអមលាំង ខ្ញុំបណ្ដុះបណ្ដាលប៉ុន្មានឆ្នាំរបស់ខ្ញុំរួចមកហើយ ខ្ញុំយកចូលមកមន្ទីរស-២១ ។ ដូច្នេះ ជាកម្លាំងដែលខ្ញុំជឿទុកចិត្តជាងគេ ។ មកដល់ភ្នំពេញចាប់ផ្ដើមស-២១ ខ្ញុំបណ្ដុះបណ្ដាលកសិករតាមដងទន្លេ គឺអតីតយុទ្ធជន ហ្នឹងហើយដែលពិបាកទប់ គេជ្រុលដៃធ្វើទារុណ-កម្ម ហ្នឹងដែលពិបាកទប់ ។

ដូច្នេះ ខ្ញុំបណ្ដុះបណ្ដាលទាំងអស់ កសិករតាមដងទន្លេក៏ខ្ញុំបណ្ដុះបណ្ដាល បញ្ញាជនក្រុងភ្នំពេញក៏ខ្ញុំបណ្ដុះបណ្ដាល កសិករព្រៃភ្នំក៏ខ្ញុំបណ្ដុះបណ្ដាល ។ បើខ្ញុំហើយមិនបណ្ដុះបណ្ដាល ខ្ញុំមិនមែនជាអ្នកមេគេទេ ហើយមិនមែនថាថ្ងៃនេះមកជាប់បទឧក្រិដ្ឋណារឿងពង្វក់ពង្វើយុវជនឲ្យៗ កាន់អំពើឃោរឃៅ

មិនមែនមកជាប់ទោសទេ ។

**ស៖** តើលោកមានបង្រៀនពួកគេអំពី ថាតើត្រូវធ្វើទារុណកម្មយ៉ាងម៉េចដែរឬទេ?

[១៤:២៣:១៣]

**ឆ៖** មានៗ រូបភាពធ្វើអនុញ្ញាតឲ្យប្អូនបែប វាយ ហ្នឹងទីមួយ។ បើអាហ្នឹងហើយមិនមែនទៀត មិនដឹងស្អីទេ អាសួរទៅ ឆ្លើយខ្លួនឯងទៅក៏បានដែរ ។

**ស៖** សូមអរគុណ ។ នេះគឺបានឆ្លើយតបទៅនឹងសំណួរដើមរបស់ខ្ញុំហើយ សូមអរគុណចំពោះការឆ្លើយដូច្នេះ ។

ខ្ញុំមានសំណួរចុងក្រោយមួយទៀត ថាតើលោកធ្លាប់ចូលរួមការសួរចម្លើយដែលអ្នកសួរចម្លើយរបស់លោកបានសួរចម្លើយដែរឬទេ? ហើយលោកដែលធ្លាប់ចូលរួមសួរចម្លើយដែរឬទេ? ហើយលោកដែលសង្កេតឃើញថាបុគ្គលិករបស់លោក គឺគាត់បានធ្វើការសួរចម្លើយតាមបញ្ជារបស់លោក?

**ឆ៖** អត់ទេ, ខ្ញុំអត់មានបានចូលរួមទេ សួរគឺសួរដាច់មុខ ទុកឲ្យគេសួរ ខ្ញុំនៅផ្ទះធ្វើឯកសារ ។

**ស៖** ដូច្នេះ ចង់ដឹងថាតើអ្នកសួរចម្លើយនោះត្រូវបានគ្រប់គ្រងតាមរបៀបណា? ហើយពួកគេត្រូវបានគ្រប់គ្រងតាមរបៀបណា ដែលដឹងពួកគេត្រូវបានសួរចម្លើយត្រឹមត្រូវទៅតាមអ្វីដែលមានការបង្គាប់នោះ?

**ឆ៖** ខ្ញុំបានរាយការណ៍រួចអស់ហើយ ក្នុងអង្គការលេខក៏មាន គឺមានក្រុមរបស់គេ ។ អង្គការលេខអត់មានដាក់ត្រជាក់ ក្តៅ អង្កៀម អីទេ មែន ។ ដូចខ្ញុំបានរាយការណ៍រួចហើយ គេមានកត់មេក្រុមរបស់គេ ផ្ទួនពេលហ្នឹងគឺគ្នាគេ ។ មេក្រុមទទួលភារកិច្ចទទួលខុសត្រូវចំពោះមុខបក្ស ចំពោះមុខមន្ទីរស-២១ ចំពោះមុខខ្ញុំ ក្នុងការអនុវត្តទារុណកម្មក៏ដោយ ក្នុងការសួរចម្លើយក៏ដោយ គេមានក្រុមរបស់គេ ។

**ស៖** មានន័យថា លោកមិនដែលគ្រប់គ្រងដោយខ្លួនឯង ថាតើពួកគេធ្វើការបានតាមរបៀបណានោះទេ? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** កញ្ញា ស្នួត ហ្សីនស្ពី ដូចជាមិនធ្លាប់ធ្វើទ័ព ឬធ្វើការងារអីឲ្យធំដុំទេអី? មិនដែលអាមេធំអីនៅចុះជាប់រហូតទៅពួកនោះ កម្មាភិបាលកងពលគេមិនកាន់ *អា.កា(AK)* ចូលប្រយុទ្ធទេ កញ្ញាអើយ ។ នេះសូមជម្រាប ខ្ញុំមេប្រធានមន្ទីរស-២១ ទៅចុះជាប់គ្រប់ការងារទៅមិនរួចទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា ។

[១៤:២៧:៣០]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

អរគុណលោកប្រធាន ។ ខ្ញុំកាត់សម្តីដោយស្ទាក់ស្ទើរនៅទីនេះ ខ្ញុំតាមពិតទៅខ្ញុំមិនចង់កាត់ការតាំងសំណួរនោះទេ ។ ប៉ុន្តែ ខ្ញុំសង្កេតឃើញថាវាហាក់ដូចជាចម្លែក ថាវាទាក់ទងទៅនឹងការដំណើរការ ស-២១ ទៅវិញទេ ចំពោះសំណួរទាំងអស់នោះទេ ។ ហើយសហព្រះរាជអាជ្ញានឹងធ្វើការស្វែងយល់អំពីខ្លឹមសារចំពោះអង្គហេតុនោះ នៅពេលមួយសមស្រប ។ ហើយខ្ញុំដឹងថា លោកចៅក្រម លោកស្រីចៅក្រម នឹងមានសំណួរច្រើនអំពីប្រតិបត្តិការនិងភាពជាក់ស្តែងចំពោះការសួរចម្លើយ ។ ហើយខ្ញុំសូមជម្រាប និងអនុញ្ញាតឲ្យលោកប្រធាន និងអង្គសវនាការធ្វើការជម្រាបទៅដល់ភាគីឲ្យតាំងសំណួរឲ្យបានត្រឹមត្រូវ ដើម្បីកុំឲ្យចូលទៅដល់ការដំណើរទៅលើ ស-២១ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញា ។ អង្គជំនុំជម្រះបានរំឭកច្រើនលើកច្រើនសាហើយ ទាំងការចាប់ផ្តើម អាចថាស្ទើរតែរាល់ថ្ងៃ យើងបានរំឭកពីបញ្ហានេះ ហើយបន្តបន្ទាប់យើងបានរំឭកជាញឹកញាប់នៅក្នុងករណីដែលការតាំងសំណួរទៅឃើញមានបញ្ហា ។ ប៉ុន្តែ យើងក៏ទទួលស្គាល់ផងដែរថា ការតាំងសំណួរមានភាពវែងឆ្ងាយរបស់អ្នកតាំងសំណួរនោះព្យាយាមប្រើពាក្យមួយ ដែលអង្គជំនុំជម្រះកំពុងតែពិចារណានូវបទពិសោធន៍ក្នុងការអនុវត្តប៉ុន្មានថ្ងៃកន្លងមកនេះ អំពីប្រើពាក្យថា "សូមសួរបញ្ជាក់" ។ នេះហើយដែលវានាំមានការលំបាកនៅក្នុងការកាត់គាត់ ព្រោះការបញ្ជាក់នូវអ្វីដែលវាមានភាពមិនច្បាស់ដោយហេតុផលការឆ្លងកាត់ នៃការបកប្រែភាសា ដែលនាំឲ្យការទទួលព័ត៌មាននឹងមិនគ្រប់គ្រាន់ ទើបគាត់សួរបញ្ជាក់ ។ ហើយប្រសិនបើយើង ការសួរបញ្ជាក់នេះហើយ យើងកាត់មិនឲ្យគាត់សួរទៀតនោះបានន័យថាភាពដែលមិនច្បាស់លាស់ វានៅតែមិនច្បាស់លាស់ដដែល ។

អ៊ីចឹងបានជាមានការចាប់អារម្មណ៍លើបញ្ហានេះ បានអនុញ្ញាតឲ្យសួរ ។ អ៊ីចឹង គឺជាសាជាថ្មីម្តងទៀត គឺរំឭកភាគីទាំងអស់ដែលចូលរួមនៅក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការតាំងសំណួរទៅជនជាប់ចោទ សូមប្រឹងប្រែងឲ្យអស់ពីលទ្ធភាព និងពីសមត្ថភាពរបស់ខ្លួន ទាំងការសិក្សាស្រាវជ្រាវ ទាំង

ការរៀបចំសំណួរទៅជនជាប់ចោទ គឺសូមឲ្យសួរនៅក្នុងរង្វង់អង្គហេតុ ដែលមកពិភាក្សាដេញដោល ។

ហើយបញ្ហាទីពីរ សូមព្យាយាមសាជាថ្មីម្តងទៀត អំពីរបៀបតាំងសំណួរ សុំសួរឲ្យច្បាស់ ឲ្យចំបញ្ហាដើម្បីអ្នកទទួលរងស្តាប់នូវសំណួរនោះគឺយល់ ងាយយល់ ហើយនិងកាលណាយល់បាននូវសំណួរហើយគឺអាចឆ្លើយតបច្បាស់លាស់នឹងសំណួរនោះហើយ ។

[១៤:៣០:៤៨]

បន្តទៀត ហើយប្រហែលជាអាចកំណត់ថាពេលវេលាដូចជាចំណាយពេលច្រើនហើយ ស្ទួត ហ្សីនស្គី អាចអនុញ្ញាតមួយសំណួរទៀត ដើម្បីសួរទៅជនជាប់ចោទ ដើម្បីមុននឹងផ្ទេរទៅឲ្យមេធាវីក្រុមបន្ទាប់ ។

**លោកស្រី ស៊ីលយីស្ទួត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ។

**ស៖** ខ្ញុំមានសំណួរចុងក្រោយមួយ ។ តើខ្ញុំត្រឹមត្រូវទេនៅពេលដែលខ្ញុំនិយាយថា លោកមានអំណាចដើម្បីធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនលោកផ្ទាល់ ដោយមិនចាំបាច់ស្នើយោបល់មេរបស់លោក? ហើយគឺថានៅពេលក្រោយមកទៀត ទើបលោកធ្វើការរាយការណ៍ទៅមេរបស់លោក ប៉ុន្តែគឺថាបន្ទាប់ពីលោកបានធ្វើសេចក្តីសម្រេចចិត្តរួចហើយ ។

ហើយទីពីរ គឺលោកមានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនលោកផ្ទាល់ ដោយមិនចាំបាច់ធ្វើសេចក្តីរាយការណ៍ទៅថ្នាក់លើទេ?

**ឆ៖** សូមគោរពលោកប្រធានជាទីគោរព! ខ្ញុំសូមឆ្លើយតបនឹងសំណួររបស់ កញ្ញា ស្ទួតហ្សីនស្គី ជាទ្រីស្តី ។ អំណាចសម្រេចចិត្តរបស់ខ្ញុំនៅក្នុងក្របខ័ណ្ឌមន្ទីរស-២១ មានពីរ ។ ទីមួយ គឺសម្រេចចិត្តដោយមិនបាច់រាយការណ៍ជូនខាងលើ ។ ឧទាហរណ៍ ខ្ញុំបញ្ជាឲ្យមិត្ត ហ៊ ធ្វើកូនបន្ទប់តូចៗ នៅក្នុងបន្ទប់ធំ ដែលបារាំងហៅថា *សែលុយ អាំងឌីវីឌែល* នោះ ហ្នឹងអត់រាយការណ៍សោះ ។ ទីពីរ ខ្ញុំសម្រេចជ្រើសរើសយកជើងឯកដើម្បីជាកន្លែងពិឃាត និងកប់សាកសពជនរងគ្រោះដែលយើងខ្ញុំបានសម្លាប់ហើយ ។ ខ្ញុំសម្រេចជ្រើសរើសរួចហើយ បានខ្ញុំរាយការណ៍ជូនមេជាព័ត៌មាន ។

នេះអំណាចសម្រេចរបស់ខ្ញុំ ដែលខ្ញុំធ្វើមានលក្ខខណ្ឌពីរនេះ មានពិតប្រាកដ ។

**លោកស្រី ស៊ីលយីស្ទួត ហ្សីនស្គី៖**

សូមអរគុណ ។ ខ្ញុំអត់មានសំណួរទៀតទេ ។

[១៤:៣៤:២៥]

**ប្រធានអង្គជំនុំ៖**

ដូចជាកិច្ចបន្ត សូមអញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី បើសិនជាមានសំណួរសួរដល់ជនជាប់ចោទ ។ សូមអញ្ជើញ ។

**សួរដោយ លោក ហ្វីលីព កាណុន៖**

ដោយមានការអនុញ្ញាតរបស់លោកប្រធាន ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរ ។

**ស៖** លោក កាំង ហ្គេកអ៊ាវ ខ្ញុំបានឮការរំឭក ដែលលោកប្រធានបានចេញមកហើយ ហើយនិងអ្វីដែលលោកសហព្រះរាជអាជ្ញា បាននិយាយហើយ ។ ឥឡូវនេះ យើងនិយាយអំពីគុកនៅតាខ្មៅ ហើយនិងយើងនិយាយអំពីការបង្កើតស-២១ ។ នេះគឺជាចំណុចពីរ ហើយខ្ញុំនឹងសួរសំណួរលោកទាក់ទងទៅនឹងអង្គហេតុតែពីរនេះទេ ។ សូមអរគុណ ។

នៅកាលព្រឹកថ្ងៃច័ន្ទលោកបានប្រាប់ពួកយើងថា នៅ ស-២១ យើងត្រូវទទួលអ្នកទោសសំខាន់ៗ ហើយខ្ញុំក៏បានឮទៀតផងថា គឺសមមិត្តហ៊ី ជាអ្នកទទួលបន្ទុកអ្នកទោសសំខាន់ៗ ។ តើមានន័យថាម៉េចទៅអ្នកទោសសំខាន់ហ្នឹង? ខ្ញុំចង់ឲ្យលោកពន្យល់ប្រាប់បន្តិចមើលអំពីអ្នកទោសសំខាន់ៗនេះ?

**ឆ៖** លោកប្រធានជាទីគោរព! សំណួររបស់លោក កាណុន ថាមិត្តហ៊ី ទទួលខុសត្រូវអ្នកជាប់គុកគន្លឹះ តើពាក្យ *"ព្រីហ្សិនញ៉េក្លេ"* ប្រែពីពាក្យគន្លឹះមែនរបស់ខ្ញុំ ឬយ៉ាងម៉េច? ខ្ញុំអត់ទាន់ ច្បាស់ទេ ក៏ប៉ុន្តែសុំសាកល្បងនិយាយ ជម្រាបទៅ ។

ខ្ញុំជឿថាលោក កាណុន ស្តាប់មិនច្បាស់ មិត្តប៉ុន ហើយនិងមិត្តហ៊ី ។ មិត្ត ប៉ុនៗ ជាកម្មាភិបាលមួយរូបទទួលភារកិច្ចសួរចម្លើយតែអ្នកទោសសំខាន់ នេះពិតៗ។ ចំណែកមិត្ត ហ៊ី គ្នាជាអនុប្រធានរត់គ្រប់កិច្ចការ ។

**ស៖** អ៊ីចឹង ខ្ញុំសូមបន្ថែមទៅលើសំណួររបស់ខ្ញុំទៀត ។ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ តើលោកបាននិយាយថា ខ្ញុំនិយាយអំពីការរៀបចំនៅពេលនេះ តើលោកបាននិយាយថា អ្នកទោសដែលលោកត្រូវទទួលយកនោះ គឺមិនមែនជាអ្នកទោសធម្មតាទេ ? អ៊ីចឹង តើគេប្រាប់លោកថាម៉េច តើអ្នកទោសនោះជាអ្នកប្រភេទណាទៅ សូមលោកបញ្ជាក់ពីចំណុចនេះឲ្យច្បាស់មើល?

**ឆ៖** លោកប្រធានជាទីគោរព! ខ្ញុំសូមអនុញ្ញាតៗ ឆ្លើយនឹងសំណួររបស់ កាណុន ដូចតទៅ៖

ជនណាដែលសំខាន់មេប្រាប់ៗ មុនៗនឹងចាប់ទៅទៀត នេះខ្ញុំសូមឆ្លើយខ្លីមេប្រាប់ ។

**ស៖** អ៊ីចឹងតើគេមានប្រាប់លោកទេ ថាហេតុអ្វីបានជាជនទាំងអស់ហ្នឹងត្រូវបានគេចាប់នោះ?

**ឆ៖** លោក កាណុន, យើងខ្ញុំធ្វើការជាប់ជាមួយនឹងមេពីរឿងចម្លើយទៅប៉ះបុគ្គលផ្សេងៗ ។ ដូច្នេះមុននឹងចាប់មនុស្សសំខាន់មកនោះមេប្រាប់ នេះ ។ ដូច្នេះ គឺយើងខ្ញុំដឹងសំណុំរឿងខ្លះៗពីមុនដោយសារចម្លើយអ្នកផ្សេងទៀតគេឆ្លើយដាក់រួចទៅហើយ និងសូមជម្រាបខ្លីប៉ុណ្ណឹង ។

[១៤:៥០:០៩]

**ស៖** បើអ៊ីចឹង ដោយខ្លី គឺថាមានន័យថាលោកបានដឹងហើយថា អ្នកទាំងនោះ គឺជាអ្នកដែលធ្វើការសំខាន់នៅក្នុងរដ្ឋាភិបាលជំនាន់នោះ មិនអ៊ីចឹង?

**ឆ៖** លោក កាណុន សូមទោសលោកនិយាយនេះត្រូវហើយ ក៏ប៉ុន្តែរួមពេល-- អ្នកទទួលខុសត្រូវកម្រិតណា ។ ដំបូងអ្នកដែលសំខាន់ចូលមក ស-២១ ត្រឹមតែអនុលេខាកងពលក៏យើងទុកជាសំខាន់ណាស់ហើយ ។ ដល់ចុងបញ្ចប់មកសំខាន់មែនទែនត្រឹម កុយ ធួន សមាជិកមជ្ឈិមពេញសិទ្ធិ មេឲ្យដឹងមុនមួយថ្ងៃពីរ ។

**ស៖** អ៊ីចឹង តាមដែលខ្ញុំយល់អ្វីដែលលោកនិយាយហ្នឹង គឺថាតាមពិតម្សិលមិញ ឬក៏ម្សិលម៉្ងៃលោកបានពន្យល់ប្រាប់យើងថា នូវវិធីដែលអ្នកយាមបានធ្វើការនៅក្នុងមន្ទីរ ។ អ៊ីចឹង ខ្ញុំមិនចង់និយាយអំពីចំណុចនោះវិញទេ ខ្ញុំយល់ច្បាស់ហើយ ប៉ុន្តែនេះជាសំណួររបស់ខ្ញុំន៎ ។ តើនរណាគេជាអ្នកទៅយកអ្នកទោសនោះ ដែលត្រូវទៅយកមកមន្ទីរស-២១ នោះ? តើជាអ្នកយាមនៅទីនោះ ឬក៏នរណាគេផ្សេង?

**ឆ៖** ក្នុងការអនុវត្តយើងមិនអាចនិយាយមួយម៉ាត់បានទេ យើងត្រូវនិយាយភាគច្រើនអ្នកទោសគេបញ្ជូនមកស-២១ ដោយអង្គភាពរបស់គេ ។ ដោយឡែក--

**ប្រធានអង្គជំនុំ៖**

គិតថា ជនជាប់ចោទមិនបាច់ឆ្លើយនឹងសំណួរហ្នឹងទេ ព្រោះសំណួរហ្នឹងពាក់ព័ន្ធជាមួយ នឹងប្រតិបត្តិការស-២១ អំពីអង្គហេតុនៃការចាប់ខ្លួន និងការចាប់ និងការបញ្ជូនជនរងគ្រោះមកស-២១ ។ អ៊ីចឹងទុកសំណួរនេះឆ្លើយតបនៅក្នុងអង្គហេតុប្រតិបត្តិការស្តីពីការចាប់ខ្លួន និងការបញ្ជូនជនរងគ្រោះទាំងឡាយពីតំបន់នានាមកស-២១ ។ មេធាវីអាចប្តូរសំណួរថ្មី ។

**លោក ហ្វីលីព កាណុន៖**

ខ្ញុំគ្រាន់តែចង់និយាយថា លោក ឌុច កំពុងតែឆ្លើយសំណួររបស់ខ្ញុំហើយ ហើយជាការអភ័ព្វណាស់ដែលមានការរំខានគាត់នោះ ។ ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ថា ខ្ញុំមិនចង់សួរ មិនសួរទាក់ទងទៅ

នឹងប្រតិបត្តិការរបស់មន្ទីរ ស-២១ ទេ ។

[១៤:៤៣:៤៦]

**ប្រធានអង្គជំនុំ៖**

តែលោកបានលើកឡើង សួរសំណួរពាក់ព័ន្ធនឹងការចាប់ខ្លួន បញ្ជូនមកមន្ទីរស-២១ វាជាអង្គហេតុដែលនឹងសួរដេញដោលនៅក្នុងអង្គហេតុប្រតិបត្តិការស-២១ ដែលជាអង្គហេតុដើមដំបូងនៃអង្គហេតុផ្តើមប្រតិបត្តិការ ។ យើងប្រើសិទ្ធិក្នុងការបញ្ឈប់លោកមិនឱ្យសួរសំណួរនេះ ហើយទាំងជនជាប់ចោទមិនឱ្យឆ្លើយនឹងសំណួរនេះ ។ បើលោកប៉ុនប៉ងចង់សួរទុករក្សាសំណួរនេះទៅសួរនៅក្នុងអង្គហេតុប្រតិបត្តិការស-២១ ស្តីពីការចាប់ខ្លួនមនុស្ស និងការបញ្ជូនមនុស្សពីកន្លែងចាប់មកកាន់ស-២១ ហើយគ្មានការបកស្រាយទេ ។ សំណួរអាចសួរថ្មីបាន ហើយបើចង់សួរសំណួរពាក់ព័ន្ធ សូមរៀបចំសំណួរឱ្យត្រូវនឹងអង្គហេតុនៃការបង្កើតស-២១ ។

**សួរដោយ លោក ហ្វ៊ីលីព កាណុន៖**

ខ្ញុំបានយល់ច្បាស់ហើយលោកប្រធាន ហើយខ្ញុំនឹងអនុវត្តតាមឱ្យបានពេញលេញនូវអ្វីដែលលោកប្រធានបានមានប្រសាសន៍ ។ អ៊ីចឹង ខ្ញុំនឹងសួរសំណួរហ្នឹងឯងនៅដំណាក់កាលក្រោយបន្តទៀត ។

**ស៖** លោក ឌុច ឥឡូវនេះ ខ្ញុំនឹងសួរលោកនូវសំណួរមួយទាក់ទងទៅនឹងការរៀបចំនៃការបង្កើតស-២១ ។ លោកបានជម្រាបប្រាប់យើងថា ក្រុមអ្នកថតរូបនៅក្នុងអង្គការចាត់តាំងហ្នឹងឯងត្រូវបានបង្កើតឡើង ។ ហើយសំណួររបស់ខ្ញុំនោះគឺថា នៅក្នុងការរៀបចំផែនការ នៅក្នុងផែនការ ខ្ញុំមិននិយាយអំពីប្រតិបត្តិការទេ ខ្ញុំនិយាយអំពីការរៀបចំផែនការ ។ តើអ្វីទៅដែលត្រូវការធ្វើក្នុងការរៀបចំការថតរូបនោះ ដើម្បីប្រយោជន៍អ្វីទៅ?

**ឆ៖** បើខ្ញុំឆ្លើយអានេះ វាចូលទៅក្នុងកិច្ចដំណើររបស់ស-២១ ទៀតហើយ ខ្ញុំសូមផ្អាកមិនទាន់ឆ្លើយជូនលោកទេ ។

**ស៖** នៅក្នុងចម្លើយរបស់លោកកាលពីម្សិលមិញ និងម្សិលម៉្ងៃ លោកបាននិយាយថា ឥឡូវនេះខ្ញុំ និយាយអំពីការរៀបចំ ការរៀបផែនការនៅឡើយទេ ។ ពេលនោះលោកបាននិយាយថា បើលោកនឹងមានទីរសាដើម្បីប្រមូលយកនូវចម្លើយសារភាព ជាពិសេស គឺចម្លើយសារភាពសម្ងាត់បំផុតនោះ ។ អ៊ីចឹង តើចម្លើយសារភាពហ្នឹង តើដើម្បីយកទៅធ្វើអ្វីទៅ? មានប្រយោជន៍អ្វីទៅ? ខ្ញុំនិយាយនេះ គឺខ្ញុំនិយាយអំពីការរៀបចំ ការគ្រប់គ្រងនោះទេ ខ្ញុំមិននិយាយអំពីប្រតិបត្តិការទេ ។

 

**ឆ៖** ឥឡូវថា *ប្រេប៉ារ៉ាហ្សុង* ក៏ថាទៅចុះ ។ ប៉ុន្តែ ខ្ញុំគ្រាន់តែៗថា គាត់មិនមែនជាអ្នកទៅស្រង់ចម្លើយទេ បានចម្លើយមកខ្ញុំហុចទៅឲ្យគាត់វៃម៉ាស៊ីន ចម្លើយនេះបានមកខ្ញុំ ហើយខ្ញុំឲ្យគាត់វៃម៉ាស៊ីនៗ។

[១៤:៤៨:២៦]

**ស៖** សំណួររបស់ខ្ញុំ គឺវាច្បាស់លាស់ជាងហ្នឹងបន្តិច ។ អ៊ីចឹង នៅពេលដែលរៀបចំទទួលចម្លើយសារភាពនោះ ហើយចម្លើយសារភាពដែលសម្ងាត់បំផុត គឺមានន័យថាសម្រាប់បុគ្គលមួយចំនួន អ៊ីចឹង តើពាក្យដែលថា "ចម្លើយសារភាពសម្ងាត់បំផុត" នោះមានន័យថាម៉េច?

**ឆ៖** សេចក្តីសារភាពដែលសម្ងាត់បំផុតនោះ គឺសេចក្តីសារភាពដែលប៉ះពាល់ដល់កម្មាភិបាលខ្ពស់បំផុត ។

**ស៖** ឥឡូវនេះ គឺខ្ញុំនៅតែនិយាយក្នុងដំណាក់កាលរៀបចំនៅឡើយទេ ។ ហេតុអ្វីបានជាលោកគិតថា សេចក្តីសារភាពដែលទទួលបានពីបុគ្គលដែលមានឋានៈខ្ពស់បំផុតនោះ គឺជាចម្លើយសារភាពដែលសម្ងាត់បំផុតនោះ?

**ឆ៖** នេះវាចូលទៅក្នុងការដែលឲ្យអត្ថន័យអំពីពាក្យ ដែលហៅថា "សម្ងាត់បំផុត" នេះពីព្រោះវាទាក់ទងទៅនឹងកម្មាភិបាលខ្ពស់បំផុត ។ ពីព្រោះបើសិនជាបែកការណ៍ធ្វើឲ្យមានបញ្ហាច្រើនណាស់ ខ្ញុំគ្រាន់តែសូមបញ្ជាក់ថាបញ្ហាច្រើនណាស់ តែប៉ុន្នឹងងបានហើយ កុំសួរតទៅទៀត ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំនាទី រហូតដល់ម៉ោងបីប្រាំនាទីនាទី អញ្ជើញចូលវិញ ។ ហើយលោកមេធាវីនៅសល់សំណួរផ្សេងទៀតចាំក្រោយពេលចូលសូមបន្តសំណួរទៀត ។

*[សវនាការសម្រាកពីម៉ោង ១៤:៥១នាទី ដល់ម៉ោង ១៥:១២នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចពិភាក្សាដេញដោលតទៅទៀត ។ ហើយមុននឹងជូនវេទិកានេះទៅដល់មេធាវីក្រុមបី ដែលអាចនឹងបន្តសំណួររបស់ខ្លួនចំពោះជនជាប់ចោទ ។ អង្គជំនុំជម្រះសូមរំឭកដល់ជនជាប់ចោទថា សូមជនជាប់ចោទរក្សានូវអាកប្បកិរិយាសមរម្យ ថ្លៃថ្នូរដើម្បីតប ឬក៏អនុវត្តសិទ្ធិមិន

ឆ្លើយតបទៅនឹងសំណួររបស់មេធាវីនោះ ជៀសវាងយើងមានការសើចអីអ៊ីចឹងទៅ អាកប្បកិរិយាមិនសមរម្យ ។

អញ្ជើញមេធាវីក្រុមបី ប្រសិនបើនៅមានសេសសល់សំណួរ គឺអាចបន្តសួរដល់ជនជាប់ចោទតទៅទៀតបាន ។

**សួរដោយ លោក ហ្វីលីព កាណុន៖**

**ស៖** អរគុណលោកប្រធាន ខ្ញុំមានសំណួរបន្ថែមមួយចំនួនតូចតែប៉ុណ្ណោះ ។ លោកជនជាប់ចោទក្នុងអំឡុងពេលការរៀបចំផែនការចំពោះការបង្កើតស-២១ ។ ខ្ញុំចង់ដឹងនៅពេលនោះ នរណាគេប្រាប់លោក ប្រាប់លោកថា នៅៗពេលដែលអ្នកទោសចូលមកដល់ក្នុងកន្លែងនេះ គឺអ្នកទោសនឹងត្រូវគេសម្លាប់ ។ តើអ្នកណាគេប្រាប់ដូច្នោះ?

**ឆ៖** នេះវាជាក្រឹត្យក្រមដែលមន្ទីរស-២១ អនុវត្តចាប់តាំងពីកកើតមក ។ តែចូលមកហើយត្រូវតែសួរចម្លើយកម្ទេច អត់មានលើកលែងទេ ។

**ស៖** ប្រសិនបើខ្ញុំយល់ត្រឹមត្រូវនោះៗជាក្រឹត្យក្រម តើបុគ្គលណាប្រាប់លោក? សំណួររបស់ខ្ញុំគឺចង់បញ្ជាក់ដូច្នេះ ។

**ឆ៖** យើងនិយាយថា អ្នកណាប្រាប់ពិបាកនិយាយណាស់ ព្រោះក្រឹត្យក្រមនេះអនុវត្តតាំងពីមន្ទីរ១៣ មកម្ល៉េះ ។ ដូច្នេះ វាជាមាគ៌ាបក្ស ជាគោលការណ៍បក្សចំពោះខ្មាំង ។

**ស៖** លោក ឌុច យើងអាចនិយាយថា មានការរៀបចំផែនការមួយបែប គឺការរៀបចំផែនការមួយបែបចំពោះអ្នកដែលត្រូវធ្វើយ៉ាងណាឲ្យគេបាត់ខ្លួន ។ តើមានផែនការមួយបែបអ៊ីចឹងដែរឬទេ?

[១៥:១៤:៣២]

**ឆ៖** ខ្ញុំមិនដឹងទេ មិនដឹងគេមានប្លង់ៗ ឬក៏មានបំណងអីយ៉ាងម៉េចទេ ។

**ស៖** សូមអរគុណ។ លោក ឌុច ខ្ញុំចង់ឲ្យលោកគិតមើល គឺអ្វីៗគឺវាដំណើរការនៅទីនោះ ថាតើមានប្រជាជនប៉ុន្មានដែលត្រូវស្លាប់ ប្រសិនបើប្រតិបត្តិការមន្ទីរនោះមិនបញ្ចប់ទេនោះ?

**ឆ៖** ឧក្រិដ្ឋកម្មហ្នឹងវាមានទំហំធំធេងណាស់ មិនដឹងជាថ្ងៃណាចប់ទេ នេះជារឿងពិត ។ អត់មានអ្នកណាប៉ាន់ថាយ៉ាងម៉េចទេ ។

**ស៖** សំណួរមួយទៀតដែលជាសំណួរចុងក្រោយរបស់ខ្ញុំ ។ លោកបាននិយាយជាមួយយើងខ្ញុំអំពីកុម្មុយនីស្តនិយម លោកនិយាយអំពីសង្គមនិយម ហើយលោកនិយាយអំពីបក្ស ហើយពីរបីដង

លោកបានលើកឡើងអំពីអង្គការ ហើយកម្ពុជានៅពេលនោះ គឺមិនបានឮអំពីកុម្មុយនីស្ត ហើយនិងសង្គមនិយមទេ គេឮតែអង្គការបានលើកឡើង ។ តើលោកអាចបញ្ជាក់ពន្យល់បន្តិចទេ ដើម្បីយើងខ្ញុំបានយល់ថាតើអ្វីទៅជាអង្គការនោះ? ហើយលោកអាចពន្យល់ឲ្យបានស្រួលៗនិងងាយៗ ដើម្បីឲ្យយើងអាចយល់អំពីអ្វីដែលលោកបានលើកឡើង ។

**លោក ការ សាវុត្ថ៖**

សូមអនុញ្ញាតលោកប្រធាន សូមជម្រាបមេធាវីខាងណោះ សួរៗតែពីអ្វីដែលជាការបង្កើតស-២១ និងអ្វីដែលជាការបង្កើតគុកនៅតាខ្មៅ ។ សូមកុំឲ្យសួរប្រាសចាកប្រធាន ។ សួរពីអង្គការ សួរពីស្អីអាន់ុងវាដូចជាមិនមែនជាស-២១ ការបង្កើត ស-២១ ទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់លោកមេធាវីការពារក្តីមានប្រសិទ្ធភាព ហើយលោក កាណុន សូមបញ្ចប់សំណួរលោកត្រឹមនេះ ហើយអង្គជំនុំជម្រះសូមជម្រាបលោក កាណុន ថាលោកមានឱកាសនៅក្នុងការសួរសំណួរនេះដល់ជនជាប់ចោទនូវអង្គហេតុមួយទៀត គឺអង្គហេតុបន្ទាប់នេះ គឺអនុវត្តគោលនយោបាយនៅស-២១ ។

**លោក ហ្វីលីព កាណុន៖**

[១៥:២០:០៩]

ដូច្នេះ ខ្ញុំនឹងសួរសំណួរនោះឲ្យបានសមស្របនៅពេលសមស្រប ។ ខ្ញុំសូមឲ្យធ្វើការសង្កេតនៅត្រង់នេះបន្តិច ។ យើងនិយាយអំពីការរៀបចំៗផែនការ ហើយយើងក៏និយាយអំពីទស្សនទាន ឬក៏ទស្សនៈនៃចំណុច ឬក៏ប្រធានបទអ្វីមួយ ។ ដូច្នេះខ្ញុំសូមឲ្យមេធាវីការពារក្តីផ្តល់មូលហេតុដែលគាត់បានលើកជំទាស់នេះ ។ ថាតើសំណួររបស់ខ្ញុំ វាមានបញ្ហាយ៉ាងម៉េច? ហើយគឺសំណួរទាក់ទងនឹងអង្គការការរៀបចំអង្គការនេះ តើវាប៉ះពាល់យ៉ាងម៉េច ឬក៏មានការជំទាស់យ៉ាងម៉េចទៅលើករណីនេះ? ដូច្នេះខ្ញុំសូមទៅលើមូលហេតុលើករណីនេះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយ ហើយសំណួរនេះគឺចប់ត្រឹមប៉ុណ្ណោះ ហើយជម្រាបម្តងទៀតថាសំណួរលោកដែលសួរពាក់ព័ន្ធជាមួយអង្គការ ជាមួយនឹងបក្ស ជាមួយនឹងអីផ្សេងៗនេះ គឺអង្គហេតុក្នុងការអនុវត្តគោលនយោបាយបក្សនៅស-២១ ហើយការលើកឡើងបង្ហាញរបស់មេធាវីការពារក្តីក្នុង

ការជំទាស់នេះសមរម្យ ដែលគួរត្រូវបានសំណួរនេះទៅប្រើប្រាស់នៅក្នុងអង្គហេតុបន្ទាប់នេះ ព្រោះអង្គហេតុបន្ទាប់ទៀតនេះ គឺអង្គសវនាការនឹងលើកពីអង្គហេតុជាក់លាក់មួយច្បាស់លាស់ គឺអង្គហេតុការអនុវត្តគោលនយោបាយបក្សនៅក្នុងមន្ទីរ ស-២១ ។

**លោក ហ្វ៊ីលីព កាណុន៖**

ខ្ញុំបានទទួលការកត់សម្គាល់អំពីចំណុចនេះហើយលោកប្រធាន ហើយខ្ញុំក៏គ្មានសំណួរអ្វីទៀតទេ ប៉ុន្តែ សហសេវិកកម្ពុជារបស់ខ្ញុំគាត់មានសំណួរបន្ថែមទៀត ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ។

**សួរដោយ លោក គឹម ម៉េងឃី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំ គឹម ម៉េងឃី មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីមានសំណួរមួយចំនួនដែលអាចសួរទៅជនជាប់ចោទផ្ទាល់ និងពាក្យដែលគាត់និយាយថា តួនាទីរបស់គាត់ជាប្រធាន ហើយគាត់កាន់តួនាទីមិនចូលផ្ទាល់ទៅនៅក្នុងការងារសួរចម្លើយទេ គឺគាត់វាយការណ៍។ ហើយវាយការណ៍ហ្នឹងគាត់បានបញ្ជាក់ថា វាយការណ៍ថាចាត់ទុកថាអ្នកណាជាខ្មាំង ។ អ៊ីចឹងខ្ញុំឆ្ងល់ថាតើគេសន្មតយ៉ាងដូចម្តេច ដែលបុគ្គលណាម្នាក់នោះជាខ្មាំង ជាជនបង្កប់ក្នុងជួរបដិវត្តន៍?

[១៥:២៣:៤៧]

**ឆ៖** លោកប្រធានជាទីគោរព! តាមខ្ញុំស្តាប់នេះក៏ដូចជាសំណួរចូលទៅក្នុងកិច្ចអនុវត្តមាគ៌ានយោបាយរបស់បក្សនៅក្នុងមន្ទីរស-២១ ហើយ ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតមិនឆ្លើយ ចាំឆ្លើយនូវលើកក្រោយជូនលោក គឹម ម៉េងឃី ។

**ស៖** សូមអនុញ្ញាតលោកប្រធាន! សំណួររបស់ខ្ញុំគិតថាវាពាក់ព័ន្ធទៅនឹងរបៀបវាយការណ៍ ។ អ៊ីចឹងបើរបៀបវាយការណ៍និយាយអំពីតួនាទីរបស់គាត់នៅក្នុងការបង្កើតមន្ទីរស-២១ ។ អ៊ីចឹង វាអាចពាក់ព័ន្ធទៅនឹងមាគ៌ាបក្ស ក៏ប៉ុន្តែបើសិនជាលោកមានឆន្ទៈឆ្លើយនៅពេលនេះ គឺសូមជនជាប់ចោទឆ្លើយបង្ហាញ ។

**ឆ៖** លោក ម៉េងឃី ជាទីគោរព! ខ្ញុំបានសូមអនុញ្ញាតលោកប្រធានហើយ ថាមិនទាន់ឆ្លើយលោកនៅពេលនេះទេ ។ យើងចាំទៅជួបគ្នានៅលើកក្រោយ រឿងក្រោយ ។

[១៥:២៥:០០]

**ប្រធានអង្គជំនុំ៖**

មេធាវីបន្តសំណួរផ្សេងទៀត ហើយកត់សម្គាល់សំណួរនេះ ចាំដល់អង្គហេតុបន្ទាប់សឹមសួរគេហៅថាសមស្រប ។ អ៊ីចឹងហើយបានជាយើងរំឭកម្តងហើយម្តងទៀត ប្រឹងប្រែងនៅក្នុងការសិក្សានូវសំណុំរឿងអំពីការបែងចែកអង្គហេតុនេះ ។ យើងគិតថាវាជាការលំបាកហើយនៅក្នុងអំឡុងពេលនៃការកើតឡើងតាំងពីដើមទី រហូតដល់ចប់នោះ វាអាចកើតហេតុ-- អង្គហេតុនៅក្នុងកាលៈទេសៈមួយ វាកើតអង្គហេតុច្រើន ។ ប៉ុន្តែ យើងញែកអំពីកិច្ចការណាដែលមានលក្ខណៈជាការរៀបចំ ជាការចាត់ចែងក្នុងការបង្កើតកិច្ចការណាជាកិច្ចប្រតិបត្តិការ ឬក៏ជាការអនុវត្តគោលនយោបាយ ។ អានឹងដើម្បីកុំឲ្យវាជាន់គ្នា ហើយគោលបំណងនេះគឺដើម្បីបង្រួញនៃ ពន្លឿននៃដំណើរការនីតិវិធីសវនាការរបស់យើងឲ្យបានលឿន ឲ្យបានឆាប់រហ័ស តាមដែលអាចធ្វើទៅបាន ហើយនិងងាយស្រួលក្នុងការចៀងវាង បាននូវការសួរសំណួរច្រំដែល ។

អ៊ីចឹងដូរសំណួរ ។ សំណួរនេះគឺជនជាប់ចោទបានលើកឡើងហើយ គឺរក្សាសិទ្ធិក្នុងការឆ្លើយនូវសំណួរដេញដោលនៅអង្គហេតុសមស្របនៅខាងមុខ ។

**សួរដោយ លោក គឹម ម៉េងឃី៖**

បាទ, សូមអរគុណ ។

**ស៖** សំណួរជាបន្ទាប់គឺ ពាក់ព័ន្ធទៅនឹងអង្គភាពពិសេស នៅក្នុងឯកសារដែលស្តីអំពីការព្រមព្រៀងអង្គហេតុ E5/11 និងចំណុច៦ លោកបានបញ្ជាក់ថា តួនាទីរបស់ប្រធានអង្គភាពពិសេសបានត្រូវធ្លាក់ទៅលើ ហ៊ឹម ហ៊ុយ ហើយអង្គភាពនេះ មានភារកិច្ចចាំបាច់មួយចំនួនដូចជាត្រូវទទួលអ្នកទោសដែលបញ្ជូនមកស-២១ យកអ្នកទោសទៅជួបប្រធានអង្គភាពការពារ ធ្វើអន្តរាគមន៍ក្នុងករណីបន្ទាន់ និងអនុវត្តការប្រហារជីវិត ។ នៅក្នុងហ្នឹងដាក់ថា "យល់ព្រម" ។ សំណួរសួរបញ្ជាក់ទៀតថា តើអង្គភាពពិសេសហ្នឹងមានសមត្ថកិច្ចក្នុងការចុះចាប់ដោយផ្ទាល់ ដោយមិនចាំបាច់មានការបញ្ជាពីថ្នាក់លើ ឬក៏រាយការណ៍ទៅថ្នាក់លើដែរឬទេ?

[១៥:២៧:៣៣]

**ឆ៖** លោកប្រធានជាទីគោរព! បញ្ហាចាប់ យើងខ្ញុំបាននិយាយជម្រាបលោកព្រះរាជអាជ្ញាខ្មែររួចហើយ លោកសួរខ្ញុំថាពីដើមមកដូចជា ស-២១ ហ្នឹងមិនចង់ទទួលស្គាល់ថាខ្លួនចេញទៅចាប់ ។ អាម៉េចអ៊ីចុង? ហើយខ្ញុំបានបញ្ជាក់ច្បាស់លាស់រួចទៅហើយ ។ ដូច្នេះ វាចូលទៅសំណួរជាន់ដាននឹងសំណួរ

របស់លោកព្រះរាជអាជ្ញាខ្មែរ ។ សូមលោកពិនិត្យចម្លើយរបស់ខ្ញុំ ដែលខ្ញុំបានរាយការណ៍ជូនលោកព្រះរាជអាជ្ញាខ្មែរទៅទៀតចុះ ។

**ស៖** សូមអរគុណ ។ អ៊ីចឹងពាក់ព័ន្ធទៅនឹងសំណួរមួយទៀត ទាក់ទងទៅនឹងតួនាទីរបស់លោកនៅក្នុងការបង្កើតមន្ទីរស-២១ លោកធ្លាប់អះអាងថាលោកជាអ្នកបង្រៀននូវមនោគមន៍វិជ្ជា និងទស្សនៈដល់អ្នកសួរចម្លើយ និងបុគ្គលិកនៅមន្ទីរស-២១ ។ តើលោកអាចរៀបរាប់បានទេ ថាតើមនោគមន៍វិជ្ជានោះគេបង្រៀនទៅលើមនោគមន៍អ្វីខ្លះ? ហើយផ្តោតសំខាន់ទៅលើបញ្ហាអី?

**ឆ៖** សូមជម្រាបលោក ម៉េងឃី ថា ខ្ញុំបានរាយការណ៍ជូនអ្នកណាដូចព្រះរាជអាជ្ញា អាឡិច សាន់ឌី ប៉េត ពីរឿងរបៀបរៀន ។ ដំបូងខ្ញុំបានរាយការណ៍ជម្រាបជូនលោកចៅក្រមឡាវ៉ែនរួចហើយ អំពីរបៀបរៀន ។ ទីមួយគឺរៀនប្រចាំឆ្នាំ ហើយទីពីរ ក្នុងមួយឆ្នាំឯកសារវាមានបីជំពូក ។ មាននយោបាយ មានសតិអារម្មណ៍ មានចាត់តាំង ។ ក្រោយពីរៀននេះយើងខ្ញុំបំបែកគ្នាប្រជុំរៀនតាមក្រុមដើម្បីយល់ឯកសារស៊ីជម្រៅបានធ្វើប្រវត្តិរូបបដិវត្តន៍និងជីវទស្សន៍បដិវត្តន៍ ។ ដូច្នេះ ឯកសារមួយឆ្នាំទៅមួយឆ្នាំ ប្រែប្រួល គេបង្រៀនខ្ញុំក៏ប្រែប្រួល ខ្ញុំយកទៅបង្រៀនកូនចៅតទៅទៀតក៏ប្រែប្រួល ។

ដោយឡែក ការបង្រៀនបំពាក់គោលនយោបាយពីរឿងដាច់ខាតចំពោះខ្មាំងនៅក្នុងមន្ទីរ ស-២១ យើងខ្ញុំបង្រៀនកូនចៅតាមការដែលយើងខ្ញុំបានទៅជួបមេជាញឹកញាប់ ។ សភាពការណ៍ណាតម្រូវឲ្យខ្ញុំនិយាយយ៉ាងម៉េច ណែនាំយ៉ាងម៉េច ខ្ញុំនិយាយអ៊ីចឹង ។ ភស្តុតាងជាកំណត់ហេតុនៅសល់ មិនមែនជាកំណត់ហេតុទេ ជាសម្តីមេរៀនដែលខ្ញុំបង្រៀននៅសល់នៅក្នុងឯកសារដែលបង ម៉ម ណៃ កត់ត្រា ។

នេះសូមបញ្ជាក់ជូនបន្ថែមប៉ុណ្ណឹងឲ្យច្បាស់លាស់ជាចុងក្រោយ ។

**លោក គឹម ម៉េងឃី៖**

អរគុណលោកប្រធាន ។ ខ្ញុំមិនមានសំណួរអ្វីសួរដល់ជនជាប់ចោទ ។

**ប្រធានអង្គជំនុំ៖**

មេធាវីក្រុមបួន តើមានសំណួរអ្វីចង់សួរដល់ជនជាប់ចោទដែរឬទេ? បើមានសូមអញ្ជើញ ។ ហើយអង្គជំនុំជម្រះសូមជម្រាបដល់លោកមេធាវីក្រុមបួនដែរថា ឥឡូវនេះយើងចុងក្រោយគេ ហើយប្រហែលជាអង្គហេតុក្រោយ ប្រហែលជាលោកមានឱកាសនឹងតាំងសំណួរត្រឡប់មកវិញ ។ បានន័យថាទទួលសិទ្ធិមុនគេ នៅក្នុងការសួរម្តង ដើម្បីកុំឲ្យថាអត់សំណួរគេសួរអស់អ៊ីចឹង ។ អ៊ីចឹងគឺបើមានសំណួរសូមអញ្ជើញ ។

[១៥:៣១:១៥]

**សួរដោយ លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធានដែលបានយល់ ផ្ដល់អធ្យាស្រ័យខាងក្រុមទីបួនយើងខ្ញុំ ។ ហើយខ្ញុំបាទក៏សូមគោរពលោកប្រធាន លោកស្រី លោកចៅក្រមអង្គជំនុំជម្រះនៃអ.វ.ត.ក ម្ដងទៀត ។ ខ្ញុំបាទសូមសួរដោយត្រង់តែម្ដងកុំឲ្យថាខាតពេលវេលាវែងឆ្ងាយ ។ ទាក់ទងជាមួយនឹងការបង្កើតមន្ទីរ ស-២១ លោក ឌុច ខ្ញុំសួរលោក បើលោកស្ដាប់មិនច្បាស់សូមសួរមកខ្ញុំវិញ ។ ព្រោះលោកបានធ្លាប់មានប្រសាសន៍ហើយ ឬបើសិនជាលោកមិនចង់ឆ្លើយ សូមលោកឆ្លើយមួយម៉ាត់ថា មិនឆ្លើយទេ ។ ព្រោះកុំបាច់យើងវែងឆ្ងាយទៀត ។

**ស៖** មុនពេលលោកចូលកាន់ការងារនៅមន្ទីរស-២១ មានន័យថា លោក ណាត ដែលលោកបានជម្រាបអង្គសវនាការថា ជាប្រធានមុនលោក ។ តើ*ប៉េហ្ស៊ី* ជាឈ្មោះ-- *ប៉េហ្ស៊ី* ហ្នឹងគឺ កន្លែងប៉ូលិសពីរបប លន់ នល់ ។ អ៊ីចឹងនៅក្នុងក្រោយ ១៧ មេសា ១៩៧៥ ដាក់ឈ្មោះថាស-២១ ដែរឬទេ?

**ឆ៖** ស-២១ វាទៅតាំងទីកន្លែងសួរចម្លើយនៅនុ៎ង ។ ដូច្នេះឈ្មោះ ស-២១ ហ្នឹង នៅក្នុងមួយរយៈហ្នឹងវានៅលើអាប៉េហ្ស៊ី ហ្នឹងដែរ ។

**ស៖** សូមអរគុណ ។ ខ្ញុំច្បាស់ សួរខ្លីៗ ។ សំណួរទីពីរ ឈ្មោះថា មន្ទីរស-២១ លោកបានជម្រាបអង្គសវនាការថា មានទាក់ទងនឹងគុកតាខ្មៅផង គុកនៅព្រៃសផង អ៊ីចឹងមែនទេ?

**ឆ៖** តាមពិតព្រៃសមិនហៅគុកទេ ជាកន្លែងអប់រំសាថ្មីៗ យកមនុស្សទៅអប់រំតាមរយៈការធ្វើស្រែចម្ការ ជាពិសេសធ្វើស្រែ ។ ឯចំណែក គុកនៅតាខ្មៅ វាជាកម្មសិទ្ធិដំបូងរបស់កងពល៧០៣ ដល់ក្រោយមកជាកម្មសិទ្ធិរបស់ ស-២១ ដល់ក្រោយមកបានបញ្ជូនទៅសង្គមកិច្ចវិញ ។

**ស៖** សូមអរគុណ ។ សំណួរទីបី តើសាខារបស់មន្ទីរស-២១ ដូចលោកជម្រាបអង្គសវនាការអម្បាញ់មិញ ថាព្រៃសគឺជាមន្ទីរអប់រំកែប្រែ តើមានឈ្មោះមន្ទីរអប់រំកែប្រែនៅតំបន់ឈ្មោះស្ទឹងជ្រៅ ឬបាគូ ដែរឬទេ?

[១៥:៣៤:០៨]

**ឆ៖** ខ្ញុំមិនជាក់ស្ដែងទេណ៎ា ប៉ុន្តែបាគូដល់ក្រោយមកយើងខ្ញុំទៅកាន់កាប់ ។ អាស្ទឹងជ្រៅអត់ជាក់ស្ដែងទេ ។ ខ្ញុំអត់បានគិតគូរអំពីភូមិសាស្ត្រហ្នឹងទេ ។ ដូច្នេះ អនុម័តថា ប្រហែលជាអាចរបស់ព្រៃសហ្នឹង ។ ដីព្រៃសវាលាតសន្ធឹងទៅដល់នុ៎ង ។

**ស៖** សូមអរគុណ ។ អ៊ីចឹងចូលមកដល់ក្នុងបរិវេណនៃមន្ទីរ ស-២១ វិញ ។ សំណួរខ្ញុំសួរថា បរិវេណនៃវិទ្យាល័យពញាយ៉ាតហ្នឹងមួយឡែក ទីតាំងនៃទាក់ទងស-២១ លាតសន្ធឹង ដែលខ្ញុំមិនទាន់ច្បាស់នៅឡើយនោះ លោកមានប្រសាសន៍ថ្ងៃមុនថា ផ្លូវ៦៣៦-- ៦១៣ នោះ ខ្ញុំអត់ទាន់ច្បាស់ ព្រោះមានការបង្ហាញលើផែនទី ។ តើលោកអាចនិយាយបន្តិចឡើងវិញថា ហាក់ដូចជាកម្មសិទ្ធិទៅចុះរបស់ ស-២១ ទីតាំងនៅក្នុងក្រុងភ្នំពេញនោះ ដូចជាពីពេទ្យចិន ទៅទល់បូកគោ ទៅទាល់ផ្លូវម៉ៅសេទុង មកវត្តមហាមន្ត្រីអីនោះ ខ្ញុំសូមអនុញ្ញាតបង្ហាញបន្តិច តើវាជាបរិវេណធំហ្នឹងរបស់ស-២១ ទាំងស្រុងដែរឬទេ?

**ឆ៖** អរគុណលោក គឹមសួន ដែលលើកបញ្ហានេះដេញដោលខ្ញុំ ដើម្បីអង្គសវនាការបានជ្រាបពិតប្រាកដ មាននិន្នាការមួយគូរផែនទីស-២១ ទូលំទូលាយណាស់ ។ ខាងកើតទាល់ផ្លូវព្រះមុន្នីវង្ស ខាងលិចមែនមិនហួសពី៣៦០ ទេ ។ ក៏ប៉ុន្តែពីខាងជើងគេលេងផ្លូវព្រះសីហនុនោះ មានទាំងសាលាព្រះយុគន្ធរទៀត នៅខាងត្បូងផ្លូវម៉ាសេទុង ហ្នឹងលើ ។ ខាងជើងពិតប្រាកដគឺនៅត្រឹមតែលេខ៣១០ ទេ តាមគំនូសផែនទីដែលខ្ញុំគូរ ឆ្លងមួយផ្លូវជាទីកដីរបស់៥០២១ ។ មានម្តងនោះខ្ញុំ ទៅតាំងទីផ្ទះនៅនឹងផ្លូវខាងនោះផ្លូវ៣១០ មែន ។ ក៏ប៉ុន្តែដល់ក្រោយមកខ្ញុំចេញមកវិញ ខាង៥០២ គេប្រាប់ ខ្ញុំចេញមកវិញ ។ ដូច្នេះខាងជើងវានៅត្រឹមផ្លូវ៥០២ ខាងកើតនៅត្រឹមផ្លូវព្រះមុនីវង្ស ខាងលិចនៅត្រឹមផ្លូវលេខ៣១០ ខាងត្បូងមានហួសណ៎ា ខាងត្បូងយើងអាចចាត់ទុកផ្លូវ៣៦០ អាផ្លូវសំបុកឃ្មុំនេះ ថាជាគោលមួយហើយ ។ ក៏ប៉ុន្តែទីកដីរបស់ខ្ញុំវាហួសទៅណោះបន្តិច ទៅត្បូងបន្តិចទៀត មានមួយផ្ទះពីរផ្ទះ បួនប្រាំផ្ទះប៉ុនន៎ុង ។

ដូច្នេះ នៅភ្នំពេញកម្មសិទ្ធិរបស់ស-២១ ប៉ុណ្ណឹងឯង អត់លើសទៅដល់ទូលំទូលាយពេក ដូចលោក គឹមសួន សួរខ្ញុំន៎ុងទេ ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមសួរបន្តទៅទៀត អ៊ីចឹងតាមអ្វីដែលលោកជម្រាបក្នុងអង្គសវនាការនេះ ដោយសារមិនបានបង្ហាញលើគំនូសព្រួញ គំនូសប្លង់បង្ហាញទាំងអស់គ្នានោះ អាហ្នឹងយើងយល់ចំពោះការដែលយើងបានដឹងរួចខ្លះៗមកហើយ ។ ខ្ញុំសួរបន្តទៀតទាក់ទងនឹងស-២១ ដដែល តើផ្ទះ ឬកន្លែងឃុំឃាំងក្រៅពីបរិវេណនៃវិទ្យាល័យពញាយ៉ាតនោះ ក្នុងអំឡុងពេលលោកធ្វើជាប្រធាន តើមានការចាត់ចែងពីលោកឲ្យដាក់ផ្ទះណាសម្រាប់ជនបរទេស ដូចជាអឺរ៉ុបផ្សេង អាមេរិកាំងផ្សេង វៀតណាមផ្សេង ថៃផ្សេង ដែរឬទេ?

[១៥:៣៧:៥៦]

**ឆ៖** ខ្ញុំសូមឆ្លើយដ៏ខ្លីថា គុកពិសេសមិនងាយចូលទៅក្នុងបរិវេណវិទ្យាពញ្ញាយ៉ាតទេ ។ យើងខ្ញុំថែរក្សានៅខាងក្រៅ ហ្នឹងគុកពិសេសដែលមិត្ត ប៉ុន សួរចម្លើយ ។ ឈ្លើយសឹករៀតណាម មិនដែលទៅឲ្យមិត្តប៉ុន សួរចម្លើយទេ បង ម៉ម ណៃ សួរ ។ ដូច្នេះ ពួកអាមេរិកមាន ពួកអាមេរិក ពួកអូស្ត្រាលីមានទៅឲ្យមិត្តប៉ុន សួរ ។ ប៉ុន្តែ មិនដឹងទាំងបួននាក់ ឬក៏ពីរនាក់ យ៉ាងណាខ្ញុំអត់ច្បាស់ទេ ។ យើងចាំមើលឯកសារ តើអ្នកណាសរសេរ? ចម្លើយអ្នកណាសរសេរ? បើបង ម៉ម ណៃ សរសេរ គឺនៅឯណោះទេ នៅខាងកើតសារមន្ទីរទួលស្លែងបច្ចុប្បន្ន ។

ឯចំណែកគុកពិសេសនេះ ដល់ចុងពាក់កណ្តាលឆមាសទីពីរ ១៩៧៨ ហើយ បានចូលមកនៅអគារ *អា* “A” ទើបនឹងចូលមកក្រោយទេ ។ នេះសូមបញ្ចប់ប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ មិញលោកបានឆ្លើយបំភ្លឺសវនាការអំពីជនបរទេស លោកថាមិនដឹងជាពីរនាក់ ឬបួនប្រាំនាក់ទេជាជនជាតិអាមេរិកាំង ។ អ៊ីចឹងទេ?

**ឆ៖** យើងនិយាយពាក្យពួកបស្ចិមប្រទេស ។ យើងនិយាយពាក្យហ្នឹងវាស្រួលស្តាប់ជាងណ៎ា ។ ព្រោះមានអាមេរិកាំងដូចជាប៉ុន្មាននាក់ទេ ខ្ញុំមិនចាំ, អង់គ្លេសម្នាក់ ខ្ញុំជួប ខ្ញុំឃើញ, នូវែលហ្សេឡង់ម្នាក់, ក្រៅពីនុ៎ងដូចមានអូស្ត្រាលីទៀត ខ្ញុំមិនចាំ ។ ប៉ុន្តែ តែបួននាក់ទេ អត់លើស ។ ដូច្នេះ ក្នុងបួននុ៎ង មិត្តប៉ុនសួរចម្លើយពីរ អាចមួយគឺជនជាតិ នូវែលហ្សេឡង់ មិត្ត ប៉ុន សួរចម្លើយ ។

**ស៖** សូមអរគុណ ។ អ្វីដែលខ្ញុំចង់សួរ ចង់បានថាតើការចាត់ចំណាត់ថ្នាក់ជនបរទេស ជាពួកអ្នកទោសពិសេស ឬកម្មាភិបាលក្នុងជួរបដិវត្តន៍ ឬក៏ក្នុងបក្សកុម្មុយនីស្ត ជាអ្នកពិសេស ពីរហ្នឹង? តើទាំងពីរហ្នឹងពិសេសដូចគ្នា ឬក៏បែងចែងថាពិសេស ឬក៏មិនពិសេសតាមគោលការណ៍នៃការគ្រប់គ្រងស-២១?

**ឆ៖** លោក គឹមសួន! កម្មាភិបាលខ្មែរខាងលើណែនាំ អ្នកណាពិសេស មិនពិសេសណា មានកម្មាភិបាលជាជនជាតិខ្មែរ ឯចំណែកជនជាតិ នូវែលហ្សេឡង់ ម្នាក់ ហើយនិងអង់គ្លេសម្នាក់ ដែលមិត្តប៉ុន សួរ ខ្ញុំចាត់ចែងទេ ឃើញមិត្តប៉ុន ទំនេរគួរសម ខ្ញុំឲ្យសួរទៅ ។ ដូច្នេះ ពីរនាក់ផ្សេងទៀត មិនដឹងជាអ្នកសួរទេ ។

**ស៖** សូមអរគុណ ។ ជាគោលការណ៍ ព្រោះអ្វីដែលយើងនិយាយច្រើនមកហើយនេះ គឺកម្រមានឯកសារបង្ហាញណាស់ លោកក៏បានមានប្រសាសន៍ដែរថា ជាទូទៅគឺការអនុវត្តបន្ទរបស់បក្សដាក់ចុះអ៊ីចឹងខ្ញុំសួរថា នៅក្នុងស-២១ លោកបានបង្ហាញឯកសារពីរទាក់ទងនឹងថ្ងៃទី៣០ តុលា ៧៥ ឬក៏មីនា

៧៦ ពីរឯកសារធំៗហ្នឹងណ៎ា! ក្រៅពីឯកសារទាំងពីរនេះ តើលោកជាប្រធានមន្ទីរស-២១ មានចេញជាសារាចរដោយខ្លួនលោកជាប្រធានសម្រាប់អ្នកក្រោមបង្គាប់លោកដែរឬទេ?

**ឆ៖** លោក គឹមសួន សារាចរមួយ មិត្តហ៊ី គាត់ចេញ ។ ខ្ញុំយល់ស្របនឹងខ្លឹមសារនុ៎ង គេអត់ប៉ានក្បត់ទេ សម្រាប់កងការពារ មានប្រហែលជាបីទំព័រ បីបួនទំព័រអីហ្នឹង ។ ចំណងជើងដាក់ថាសារាចរ ។ ក្នុងមាននិយាយពីអត្ថបទ ពីរឿងលេបខ្មៅ លេបអីហ្នឹង អាហ្នឹងរបស់ខ្ញុំ ។ ពិត ។

**ស៖** សូមលោករំឮកឡើងវិញ ចេញមួយ ឬក៏ចេញពីរ ឬក៏ច្រើនជាង ឬក៏តិចជាង?

**ឆ៖** សារាចរ បើតាមខ្ញុំចាំ ហើយគេយកមកបង្ហាញខ្ញុំ គឺចេញតែមួយហ្នឹងទេ ។ អង្គាល់ដែលចេញណ៎ា សូមជម្រាបលោក គឹមសួន ដោយត្រង់ គេៗធ្វើ ខ្ញុំអត់ដឹង ។ ប៉ុន្តែ និយាយអ៊ីចឹង មិនមែនបានន័យថា យើងទម្លាក់គេទេណា ជាស្វ័យភាពរបស់ការងារគេ ធ្វើម៉េចឃុំឃាំងកុំឱ្យគេរត់រួច បក្សដាក់ទោសគេ ។ អាហ្នឹងជាសិទ្ធិស្វ័យភាពរបស់គេហើយ ។ ដូច្នេះ តែមួយដែលខ្ញុំឃើញ ។

**ស៖** សូមអរគុណ ខ្ញុំសួរលោកទាក់ទងនឹងសារាចរនេះដដែល នេះជាការបង្គាប់ពីថ្នាក់លើ ជាមេរបស់លោកឬ ជាការយល់របៀបគ្រប់គ្រងដែលលោកចេញសារាចរនេះ?

[១៥:៤២:៤៩]

**ឆ៖** ជាពិសោធន៍ចាស់របស់មិត្ត ហ៊ី តាំងពីកងពល៧០៣ ដូច្នេះជាពិសោធន៍របស់កងទ័ព ខាងកងទ័ព ខាង៧០៣ ។

**ស៖** សូមអរគុណ ។ ពីព្រឹកមិញលោកបានជម្រាបហើយជម្រាបទៀតថា អ្នកដែលមានសិទ្ធិសម្រេច គឺមានក្រុមបួន ដែលលោកបានមានប្រសាសន៍អង្គសវនាការថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះ ។ ក្រៅពីបួនក្រុមនេះ ខ្ញុំមិនចាំបាច់រៀបរាប់ឡើងវិញទេ ។ នៅក្នុងមន្ទីរស-២១ តើមានអ្នកណាមួយទៀត មានសិទ្ធិសម្រេចយកទៅកម្ទេច ឬសម្លាប់ដែរឬទេ?

**ឆ៖** លោក គឹមសួន ដំបូងខ្ញុំសូមកែពាក្យលោកមួយម៉ាត់ណ៎ា សូមកែពាក្យលោកមួយម៉ាត់ លោកមានប្រសាសន៍ដំបូងថា ក្រុមបួន មិនមែនបួនក្រុមទេ ។ ន័យខុសគ្នា ។ ដូច្នេះ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតហ្នឹង មានបួនក្រុម ។ ខ្ញុំសូមអនុញ្ញាតមិនទាន់ជម្រាបឈ្មោះទេ នៅពេលដែលតុលាការកំពុងតែដំណើរការ អ្នកណាខ្លះ? ក្រៅពីបួនក្រុមនេះ គ្មានអ្នកណាមានសិទ្ធិសម្រេចកម្ទេចទេ ។ ហ្នឹងហើយបានជាគេត្រូវតែហៅជនទាំងបួនក្រុមនេះ ថាជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងច្បាប់កម្ពុជា ។

**ស៖** សូមអរគុណ ។

**ឆ៖** បាទ ។

**លោក ហុង គីមសួន៖**

ខ្ញុំសូមជម្រាបលោកប្រធានបន្តិច ហើយសូមឱ្យ ឌុច គាត់បង្ហាញ ឬពន្យល់ទាក់ទងជាមួយឯកសារលេខ D21 ជាភាសាខ្មែរ នៅក្នុងទំព័រទី៥ ។ ខ្ញុំសូមអនុញ្ញាតបញ្ចាំង ដើម្បីឱ្យបានឃើញទាំងអស់គ្នា ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារនោះ ដាក់បញ្ចាំងលើកកញ្ចក់អេក្រង់ទូរទស្សន៍ ។

**លោក ហុង គីមសួន៖**

នេះជាឯកសារដែលបានឆ្លើយជាមួយសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ ។ សូមលោកពន្យល់ទាក់ទងនឹង-- ខ្ញុំគូស *ហាយឡាយ* ពណ៌លឿងលើអក្សរទាំងពីរបន្ទាត់នេះក្នុងអង្គសវនាការ ថាតើមានន័យយ៉ាងម៉េច ចំពោះឈ្មោះ ហ៊ី ដែលមានសិទ្ធិសម្រេច ឬកម្ទេច?

ខ្ញុំសូមអនុញ្ញាតឱ្យក្រឡាបញ្ជីអានផង លោកប្រធាន ដើម្បីឱ្យបានឮ ។

**ប្រធានអង្គជំនុំ៖**

លោកស្រី សែ កុលវុឌ្ឍី អាននៅត្រង់ចំណុចឆ្លើយ ហើយមានអក្សរដោយ *ហាយឡាយ* ដោយពណ៌លឿងនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

ទាក់ទងនឹងការសម្រេច វាមានដំបូង គឺមាគ៌ារបស់បក្ស គ្រប់ជនដែលគេឃាត់ខ្លួនត្រូវតែកម្ទេចច្បាស់ជាងនេះទៀត ទាក់ទងនឹង ស-២១ គឺ ហ៊ី ជាអ្នកសម្រេច ។

**ជនជាប់ចោទ៖**

តុលាការជាទីគោរព! ខ្ញុំសូមអនុញ្ញាតបញ្ជាក់បញ្ហានេះឱ្យច្បាស់ មួយឃ្លាខាងដើម ទាក់ទងនឹងការសម្រេច វាមានដំបូង គឺមាគ៌ាបក្ស គ្រប់ជនដែលឃាត់ខ្លួនត្រូវតែកម្ទេច ។ ដូច្នេះ វាបន្តមួយឃ្លាទៅទៀត អ្នកដែលគេចាប់មកដល់ស-២១ គ្នាងាប់ហើយស្រេចហើយ គ្នាស្លាប់ស្រេចហើយ ។ ស-២១ ប៉ុនតែដោះលែង អ្នកឯងត្រូវកំបុតក ។ ដូច្នេះ ឧក្រិដ្ឋកម្ម ដែលហ៊ី ប្រព្រឹត្តទៅលើគ្នាហ្នឹង គឺឧក្រិដ្ឋកម្មដែលប្រព្រឹត្តទៅលើមនុស្សស្លាប់ស្រេច ។ ដូច្នេះ ប្រចាំថ្ងៃ ហ៊ី គ្នាចាំមើល ថ្ងៃណា ដែលយើងសួរ

ចម្លើយហើយ គេយកចេញហើយ ។ ដូច្នេះ កុំឲ្យវាស្ទះ ។ ដូច្នេះ ឧក្រិដ្ឋកម្មទី២នេះ ហ៊ា ជាអ្នកសម្រេចណ៎ា ធ្វើមិញកុំឲ្យវាគរ គ្នាសម្លាប់មនុស្សដែលគេសម្រេចរួចទៅហើយ ។ អាអ្នកសម្រេច គឺអាប្អូនក្រុមហ្នឹងរួចទៅហើយ នេះសូមបញ្ជាក់ឲ្យច្បាស់ ។

**លោក ហុង គឹមសួន៖**

សូមអរគុណ សូមលោកប្រធានត្រឡប់ទៅរកភាពដើមវិញ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងរូបភាព បង្វែរទៅរកភាពដើមវិញ ហើយមន្ត្រីដកឯកសារនេះចេញ ។

**សួរដោយលោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ខ្ញុំបាទ សូមសួរសំណួរតទៅទៀត ។

**ស៖** លោកឌុច តាំងពីពេលលោកចូលធ្វើការងារក្នុងនាមជាអ្នកគ្រប់គ្រងមន្ទីរស-២១ តើមានការចាប់មនុស្សច្រឡំឬទេ? ហើយតើមានការដោះលែងដែរឬទេ តាំងពីចាប់ផ្តើមរហូតដល់បញ្ចប់ការងារលោក?

[១៥:៤៨:៤៧]

**ឆ៖** អរគុណលោក គឹមសួន ជាគោលការណ៍ណ៎ា នៅ ស-២១ ចាប់ច្រឡំ ឲ្យតែចូលទៅដល់ខាងក្នុងហើយ អត់លែងទេ នេះជាគោលការណ៍ ។ ចាប់ច្រឡំមានម្នាក់មែន មិត្តស៊ីន ទៅហៅមនុស្សឯណាទេ មកច្រឡំ មិនមែន សុភា ថ្ងៃនោះប្រុងចាប់ សុភា ។ ដល់មិត្ត ស៊ីម-- មិត្តលីន គាត់នៅជាមួយនឹងខ្ញុំ ។ មិត្តលីន ខ្ញុំសូមបញ្ជាក់លោក គឹមសួន ឡើងវិញ នីរសារផ្ទាល់របស់បងប៉ុល ។ មិត្តលីន គាត់នៅជាមួយនឹងខ្ញុំ គាត់ឃើញទាន់ ។ គាត់ថា អ៊ើ មិនមែនទេ បងឌុច កុំយកទៅចូលក្នុង ទុកនៅខាងក្រៅនេះហើយ ខ្ញុំទៅសួរយោបល់សិន ។ មកវិញដោះលែងបាត់ទៅ ។

ដូច្នេះជាគោលការណ៍ វាគោលការណ៍ ក៏ប៉ុន្តែជាក់ស្តែងចាប់ច្រឡំមានម្នាក់មែន ក៏ប៉ុន្តែអត់បានកម្ទេចទេ ដោះលែងទៅវិញ ព្រោះយើងអត់បានបញ្ចូលទៅដល់ខាងក្នុង ។ នេះជារឿងពិត ។ ឯចំណែកការសុំដោះលែងមាន ខ្ញុំមាន ក៏ប៉ុន្តែសម្រេចបានតែពាក់កណ្តាលទេ ពាក់កណ្តាលដោះលែង ចំពោះអ្នកគួរ ហើយនិងអ្នកឆ្កាក់។ ខាងលើសម្រេចទុកជីវិត សម្រាប់ទៅធ្វើវិមាននៅវត្តភ្នំ នេះបានតែប៉ុន្មាន បីនាក់បួននាក់ ប៉ុណ្ណឹងឯង ក្រៅពីហ្នឹងអត់ទេ ដូចលោក ជុំ ម៉ី អីហ្នឹង មកធ្វើការហ្នឹង មិនទាន់បានសម្រេចពីខាងលើនៅឡើយទេ ។

**ស៖** សូមអរគុណ ។ ទាក់ទងទៅក្នុងបន្ទប់ ឬអគារនៃស-២១ តើលោកមានចាត់ចែង ឬបង្គាប់បញ្ជាអ្នកក្រោមបង្គាប់លោក ប្រភេទណាជាអ្នកយាមខាងក្នុងបរិវេណ អ្នកយាមប្រភេទណាយាមពីក្រៅបរិវេណ និងអ្នកយាមប្រភេទណា យាមដើរតាមមុខបន្ទប់នៃអគារនីមួយ?

**ឆ៖** រឿងនេះ ខ្ញុំនិយាយរួចហើយ ប៉ុន្តែលោក គឹមស្រួន សួរនេះ គឺចង់បញ្ជាក់ឲ្យច្បាស់ ខ្ញុំសូមបញ្ជាក់ជូនពីរបីម៉ាត់ ជូនដូចតទៅ ។

**ស៖** សូមទោស ទាក់ទងនឹងកងពិសេស ឬកងធម្មតា?

**ឆ៖** ត្រូវហើយៗ សូមបញ្ជាក់ជូនពីរបីម៉ាត់ ដូចតទៅ៖ កងធម្មតា យាមនៅខាងក្នុង ឲ្យបាយឲ្យទឹកអ្នកនៅខាងក្នុងគុក ឯចំណែកកងពិសេស យាមអាគុកពិសេសរបស់ មិត្តប៉ុន ហើយនិងយាមក្រវែលជុំវិញបរិវេណហ្នឹងទាំងមូល បរិវេណស-២១ ទាំងមូល ប៉ុន្តែបរិវេណគុករបស់ស-២១ ទេ មិនមែនបរិវេណវិទ្យាល័យពញាយ៉ាតទេ បរិវេណស-២១ ទាំងមូល កងពិសេស ។

**ស៖** សូមអរគុណ ។ សំណួរខ្ញុំមួយទៀតនេះ សូមអនុញ្ញាត មិនដឹងជាទាក់ទង ឬក៏អត់ទេ សូមអនុញ្ញាតលោកប្រធាន ។ ទាក់ទងនឹងមន្ទីរបឹងត្របែក និងស-២១ តើមានទាក់ទងគ្នាដែរឬទេ?

**ឆ៖** អរគុណលោកប្រធាន អនុញ្ញាតឲ្យយើងហើយ ។ ឥឡូវខ្ញុំសូមបញ្ជាក់ថា បឹងត្របែកផ្សេងគ្រប់គ្រងដោយគណៈកម្មាធិការរបស់គេផ្សេង ឯចំណែកស-២១ វាគ្រប់គ្រងដោយគណៈកម្មាធិការរបស់វាផ្សេង មេទៅពីខាងលើក៏ខុសគ្នាដែរ ។ សូមចប់ ។

[១៥:៥២:១៩]

**ស៖** សូមអរគុណ ។ ជាបន្តទៅទៀត តើនៅក្នុងអំឡុងលោកគ្រប់គ្រងមន្ទីរស-២១ តើអ្នកទោសមានដែលបញ្ជូនពីបឹងត្របែកចូលមន្ទីរស-២១ ដែរឬទេ?

**ឆ៖** អរគុណលោក គឹមស្រួន សួរហ្នឹង ប៉ុន្តែដូចជាកិច្ចដំណើរការរបស់ស-២១ ហើយលោកយ៉ាងម៉េច? យើងមើលសាច់រឿង យើងមើល?

**ស៖** ខ្ញុំមិនសួរលម្អិតទេ គ្រាន់តែថា តើទទួលអត់ឬទេ?

**ឆ៖** អ៊ីចឹងហ៎! អ៊ីចឹងអី ប៉ុន្តែវាចូលដល់ដំណើរការយើងហើយ ។ បឹងត្របែកមានបញ្ជូនមនុស្សមក ក៏ប៉ុន្តែខាងលើសម្រេចពីខាងលើមក ។

**ឆ៖** សូមអរគុណ ។ ខ្ញុំបាទ សូមអនុញ្ញាតលោកប្រធាន សូមឲ្យមានបញ្ចាំងឆ្លាក្រាម ឬអង្គការលេខមួយ ដែលជាភាសាអង់គ្លេស ខ្ញុំរកភាសាខ្មែរមិនបាន ។ នៅក្នុងឯកសារលេខ D21 បើសិន

ជាលោក ឌុច អាចបានយល់ សូមពន្យល់លើដ្យាក្រាម ព្រោះយើងអត់ដែលបានពន្យល់ ឬបង្ហាញទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតឲ្យមន្ត្រីតុលាការចាត់ការ ។

**លោក ហុង គីមសួន៖**

**ស៖** សូមឲ្យលោក ឌុច ពិនិត្យមើល តើលោកអាចពន្យល់បានទេ លើឯកសារនេះ ព្រោះខ្ញុំអត់មានជាភាសាខ្មែរទេ?

**ឆ៖** ដំបូងខ្ញុំសូមជម្រាបថា អាមួយជួរខាងលើហ្នឹង ប្រអប់ពីរខាងលើហ្នឹងត្រឹមត្រូវហើយ ។ ប្រធានចាស់របស់ស-២១ គឺ អ៊ិន លន ហៅ ណាត ឬ អ៊ិន ណាត រួចដល់បន្តមកប្រធានរបស់ស-២១ កាំង ហ្គេកអ៊ាវ ហៅឌុច ប៉ុន្តែសរសេរឈ្មោះខ្ញុំខុស តែប៉ុណ្ណឹងទេ ។ ដូច្នេះ អាលើហ្នឹងត្រឹមត្រូវ ។

[១៥:៥៥:១៣]

ចំណែក ប្រអប់ដំបូងនៅក្នុងជួរទីពីរនេះ ខុស ។ ខ្ញុំអត់មានចាត់តាំងអ្នកណាជាប្រធានទេ គេចូលចិត្តច្រឡំថាខ្ញុំចាត់តាំងបង ម៉ម ណៃ ជាប្រធាន ហើយមិត្តប៉ុន ជាអនុប្រធាន ។ មិនត្រូវទេ មិត្តប៉ុន សួរចម្លើយបុគ្គលពិសេស បង ម៉ម ណៃ មុនដំបូងខ្ញុំប្រើជាជំនួយការ-- អឺ!នៅតែប្រើជាគាត់ជាជំនួញការសឹងតែរហូតហ្នឹង ហើយនឹងសួរចម្លើយពួកវៀតណាម ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។ ប្រអប់ដំបូងនៃជួរទីពីរនេះមិនត្រូវទេ ។ ប្រអប់ទីពីរនៃជួរទីពីរនេះ តួនាទីរបស់ មិត្តហ៊ី រួញហើយ ។ តួនាទីរបស់ មិត្តហ៊ី គ្រប់ដណ្តប់ទាំងអស់ ។

មែនអាប្រអប់ទីបីនេះត្រឹមត្រូវ ចប់ហើយៗ ។ ដូច្នេះ មួយជួរទីពីរនោះត្រឹមត្រូវ ។

ក្រុមទីមួយ “ក្រុមក្តៅ” ក្រុមទីពីរ “ក្រុមត្រជាក់” ក្រុមទីបី “ក្រុមអង្កៀម” ។ ខ្ញុំសូមជម្រាបបញ្ជាក់ថា ក្រុមនេះចែកមែន ប្រធានក្រុមគេគ្រប់គ្រងមែន ខ្ញុំភ្លាប់មិនបានអ្នកណាជាអ្នកណីទេ ។ ក៏ប៉ុន្តែនៅមន្ទីរស-២១ ពិតជាមានឈ្មោះ ដែក ប៊ូ, មានឈ្មោះ មិត្តម៉េង ឈ្មោះទីពីរនេះ មើលមិនដាច់ទេ ឈ្មោះ ចាន់ មិនដឹង ចាន់ ណា មិនដឹង ។ ហើយក្រុមទី-- ក្រុមត្រជាក់ មិនដឹងទេ មិនដឹងអ្នកណា “ច” ណា “ឈ” ណាទេ ប្រធាននេះ ខ្ញុំមិនដឹងទេ ។ ហើយមានមិត្ត ឡាច មាន, ឡាច មាន នេះខ្ញុំមិនដែលស្គាល់ទេ ។ ហើយក្រុមអង្កៀមមានឈ្មោះ ទិត ន៉ែ ទិត នៅក្រុមអង្កៀមផង នៅក្រុមក្តៅផង ។ លោកសង្ខេបឃើញហើយ ខ្ញុំក៏សង្ខេបឃើញបញ្ហាហ្នឹងមួយ ។ ហើយនៅខាងក្រោមហ្នឹង មានឈ្មោះ ប្រាក់ ខន ម្នាក់ ។ សូមបញ្ជាក់ថា ប្រាក់ ខន ហ្នឹង កាលពីនៅ ស-២១ ខ្ញុំមិនដែលស្គាល់មុខទេ ។ ប៉ុន សួរ

ចម្លើយអ្នកទោសសំខាន់ ។ ហើយក្រុមបីក្រុមនេះ សួរចម្លើយមនុស្សធម្មតា ។ ហើយអ្នកទោសបរទេស សួរចម្លើយដើម្បីផ្សាយវិទ្យុយួន ហើយអត់មានដាក់អ្នកណាទេ ។

ដូច្នេះ ដ្យាក្រាមនេះ និយាយរួមមួយម៉ាត់មិនត្រឹមត្រូវប៉ុន្មានទេ ។ ហើយស្អី--

**ប្រធានអង្គជំនុំ៖**

បានហើយ-- ផ្អាកសិនជនជាប់ចោទ ។ យ៉ាងម៉េចទៅ សហព្រះរាជអាជ្ញា មានបំណងអ្វីទៅនុ៎ង? សូមអញ្ជើញ ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

សាជាថ្មី ខ្ញុំសូមទោស ដែលខ្ញុំកាត់សម្តី ។ គឺលោក ខ្ញុំចង់ឲ្យបញ្ជាក់ ថាតើអង្គការលេខនេះ គឺចេញមកពីណា? អ្នកណាគេជាអ្នកបង្កើត? ហើយខ្ញុំអត់ដឹងអំពីវត្តមាន ឬក៏អាទិភាពនៃអង្គការលេខនេះទេ ។ ហើយខ្ញុំចង់ដឹងថាតើតារាងនេះកើតចេញពីណា? អ្នកណាអ្នកបង្កើត? ហើយខ្ញុំឆ្ងល់ ហើយចង់សួរលោក ហុង គឹមសួន ទៅលើបញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅលោក ហុង គឹមសួន អាចឆ្លើយនឹង-- ពន្យល់បញ្ហានេះបានទេ?

**លោក ហុង គឹមសួន៖**

សូមអរគុណ លោកប្រធាន។ ឯកសារទាំងអស់នេះ ខ្ញុំបាទ មិនដឹងចេញពីប្រភពណាទេ ប៉ុន្តែខ្ញុំសិក្សាលើសំណុំរឿងជាឯកសាររបស់សហចៅក្រមស៊ើបអង្កេត លេខD21 ដែលផ្តើមពីលេខ ERN-- បាទ កំណត់ហេតុជាភាសាអង់គ្លេស ។ មានទំព័រជា ERN ដំបូង 00149907 ហើយឯកសារដែលកំពុងបញ្ចាំងនេះ មានលេខ ERN 00149919 ។

ដូច្នេះ ខ្ញុំបញ្ជាក់ជូនបានប៉ុណ្ណេះ ។ បាទ, សូមអញ្ជើញ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះមានបញ្ហាខ្លះ ដោយសារតែឯកសារនេះមានតែជាភាសាអង់គ្លេសទេនៅក្នុងសំណុំរឿង ដែលធ្វើការពិនិត្យឡើងវិញ គឺឃើញក៏ដូចគ្នា បានន័យថាឃើញអត់មានជាភាសាខ្មែរទេ ។ ហើយយកភាសាអង់គ្លេសមកដេញដោលវាជាបញ្ហា ប៉ុន្តែទោះបីយ៉ាងណា ការខិតខំរបស់ជនជាប់ចោទបានបញ្ជាក់ច្រើនហើយ ។ ប៉ុន្តែ ជារួមគឺមានភាពមិនត្រឹមត្រូវខ្លះ បានន័យថា មិនស៊ីគ្នាជាមួយអ្វីដែលគាត់បានគូរដោយរចនាសម្ព័ន្ធដោយខ្លួនគាត់ ហ្នឹងគឺឲ្យអង្គជំនុំជម្រះអាចយល់បានខ្លះហើយ ។ ហើយអង្គជំនុំជម្រះ

ឲ្យបញ្ចប់នូវការបង្ហាញចំណុចនេះ បញ្ហានេះត្រឹមនេះ ។

ហើយបញ្ហាមួយទៀត អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មានហេតុផលតិចតួចទេ។ ប្រហែលជាអាចភាគីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីភ្លេច កាលពីការរំឭករបស់អង្គជំនុំជម្រះពីម្សិលមិញថា ប្រសិនបើភាគដែលមានប៉ុនប៉ងនៃការសួរ ហើយការប្រើប្រាស់ឯកសារដើម្បីជាការបញ្ជាក់អីផ្សេងៗ សូមឲ្យបញ្ជូនឯកសារហ្នឹងមកដល់ក្រឡាបញ្ជីនៃអង្គសវនាការជាមុន ដើម្បីយើងត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ នៅក្នុងការចាត់ចែងនៅក្នុងការពិភាក្សាឲ្យបានល្អជាងនេះ ។

យើងខ្ញុំសង្ឃឹមថាប្រហែលជាក្រោយទៀតៗ យើងអាចនឹងទទួលបានលទ្ធផលវិធីនេះដោយល្អប្រសើរ នៅក្នុងការពិភាក្សាដេញដោល ។

**សួរដោយលោក ហុង គីមសួន៖**

សូមអរគុណ លោកប្រធាន ដែលបានដាស់តឿន ដោយសារការសាកសួរទៅចេះតែទៅមុន វាអាចភ្លេចអំពីការណែនាំ ។ អូ! ជាបន្តទៅទៀត ខ្ញុំបាទសុំអនុញ្ញាតត្រឡប់មកក្នុងមន្ទីរស-២១ វិញដដែលទេ ។

**ស៖** តើលោក ឌុច លោកបានរៀបចំ ឬបង្គាប់ដល់អ្នកគ្រប់គ្រងអ្នកទោសដាច់ដោយឡែកគ្នាឬទេ? អំពីការឲ្យជារបបហូប ឬរបបស្លៀកពាក់ ។ លោកមានចេញបញ្ជា ឬចែងជាគោលការណ៍ឲ្យដល់ពួកគេដែរឬទេ?

**ឆ៖** កិច្ចការអស់នេះ ខ្ញុំមិនចូលទៅជ្រៅ ប៉ុន្តែតាមឃើញឯកសារដែលនៅសល់ ហើយខ្ញុំអានឥឡូវនេះណា មានការបែងចែករបបហូបមិនត្រូវគ្នាទេ ពីសម័យ ណាត ។ ប៉ុន្តែ ដល់ក្រោយមកដល់ណាត ចេញទៅមិនដឹងយ៉ាងម៉េចទៀត ។ ខ្ញុំគិតថាវាឯកភាព មិនបែងចែកអ្នកទោសធ្ងន់ អ្នកទោសស្រាល អ្នកទោសណាដែលធ្វើបាបអី ដូចមិនអាចនេះ ប៉ុន្តែ អត់ស្មើរទាំងអស់គ្នាហ្នឹង ។

**ស៖** សូមអរគុណ ។ ទាក់ទងជាមួយនឹងស្ត្រីដែលជាអ្នកទោសបញ្ជូនទៅមន្ទីរស-២១ មានកូនតូច ។ តើមានគោលការណ៍ ឬការណែនាំពីលោកដែរឬទេ ក្នុងការឃុំឃាំងដាច់ដោយឡែក ឬជុំគ្នាជាមួយអ្នកទោសស្ត្រីអត់កូន?

[១៦:០៥:០៨]

**ឆ៖** រឿងនេះខ្ញុំអត់ច្បាស់សោះ សូម្បីតែដល់ក្រោយមកនុំងគេប្រាប់ខ្ញុំថា អ្នកទោសស្ត្រីអត់មានដាក់ខ្នោះទេ ។ ខ្ញុំឆ្លើយថា អាហ្នឹងជារឿង មិត្តហ៊ ទេ គេមានគុណសម្បត្តិមិនដាក់ខ្នោះស្ត្រី អាហ្នឹងជា

រឿងរបស់គេទេ ខ្ញុំអត់នេះទេ ។

ដូច្នេះ ខ្ញុំអត់បានគិត បានគូអីទេរឿងហ្នឹង ។ ប៉ុន្តែ ឧក្រិដ្ឋកម្មរបស់ខ្ញុំក្នុងរឿងឃុំឃាំងស្រី ហើយនឹងបំបែកយកកូនចេញ អាហ្នឹងជាមាគ៌ាដែលខ្ញុំណែនាំ តាមគោលការណ៍ចាស់ ។

**លោក ហុង គឹមសួន៖**

លោកប្រធាន សូមអនុញ្ញាតបើ-- តើពេលវេលានេះសមល្មមនឹងសម្រាកសិន ឬក៏អនុញ្ញាតឲ្យខ្ញុំបន្តទៅទៀត?

**ប្រធានអង្គជំនុំ៖**

លោកមានការប៉ុនប៉ងនូវការតាំងសំណួរច្រើនទេ?

**លោក ហុង គឹមសួន៖**

ប្រហែលជាបួនប្រាំសំណួរទៀតដែរ បាទៗ ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង អង្គជំនុំជម្រះមិនអាចអនុញ្ញាតឲ្យលោកធ្វើការសំណួរសួរបន្តទៀតទេ ។ ដោយហេតុអង្គជំនុំជម្រះ ដល់ពេលត្រូវប្រកាសសម្រាក ឥឡូវនេះហើយ ។ អ៊ីចឹងសំណួរដែលលោកប៉ុនប៉ងសួរនោះ គឺទុកលើកទៅថ្ងៃស្អែក ។

សូមអញ្ជើញ លោក ហ្សង់ម៉ាក តើមានសំណួរអ្វីទៀត?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន ខ្ញុំចង់និយាយអំពីតារាងអង្គការលេខ ដែលបានបង្ហាញអម្បាញ់មិញជាភាសាអង់គ្លេសនេះ ដើម្បីឲ្យធ្វើការបង្ហាញថា អង្គការលេខហ្នឹង តាមពិតគឺមានបញ្ចូនទៅក្នុងសំណុំរឿងនោះ គឺជាឧបសម្ព័ន្ធបន្ថែមទៅលើកំណត់បទសម្ភាសន៍សួរចម្លើយមួយដែលខាងសហចៅក្រមស៊ើបអង្កេតបានធ្វើកាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៧ ។

នៅក្នុងកិច្ចសម្ភាសន៍នោះ មានការលើកឡើងថា តារាងអង្គការលេខនេះគឺមានបានបញ្ចូនជាឧបសម្ព័ន្ធ ហើយតារាងអង្គការលេខនេះតាមពិត ត្រូវបានរៀបចំដោយអ្នកស៊ើបអង្កេតនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ហើយពេលនុ៎ង នៅក្នុងអំឡុងពេលបទសម្ភាសន៍នោះ គឺជនជាប់ចោទត្រូវបានសួរឲ្យផ្តល់មតិយោបល់ទាក់ទងនៅនឹងអង្គការលេខនេះ ។ ហើយក្រោយមកគឺថាគាត់បានឆ្លើយតបទៅនឹងចម្លើយទាំងនុ៎ង ។ នេះគ្រាន់តែជាចំណុចបញ្ជាក់ដើម្បីឲ្យដឹងថា តើតារាងអង្គការលេខហ្នឹង

បានមកពីណា? ឬក៏ តើអ្វីទៅជាប្រភពនៃតារាងអង្គការលេខនោះ?

[១៦:០៨:០១]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងនៅដំណើរការសវនាការថ្ងៃនេះ អង្គជំនុំជម្រះសម្រេចថាសម្រាកត្រឹមពេលនេះ ។ ហើយអង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកសវនាការ ហើយលើកទៅបន្តសវនាការនៅថ្ងៃស្អែក ។ មូលហេតុដែលត្រូវការឈប់សម្រាកមុនម៉ោងបន្តិចនេះ ដោយកិច្ចការមួយចំនួនអង្គជំនុំជម្រះសាលាដំបូងត្រូវប្រជុំពិភាក្សា ដើម្បីធ្វើកិច្ចមួយចំនួនដែលជាការចាំបាច់ ដើម្បីដំណើរការកិច្ចការ ដំណើរការសវនាការជាបន្តបន្ទាប់នៅសប្តាហ៍ក្រោយៗទៀត ។

អ៊ីចឹង សវនាការនឹងលើកទៅបន្តនៅថ្ងៃស្អែក អ៊ីចឹងគឺពេលវេលាចាប់ពីម៉ោងប្រាំបួនទៅ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់ទីនេះថ្ងៃស្អែក ចាប់ពីម៉ោងប្រាំបួនព្រឹក ។ ហើយសូមជម្រាបដល់អ្នករួមនៅក្នុងដំណើរការនីតិវិធីសវនាការ សូមអញ្ជើញកាន់ទីកន្លែងរៀងៗខ្លួន ឲ្យបានមុនម៉ោងប្រាំបួនព្រឹក ៕

*[សវនាការផ្អាកនៅម៉ោង ១៦:០៩ នាទី]*